ក្រសួងអប់រំ យុវជន និងកីឡា

# ការពង្រឹងការអនុវត្តការអប់រំបំណិនជីវិត នៅកម្រិតមធ្យមសិក្សាបឋមភូមិ





អ៊ុន ស្រីណែត

ស៊ីវ សម្ផស្ស

ឈឹម ឫទ្ធិវង្ស

អ៊ីវ ចាន់ណារ៉ា



**នាយកដ្ឋានគោលនយោបាយ** កញ្ញា ២០១៩

ក្រសួងអប់រំ យុវជន និងកីឡា

# ការពង្រឹងការអនុវត្តការអប់រំបំណិនជីវិត នៅកម្រិតមធ្យមសិក្សាបឋមភូមិ

អ៊ុន ស្រីណៃត

ស៊ីវ សម្ផស្ស

ឈឹម ឫទ្ធិវង្ស

អ៊ីវ ចាន់ណារ៉ា

នាយកដ្ឋាន គោលនយោបាយ

កញ្ញា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ក្រុមការងារស្រាវជ្រាវសូមថ្លែងអំណរគុណជាអនេកចំពោះថ្នាក់ដឹកនាំនៃក្រសួងអប់រំ យុវជននិងកីឡា ជាពិសេសអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការដែលបានអនុញ្ញាតឱ្យក្រុមស្រាវជ្រាវនៃនាយកដ្ឋានគោលនយោបាយដំណើរការការស្រាវជ្រាវនេះ។

ក្នុងនោះ ក្រុមការងារ សូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍គឺយូនីសេហ្វដែលបានផ្តល់ការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដើម្បីដំណើរការស្រាវជ្រាវ។

ជាមួយគ្នានេះដែរ សូមថ្លែងអំណរគុណជាពិសេសចំពោះ លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា ប្រធាននាយកដ្ឋានគោលនយោបាយចំពោះផ្តល់ការណែនាំ ការគាំទ្រទាំងកម្លាំងកាយចិត្តយ៉ាងសស្រាក់សស្រាំក្នុងដំណើរការនៃការសិក្សាដើម្បីជំរុញឱ្យការងារនេះប្រព្រឹត្តទៅបានរលូន។

ក្រុមការងារក៏សូមថ្លែងអំណរគុណដល់តំណាងទាំងអស់មកពីនាយកដ្ឋានពាក់ព័ន្ធ ជាពិសេសនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈសម្រាប់ការចូលរួមផ្តល់មតិយោបល់ និងធាតុចូលបន្ថែមទៀតទៅក្នុងសេចក្តីព្រាងនៃការសិក្សា។

ឆ្លៀតក្នុងឱកាសនេះ ក្រុមការងារក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិកក្រុមការងារនៃនាយកដ្ឋានគោលនយោបាយ និងអ្នកពាក់ព័ន្ធទាំងអស់ព្រមទាំងអ្នកចូលរួមមកពីខេត្តទាំង៩។ ជាក់ស្តែង ការសិក្សានេះនឹងមិនអាចសម្រេចបានជាលទ្ធផលទេ ប្រសិនបើមិនមានការសហការពីគ្រប់ភាគី។

# មូលន័យសង្ខេប

ការអប់រំបំណិនជីវិតមានសារៈសំខាន់ណាស់ក្នុងការពង្រឹងសមត្ថភាពចិត្តសង្គម និងជំនាញវិជ្ជាជីវៈរបស់បុគ្គលម្នាក់ៗដើម្បីប្រជែងនឹងតម្រូវការសម្រាប់បរិបទតំបន់ និងសាកលភាវូបនីយកម្ម។ រហូតមកដល់ពេលនេះការអប់រំបំណិនជីវិតត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់ជាតិសម្រាប់ថ្នាក់អនុវិទ្យាល័យ។ ទោះយ៉ាងណា ការអនុវត្តត្រូវបានរាំងស្ទះដោយកត្តាជាច្រើន។ ដូច្នេះការសិក្សាស្រាវជ្រាវនេះ ព្យាយាមរកភស្តុតាងសំខាន់ៗដើម្បីបង្ហាញពីស្ថានភាពបច្ចុប្បន្ននៃការអនុវត្តការអប់រំបំណិនជីវិតនៅតាមអនុវិទ្យាល័យនៃប្រទេសកម្ពុជាដោយរកឱ្យឃើញនូវបញ្ហាប្រឈមដែលកំពុងជួបប្រទះក្នុងអំឡុងពេលអនុវត្ត និងបំណិនជីវិតតាមមូលដ្ឋានដែលជាតម្រូវការចាំបាច់ និងបំផុសបទអន្តរាគមន៍ជាយុទ្ធសាស្ត្រដើម្បីធ្វើឱ្យការអនុវត្តដំណើរការបានប្រសើរឡើង។ ដើម្បីទទួលបានលទ្ធផលគ្រប់ជ្រុងជ្រោយ ការសិក្សានេះបានជ្រើសរើសអ្នកចូលរួមដោយចៃដន្យចំនួន ៦៨៥ នាក់ពីខេត្តចំនួន ៩ ដែលក្នុងនោះរួមមាន ថ្នាក់ខេត្ត (មន្ទីរ.អយក) ថ្នាក់ស្រុក (ការិយាល័យ.អយក) ថ្នាក់សាលារៀន (នាយក ឬនាយិកាសាលា, គ្រូ និងសិស្ស) និងសហគមន៍ (គណៈកម្មការទ្រទ្រង់សាលា អាជ្ញាធរមូលដ្ឋាន និងអាណាព្យាបាលសិស្ស)។ គួរបញ្ជាក់ផងដែរថាសាលាដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវត្រូវបានជ្រើសរើសទាំងសាលាដែលធ្លាប់ និងមិនធ្លាប់ទទួលបានការជួយគាំទ្រពីដៃគូអភិ វឌ្ឍន៍នានា។ ក្នុងចំណោមនោះមានសាលាខ្លះដែលត្រូវបានគាំទ្រដោយដៃគូអភិវឌ្ឍន៍ផ្សេងៗ។ ក្រុមអ្នកស្រាវជ្រាវបានចែកកម្រងសំណួរទៅឱ្យអ្នកចូលរួមឆ្លើយ។ ដើម្បីធានាសុក្រឹតភាពនៃទិន្នន័យ ក្រុមអ្នកស្រាវជ្រាវបានធ្វើការសម្ភាសអ្នកចូលរួមដោយ កំណត់យកតែម្តង (purposive sampling)។ ទិន្នន័យដែលទទួលបានត្រូវបានយកទៅវិភាគតាមបែបបរិមាណវិស័យ បញ្ជាក់គឺស្ថិតិបែបពណ៌នាក្នុង SPSS 23 និងបែបគុណវិស័យ ពោលគឺការវិភាគជាលក្ខណៈគំនិតគោលៗ (Thematic)។ ការសិក្សានេះបានបង្ហាញថាការអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិហាក់នៅមានកម្រិតនៅឡើយ និងទាមទារឱ្យមានការយកចិត្តឱ្យខ្លាំងឡើងវិញ។ បញ្ហាប្រឈមមួយចំនួននៅតែបន្តកើតមានឡើងទាក់ទងនឹង ការយល់ដឹងពីកម្មវិធី និងការតម្រង់ទិសភាពជាអ្នកដឹកនាំដោយសារតែឯកសារគោលនយោបាយ និងឯកសារក្របខណ្ឌគតិយុត្តិពាក់ព័ន្ធនានាមិនទាន់បានចែកចាយគ្រប់គ្រាន់ទៅដល់អ្នកអនុវត្ត ហើយការណែនាំមិនទាន់ច្បាស់លាស់។ បញ្ហាប្រឈមមួយទៀតទាក់ទងនឹងបំណិនដែលកំពុងអនុវត្តមិនបានគ្របដណ្តប់បានពេញលេញមានដូចជា រោងជាង សិល្បៈ និងកុំព្យូទ័រ ជាពិសេសនៅថ្នាក់ទី៩ ដោយសារតែមិនទាន់មានធនធានដែលមានជំនាញ និងឯកទេស

បង្រៀនមុខវិជ្ជាបំណិនជីវិតច្បាស់លាស់មិនទាន់មានប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃត្រឹមត្រូវ ក៏ដូចជាមិនទាន់មានការសហការគាំទ្រលើធនធានសម្រាប់បង្រៀន និងរៀនជំនួយបច្ចេកទេស និងការលើកទឹកចិត្តខាងផ្នែកស្មារតី និងធនធាន។ ខណៈដែលមុខវិជ្ជាខ្លះនៃបំណិនអាជីពងាយៗ ឬបំណិនជីវិតតាមមូលដ្ឋានមិនទាន់អនុវត្តបានពេញលេញ ការសិក្សាបាននេះក៏បានរកឃើញដែរថាមុខវិជ្ជាទាំងនោះពិតជាតម្រូវការខ្លាំងដើម្បីឆ្លើយតបនឹងតម្រូវការក្នុងតំបន់ ក៏ដូចជាសកលភាវូបនីយកម្ម។ មុខវិជ្ជាដែលជាតម្រូវការខ្លាំងបំផុតគឺមុខវិជ្ជាកុំព្យូទ័រ បន្ទាប់មកទៀតគឺកសិកម្ម គេហវិទ្យា រោងជាង និងសិល្បៈ។ ក្នុងនោះមានមុខវិជ្ជាខ្លះទៀតត្រូវបានស្នើសុំឱ្យបញ្ចូលក្នុងកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន ដូចជាការគ្រប់គ្រងហិរញ្ញវត្ថុ និងកែសម្ផស្ស។ ទាក់ទងនឹងបញ្ហាប្រឈមទាំងនោះ អ្នកពាក់ព័ន្ធមួយចំនួនបានរៀបរាប់ថាធ្លាប់បានចាត់វិធានផ្សេងៗមួយចំនួន
ប៉ុន្តែគេសង្កេតឃើញថាការអនុវត្តជាក់ស្តែងហាក់នៅមិនទាន់បានប្រសើរនៅឡើយ។ អាស្រ័យហេតុនេះ ក្រុមស្រាវជ្រាវបានស្នើនូវអនុសាសន៍ជាយុទ្ធសាស្រ្តមួយចំនួនទៅកាន់អ្នកពាក់ព័ន្ធសំខាន់នីមួយៗនៅគ្រប់កម្រិតទាំងអស់ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តការអប់រំបំណិនជីវិតតាមមូលដ្ឋាននៅតាមអនុវិទ្យាល័យដើម្បីជាថ្នាលសម្រាប់សិស្សានុសិស្សទាំងអស់ក្នុងការចាប់យកជំនាញបច្ចេកទេស ក៏ដូចជាបន្តការសិក្សាថ្នាក់ឧត្តមសិក្សា។

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| DCD | Department of Curriculum Development | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| DOEYS | District Office of Education, Youth and Sport | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក (ការិយាល័យ.អយក) |
| DP | Development Partners | ដៃគូអភិវឌ្ឍន៍ |
| DVO | Department of Vocational Orientation | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| EFA | Education for All | ការអប់រំសម្រាប់ទាំងអស់គ្នា |
| KAPE | Kampuchea Action for Primary Education | អង្គការសកម្មភាពសម្រាប់ការអប់រំកម្រិតបឋមសិក្សាកម្ពុជា |
| LSE | Life Skills Education | ការអប់រំបំណិនជីវិត |
| LA | Local Authorities | អាជ្ញាធរមូលដ្ឋាន |
| M&E | Monitoring and Evaluation | ការពិនិត្យតាមដាន និងវាយតម្លៃ |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| ( ក្រសួង. អយក) | United Nations Convention on the Rights of the Child | អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ |
| NEP | NGOs Education Partnership Cambodia | អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល |
| NGOs | Non-Government Organiza-tions | អង្គការក្រៅរដ្ឋាភិបាល |
| POEYS | Provincial Office of Education, Youth and Sport | មន្ទីរអប់រំ យុវជន និងកីឡា (មន្ទីរ.អយក) |
| PA | Parents | អាណាព្យាបាល |

| | | |
|---|---|---|
| R2R | Room to Read | អង្គការរូមធ្វូរីតកម្ពុជា |
| TVET | Technical and Vocational Education and Training | ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| T | Teachers | គ្រូ |
| SBM | School Based Management | ការគ្រប់គ្រងតាមសាលារៀន |
| SP | School Principals | នាយកឬនាយិកាសាលា |
| Ss | Students | សិស្ស |
| SSC | School Support Committee | គណៈកម្មការទ្រទ្រង់សាលា |
| UNICEF | The United Nations Children's Fund | មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ |
| UNESCO | The United Nations, Educational, Scientific, and Cultural Organization | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ |
| WHO | World Health Organization | អង្គការសុខភាពិភពលោក |

# មាតិកា


ថ្លែងអំណរគុណ ........ i

មូលន័យសង្ខេប ........ ii

អក្សរកាត់ ........ iv

មាតិកា ........ vi

បញ្ជីរូបភាព ........ ix

តារាង ........ xi

## ជំពូកទី ១: សេចក្ដីផ្ដើម ........ 1

១.១ ទិដ្ឋភាពទូទៅនៃការអប់រំបំណិនជីវិត ........ 1

១.២ បញ្ហានៃការស្រាវជ្រាវ ........ 4

១.៣ សារៈសំខាន់នៃការស្រាវជ្រាវ ........ 6

១.៤ គោលបំណងនៃការស្រាវជ្រាវ ........ 6

១.៥ សំណួរស្រាវជ្រាវ ........ 7

១.៦ ក្របខ័ណ្ឌនៃទស្សនាទាន ........ 7

១.៧ និយមន័យពាក្យគន្លឹះ ........ 9

១.៨ វិសាលភាពនៃការសិក្សា ........ 11

១.៩ រចនាសម្ព័ន្ធនៃរបាយការណ៍ស្រាវជ្រាវ ........ 11

## ជំពូកទី ២: បណ្ណាល័យសាស្ត្រ ........ 13

២.១ ការអនុវត្តការអប់រំបំណិនជីវិតក្នុងបរិបទសកលលោក ........ 13

២.២ ការអនុវត្តការអប់រំបំណិនជីវិតនៅក្នុងបរិបទកម្ពុជា ........ 18

២.៣ សេចក្ដីសន្និដ្ឋានបណ្ណាល័យសាស្ត្រ ........ 19

## ជំពូកទី៣: វិធីសាស្ត្រស្រាវជ្រាវ ........ 21

៣.១ អ្នកចូលរួម និងវិធីសាស្ត្រជ្រើសរើសសំណាកគម្រូ ........ 21

៣.២ ការប្រមូលទិន្នន័យ ........ 22

៣.២.១ ឧបករណ៍ស្រាវជ្រាវ ........ 22

៣.២.២ ដំណាក់កាលនៃការប្រមូលទិន្នន័យ ........ 24

៣.៣ ការវិភាគទិន្នន័យ ........ 24

៣.៤ សុពលភាព និងសុក្រឹតភាពនៃការស្រាវជ្រាវ ........ 25

## ជំពូកទី ៤: របកគំហើញ និងការពិភាក្សា ........ 28

៤.១ ព័ត៌មានប្រជាសាស្ត្ររបស់អ្នកចូលរួម ........ 28
៤.២ ស្ថានភាពបច្ចុប្បន្ននៃការអនុវត្តការអប់រំបំណិនជីវិត និងបញ្ហាប្រឈម ........ 36
៤.២.១ ការយល់ដឹងពីការអប់រំបំណិនជីវិត ........ 36
៤.២.២ ការប្រតិបត្តិការអប់រំបំណិនជីវិត ........ 39
៤.៣ មុខវិជ្ជាបំណិនជីវិតដែលជាតម្រូវការ ........ 65
៤.៤ បទអន្តរាគមន៍ដោយអ្នកពាក់ព័ន្ធ ........ 69
៤.៥ យោបល់របស់អ្នកចូលរួម ........ 75
៤.៥.១ ក្រសួង.អយក ........ 75
៤.៥.២ ថ្នាក់មន្ទីរ.អយក ........ 76
៤.៥.៣ ថ្នាក់ការិយាល័យ.អយក ........ 77
៤.៥.៤ នាយកឬនាយិកាសាលា ........ 78
៤.៥.៥ គណៈកម្មការទ្រទ្រង់សាលា ........ 79
៤.៥.៦ អាជ្ញាធរមូលដ្ឋាន ........ 80
៤.៥.៧ អាណាព្យាបាល ........ 81
៤.៥.៨ ដៃគូអភិវឌ្ឍន៍ ........ 82
៤.៦ ការពិភាក្សា ........ 82
៤.៦.១ ការពិភាក្សាអំពីបញ្ហាប្រឈមសំខាន់ៗនៃការអនុវត្តការអប់រំបំណិនជីវិត ........ 82
៤.៦.២ ការពិភាក្សាពីតម្រូវការជំនាញ ........ 85

## ជំពូកទី៥: សេចក្ដីសន្និដ្ឋាន និងអនុសាសន៍ ........ 87

៥.១ សេចក្ដីសន្និដ្ឋានរួម ........ 87
៥.២ ដែនកំណត់នៃការសិក្សាស្រាវជ្រាវ ........ 88
៥.៣ អនុសាសន៍សម្រាប់បទអន្តរាគមន៍ជាយុទ្ធសាស្ត្រ ........ 89
ឯកសារយោង ........ 97
ឧបសម្ព័ន្ធ ........ 99

# បញ្ជីរូបភាព


រូបភាព ១.១: ក្របខ័ណ្ឌទស្សនទានសម្រាប់ការពិនិត្យតាមដាន និងពង្រឹងការអនុវត្តការអប់រំបំណិនជីវិត ........ 9
រូបភាព ៤.១: ក្រាហ្វិចបង្ហាញការយល់ដឹងអំពីបំណិនជីវិត (n=៦៨៣) ........ 36
រូបភាព ៤.២: ក្រាហ្វិចបង្ហាញភាគរយអ្នកចូលរួមដែលមិនធ្លាប់បានដឹងពីការអប់រំបំណិនជីវិត (n=២១៦) ........ 37
រូបភាព ៤.៣៖ ភាគរយអ្នកដែលទទួលបានឯកសារសេចក្តីណែនាំ (n=222) ........ 38
រូបភាព ៤.៤៖ ភាគរយអ្នកមិនបានទទួលឯកសារសេចក្តីណែនាំ ឬឯកសារពាក់ព័ន្ធ ........ 38
រូបភាព ៤.៥៖ ភាគរយអ្នកដែលមិនបានទទួលការណែនាំទាក់ទងនឹងការអនុវត្ត ........ 38
រូបភាព ៤.៦៖ ភាគរយអ្នកដែលបានអនុវត្តការអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិនៅកម្ពុជា ........ 39
រូបភាព ៤.៧៖ ភាគរយបង្ហាញភាពញឹកញាប់ដែលនាយកឬនាយិកា គ្រូ និងសិស្សដែលបានអនុវត្តមុខវិជ្ជាកសិកម្ម ........ 43
រូបភាព ៤.៨៖ ភាគរយបង្ហាញភាពញឹកញាប់ដែលនាយកឬនាយិកា គ្រូ និងសិស្សដែលបានអនុវត្តមុខវិជ្ជារោងជាង ........ 43
រូបភាព ៤.៩៖ ភាគរយបង្ហាញភាពញឹកញាប់ដែលនាយកឬនាយិកា គ្រូ និងសិស្សដែលបានអនុវត្តមុខវិជ្ជា គេហវិទ្យា ........ 44
រូបភាព ៤.១០៖ ភាគរយបង្ហាញភាពញឹកញាប់ដែលនាយកឬនាយិកា គ្រូ និងសិស្សដែលបានអនុវត្តមុខវិជ្ជាសិល្បៈ ........ 45
រូបភាព ៤.១១៖ ភាគរយបង្ហាញភាពញឹកញាប់ដែលនាយកឬនាយិកា គ្រូ និងសិស្សដែលបានអនុវត្តមុខវិជ្ជា កុំព្យូទ័រ ........ 45
រូបភាព ៤.១២៖ ភាគរយបង្ហាញពីវិធីសាស្ត្របង្រៀន (n=134) ........ 46
រូបភាព ៤.១៣៖ ភាគរយបង្ហាញការបង្រៀនការអប់រំបំណិនជីវិត (បំណិនអាជីពងាយៗ) ........ 46
រូបភាព ៤.១៤៖ ភាគរយបង្ហាញគ្រូអប់រំបំណិនជីវិតដែលមាន ........ 47
រូបភាព ៤.១៥៖ ភាគរយបង្ហាញការរៀបចំគ្រូបង្រៀនបំណិនជីវិត (ករណីកង្វះគ្រូ) ........ 48
រូបភាព ៤.១៦៖ ភាគរយបង្ហាញការរៀបចំគ្រូ (ករណីមានគ្រូមិនគ្រប់គ្រាន់) ........ 49

រូបភាព ៤.១៧៖ ភាគរយបង្ហាញពីការពិនិត្យតាមដាន និងវាយតម្លៃធ្វើឡើងដោយថ្នាក់មន្ទីរ.អយក ថ្នាក់ការិយាល័យ.អយក និងនាយកឬនាយិកាសាលា ........ 50
រូបភាព ៤.១៨៖ ភាគរយបង្ហាញវិធីសាស្រ្តក្នុងការពិនិត្យតាមដាន និងវាយតម្លៃ ........ 51
រូបភាព ៤.១៩៖ ភាគរយបង្ហាញវិធីសាស្រ្តពិនិត្យតាមដាន និងវាយតម្លៃដែលបានប្រើសម្រាប់គ្រូ ........ 52
រូបភាព ៤.២០៖ ភាគរយបង្ហាញវិធីសាស្រ្តពិនិត្យតាមដាន និងវាយតម្លៃដែលបានប្រើសម្រាប់សិស្ស ........ 53
រូបភាព ៤.២១៖ ភាគរយនៃការយល់ឃើញចំពោះការរៀនការអប់រំបំណិនជីវិតតាមមូលដ្ឋាន ........ 54
រូបភាព ៤.២២៖ ភាគរយនៃការអនុវត្តការអប់រំបំណិនជីវិតឆ្លើយតបនឹងសេចក្តីណែនាំរបស់ក្រសួង អយក ........ 55
រូបភាព ៤.២៣៖ ភាគរយនៃការអនុវត្តការអប់រំបំណិនជីវិតឆ្លើយតបនឹងតម្រូវការមូលដ្ឋាន ........ 55
រូបភាព ៤.២៤៖ ភាគរយនៃការសហការគាំទ្ររវាង ថ្នាក់មន្ទីរ.អយក និងអ្នកពាក់ព័ន្ធ ........ 57
រូបភាព ៤.២៥៖ ភាគរយការសហការគាំទ្ររវាង ថ្នាក់ការិយាល័យ.អយក និងអ្នកពាក់ព័ន្ធ ........ 58
រូបភាព ៤.២៦៖ ភាគរយការសហការគាំទ្ររវាង នាយកឬនាយិកាសាលា និងអ្នកពាក់ព័ន្ធ ........ 59
រូបភាព ៤.២៧៖ ភាគរយការសហការគាំទ្ររវាង គណៈកម្មការទ្រទ្រង់សាលា និងអ្នកពាក់ព័ន្ធ ........ 60
រូបភាព ៤.២៨៖ ភាគរយការសហការគាំទ្ររវាង គ្រូ និងអ្នកពាក់ព័ន្ធ ........ 61
រូបភាព ៤.២៩៖ ភាគរយការសហការគាំទ្ររវាង អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ ........ 62
រូបភាព ៤.៣០៖ ភាគរយការសហការគាំទ្ររវាង អាណាព្យាបាល និងនាយកឬនាយិកាសាលា ........ 63
រូបភាព ៤.៣១៖ ភាគរយបង្ហាញការយល់ឃើញរបស់អ្នកចូលរួមចំពោះផលសម្រេចនៃការអប់រំបំណិនជីវិត ........ 65
រូបភាព ៤.៣២: មុខវិជ្ជាបំណិនជីវិតដែលជាតម្រូវការ (បំណិនអាជីពងាយៗ) នៅកម្រិតមធ្យមសិក្សាបឋមម ........ 66
រូបភាព ៤.៣៣៖ ភាគរយបង្ហាញមុខវិជ្ជាបំណិនជីវិតដែលជាតម្រូវការ (បំណិនអាជីពងាយៗ) ដោយអ្នកចូលរួមផ្សេងៗ ........ 67

រូបភាព ៤.៣៤៖ ភាគរយបង្ហាញអ្នកចូលរួមអន្តរាគមន៍របស់ ថ្នាក់មន្ទីរ.អយក...................... 69
រូបភាព ៤.៣៥៖ ភាគរយបង្ហាញអ្នកចូលរួមអន្តរាគមន៍របស់ ថ្នាក់ការិយាល័យ.អយក .......... 70
រូបភាព ៤.៣៦៖ ភាគរយបង្ហាញអ្នកចូលរួមអន្តរាគមន៍របស់ នាយកឬនាយិកាសាលា.......... 71
រូបភាព ៤.៣៧៖ ភាគរយបង្ហាញអ្នកចូលរួមអន្តរាគមន៍របស់ គ្រូ ....................................... 72
រូបភាព ៤.៣៨៖ ភាគរយបង្ហាញអ្នកចូលរួមអន្តរាគមន៍របស់ គណៈកម្មការទ្រទ្រង់សាលា .... 73
រូបភាព ៤.៣០៖ ភាគរយបង្ហាញអ្នកចូលរួមអន្តរាគមន៍របស់ អាជ្ញាធរមូលដ្ឋាន..................... 74
រូបភាព ៤.៤០៖ ភាគរយបង្ហាញអ្នកចូលរួមអន្តរាគមន៍របស់ អាណាព្យាបាលសិស្ស ............. 74

## តារាង

តារាង ៣.១:សមាមាត្រនៃអ្នកចូលរួមសម្រាប់កម្រងសំណួរសាកល្បង............................... 23
តារាង ៣.២: ការបង្ហាញស្ថិតិនៃកម្រិតជឿជាក់ ............................................................. 26
តារាង ៤.១: ការបង្ហាញភាគរយនៃសារវតាអ្នកចូលរួម...................................................... 31
តារាង ៤.២៖ ភាគរយសង្ខេបនាយកឬនាយិកាសាលា និងគ្រូដែលបានអនុវត្តការអប់រំ
បំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិ ......................................................... 41
តារាង ៤.៣៖ ភាគរយសិស្សដែលបានរៀនបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិ....... 42

# ជំពូកទី ១: សេចក្ដីផ្ដើម

## ១.១ ទិដ្ឋភាពទូទៅនៃការអប់រំបំណិនជីវិត

ដើម្បីបំពេញតម្រូវការសង្គម ការអប់រំគឺជាឧបករណ៍យ៉ាងសំខាន់ក្នុងការជំរុញភាពរីកចម្រើនខាងសេដ្ឋកិច្ច និងភាពសុខដុមរមនាក្នុងប្រទេស។ ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ការវិនិយោគទៅលើមូលធនមនុស្សផ្ដោតការយកចិត្តយ៉ាងខ្លាំង ពោលគឺធ្វើយ៉ាងណាឱ្យយុវជនមានសមត្ថភាព និងជំនាញច្បាស់លាស់តាមរយៈកិច្ចខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ មានលក្ខណៈជាប្រព័ន្ធ និងប្រកបដោយនិរន្តភាព ដើម្បីឱ្យដំណើរការការងារប្រព្រឹត្តទៅបានរលូន។ ជំនាញទាំងនោះរួមមានជំនាញក្នុងការគិត ជំនាញបច្ចេកទេស និងជំនាញទំនាក់ទំនងជាមួយមនុស្សដែលជាថ្នាលចម្លងធ្វើឱ្យជីវិតរស់នៅប្រសើរឡើង និងបង្កើនផលិតភាពការងារ។

ស្របពេលជាមួយគ្នានេះ រដ្ឋាភិបាលកម្ពុជាមានមហិច្ឆិតាប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ក្នុងន័យនេះ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ដែលបានកំណត់យ៉ាងច្បាស់នូវរបៀបវារៈគោលនយោបាយសង្គមសេដ្ឋកិច្ចរយៈពេល ៥ឆ្នាំខាងមុខ នឹងត្រួសត្រាយផ្លូវសម្រាប់ការប្ដេជ្ញាចិត្តនោះ និងការធ្វើដំណើរឆ្ពោះទៅមុខតាមរយៈការដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ៤ និងវិស័យអាទិភាព៤។ បញ្ហាមួយក្នុងចំណោមនោះទាក់ទងនឹងការអភិវឌ្ឍធនធានមនុស្សឱ្យស្របនឹងបដិវត្តឧស្សាហកម្ម ៤.០។ ដើម្បីជាការឆ្លើយតប កម្ពុជាត្រូវការធនធានមនុស្សដែលមានសមត្ថភាពនិងផលិតភាពការងារដើម្បីធានានិរន្តភាពនៃការប្រកួតប្រជែងរបស់ប្រទេសខ្លួន[1]។ ហេតុដូច្នេះការអប់រំបំណិនជីវិតចាត់ទុកថាជាផ្នែកសំខាន់មួយដើម្បីរៀបចំយុវជន និងមនុស្សពេញវ័យឱ្យចេះដោះស្រាយ និងរៀនសម្របខ្លួនជាមួយនឹងបញ្ហាដែលជួបប្រទះនិងហានិភ័យនានាប្រចាំថ្ងៃ និងជួយឱ្យមានការចូលរួមប្រកបដោយផលិតភាពខ្ពស់នៅក្នុងសង្គម។ ការរៀនបំណិនជីវិតមានប្រយោជន៍យ៉ាងខ្លាំងក្នុងការលើកកម្ពស់សុខភាព សុខុមាលភាព និងការងាររបស់បុគ្គលម្នាក់ៗនាពេលអនាគត។ ការអប់រំបំណិនជីវិតពិតជាជាបានរួមចំណែកសំខាន់ជាពិសេសសម្រាប់យុវជន ជាវ័យមួយដែលត្រូវការការអភិវឌ្ឍខ្លាំងខាងផ្នែកបញ្ញា រាងកាយ សង្គម ផ្លូវចិត្ត និងសមត្ថភាព។ យ៉ាងណាមិញ សមត្ថភាពរបស់យុវជន ហាក់ដូចជានៅមានកម្រិតនៅឡើយ។

1 រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤, ២០១៨

ទាក់ទងទៅនឹងគុណភាពនៃការបង្រៀន និងរៀនសូត្រ និងបង្កើនជំនាញ ក្រសួងអប់រំ យុវជន និងកីឡាសហការជាមួយដៃគូអភិវឌ្ឍន៍បានខិតខំប្រឹងប្រែងក្នុងការកែប្រែកម្មវិធីសិក្សាជាតិ និងព្យាយាមបញ្ចូលបំណិនជីវិតដែលជាអាទិភាពទៅក្នុងកម្មវិធីសិក្សារបស់ខ្លួន។ គោលនយោបាយសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សាចំណោះទូទៅ ២០០៥-២០០៩ ត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ការកែប្រែកម្មវិធីសិក្សាចាស់ក្នុងឆ្នាំ១៩៩៦ ដើម្បីឆ្លើយតបនឹងនិន្នាការក្នុងតំបន់ដោយផ្ដល់ឱ្យសិស្សនូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ព្រោះបំណិនជីវិតត្រូវបានគូសបញ្ជាក់ និងស្នើឱ្យបញ្ចូលក្នុងកម្មវិធីសិក្សាតាមរយៈការធ្វើសមាហរណកម្មក្នុងមុខវិជ្ជានីមួយៗនៃការរៀនសូត្រសម្រាប់បំណិនជីវិតទូទៅ និងការធ្វើពិពិធកម្មសម្រាប់បំណិនបុរេវិជ្ជាជីវៈក្នុងគោលបំណងលើកកម្ពស់សក្ដានុពល និងផលិតភាពរបស់អ្នកសិក្សា និងដើម្បីបំពេញបន្ថែមកម្មវិធីសិក្សាជាតិ (ក្រសួង.អយក, ២០០៤)។ ទន្ទឹមនឹងការបង្កើតគោលនយោបាយនេះផងដែរ ក្រសួងអប់រំ យុវជន និងកីឡាក៏បានអភិវឌ្ឍ និងដាក់ចេញនូវគោលនយោបាយបំណិនជីវិតក្នុងឆ្នាំ២០០៦ គោលបំណងឱ្យសិស្សទាំងអស់ទទួលបាននូវវិជ្ជាសម្បទា បំណិនសម្បទា ចរិយា សម្បទាអាកប្បកិរិយា និងសមត្ថភាពប្រកបដោយគុណភាព និងសមធម៌ដើម្បីឆ្លើយតបទៅនឹងតម្រូវការសង្គម។ គោលនយោបាយអប់រំបំណិនជីវិតបានពណ៌នាយ៉ាងលម្អិត និងចែកចេញជាពីរប្រភេទធំៗគឺ៖ ១) បំណិនមូលដ្ឋាន (បំណិនជីវិតទូទៅ និងបំណិនបុរេវិជ្ជាជីវៈ) និង ២) បំណិនអាជីព (បំណិនអាជីពងាយៗ និងបំណិនវិជ្ជាជីវៈ) (ក្រសួង.អយក, ២០០៦)។ បំណិនជីវិតមូលដ្ឋានចាំបាច់ណាស់ដែលគួរសិស្សទាំងអស់គ្នាត្រូវមាន ដើម្បីជួយឱ្យពួកគេឱ្យមានគ្រឹះរឹងមាំដើម្បីធ្វើការងារបានល្អប្រសើរ សម្រាប់ដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេក៏ដូចជាធ្វើឱ្យកាន់តែមានឯករាជ្យដែលវាមាន ប្រយោជន៍ក្នុងការគ្រប់គ្រងសុខភាពរាងកាយ និងផ្លូវចិត្តឱ្យបានល្អនៅពេលបន្តការសិក្សាទៅមហាវិទ្យាល័យ។ បំណិនទាំងនោះត្រូវបានណែនាំឱ្យបញ្ជ្រាបទៅក្នុងមុខវិជ្ជាគោលចំនួនបួន រួមមានភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម។ ដោយឡែក បំណិនអាជីព គឺជាបំណិនដែលកំណត់ និងធានានូវការត្រៀមខ្លួនសម្រាប់ការងារនាពេលអនាគតរបស់សិស្ស។ បំណិននោះចែកចេញជា ពីរប្រភេទរួមមាន៖ (១)បំណិនអាជីពងាយៗ ឬបំណិនជីវិតតាមមូលដ្ឋាន (សម្រាប់ថ្នាក់មធ្យមសិក្សាបឋមភូមិ) មានលក្ខណៈបន្ថែមលើសពីចំណោះដឹងបច្ចេកទេស ដែលតម្រូវឱ្យមានការបណ្តុះបណ្តាលរយៈពេលខ្លី និងបច្ចេកទេសងាយៗដើម្បីឆ្លើយតបនឹងតម្រូវការមូលដ្ឋាន និងចំណាប់អារម្មណ៍របស់បុគ្គលម្នាក់ៗ(២)បំណិនវិជ្ជាជីវៈសំដៅលើបំណិនដែលផ្ដល់ឱ្យសិស្សនូវការបណ្តុះបណ្តាលជាមូលដ្ឋាន ឬការបណ្តុះបណ្តាលជំនួសឱ្យកម្រិតមហាវិទ្យាល័យ ហើយចំណាយពេលតិចជាងកម្មវិធីសិក្សា

នៅមហាវិទ្យាល័យរយៈពេល៤ឆ្នាំ។ ពាក់ព័ន្ធទៅនឹងចំណុចនេះដែរក្រសួងអប់រំ យុវជន និងកីឡា (២០០៣) បានប្ដេជ្ញាបង្រៀនបំណិនបច្ចេកទេសដែលស្របនឹងទីផ្សារការងារដល់សិស្សមធ្យមសិក្សា ដោយបានដាក់ចេញនូវគោលនយោបាយអប់រំបច្ចេកទេសអមជាមួយនឹងសេចក្ដីណែនាំ លេខ ៣៩ (២០១៣)[2] និងលេខ ៣៦ (២០១៤)[3]។ ការអប់រំបច្ចេកទេស មានបញ្ចូលការបណ្ដុះ-បណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងនោះរួមមាន៖ (១) កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន (ឧ- កសិកម្ម សិល្បៈ គេហវិទ្យា រោងជាង កុំព្យូទ័រ -ល-) (២) ការតម្រង់ទិសវិជ្ជាជីវៈ និង (៣) ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាពនៅតាមសាលានានា ក្រសួងអប់រំ យុវជន និងកីឡាបានប្រកាសសេចក្ដីណែនាំលេខ ៣២ (២០១៥)[4] សម្រាប់បុគ្គលសំខាន់ៗដើម្បីកំណត់ប្រធានបទសម្រាប់ការបង្រៀន រយៈពេលនៃការបង្រៀន និងការវាយតម្លៃ។ សេចក្ដីណែនាំលេខ ១២ (២០១៦)[5] ត្រូវបានចេញផ្សាយផងដែរ ដើម្បីធានាថាការអនុវត្តការអប់រំបំណិនជីវិតនៅតាមសាលារៀន ជាពិសេសមុខវិជ្ជារោងជាងបានរៀបចំកន្លែង និងសម្ភារៈសមស្របសម្រាប់ការបង្រៀននិងរៀនបំណិនជីវិត និងបានធ្វើការពិនិត្យនិងវាយតម្លៃជាទៀងទាត់លើការអនុវត្ត។ ទន្ទឹមនឹងការអនុវត្តដែលបានលើកឡើងខាងលើ ក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈសហការជាមួយដៃគូអភិវឌ្ឍន៍បានបង្កើតក្របខ័ណ្ឌកម្មវិធីសិក្សាអប់រំបំណិនជីវិត (២០១៦) ដែលជាផែនទីដើម្បីអភិវឌ្ឍកម្មវិធីសិក្សា រៀបចំសៀវភៅសិក្សាគោល និងកសាងសមត្ថភាពដល់មន្ត្រីអប់រំពាក់ព័ន្ធទាំងអស់។ ជាមួយគ្នានឹងក្របខ័ណ្ឌនេះ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ បានបង្កើតសៀវភៅណែនាំសម្រាប់បំណិនអាជីព (២០១៧) ក្នុងគោលបំណងជួយដល់នាយកឬនាយិកាសាលា និងគ្រូដើម្បីអនុវត្តបំណិនជីវិតតាមមូលដ្ឋាននៅតាមអនុវិទ្យាល័យ។ នៅឆ្នាំ២០១៨ កម្មវិធីសិក្សាថ្មីស្ដីពីការអប់រំបំណិនជីវិតសម្រាប់អនុវិទ្យាល័យ និងសេចក្ដីណែនាំសម្រាប់គ្រូស្ដីពីការអនុវត្តការអប់រំបំណិនជីវិតទើបតែបានបង្កើតឡើង ប៉ុន្តែមិនទាន់បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅតាមសាលារៀននៅឡើយទេ។

## ១.២ បញ្ហានៃការស្រាវជ្រាវ

ការបន្តកិច្ចខិតខំប្រឹងប្រែងលើកំណែទម្រង់ការអប់រំទាំងមូលគឺ ដើម្បីធានាឱ្យសិស្សទាំងអស់ទទួលបាននូវបំណិនជីវិតដែលជាតម្រូវការឱ្យឆ្លើយតបទៅនឹងសង្គមបច្ចុប្បន្ន ធានាការ

2 សេចក្ដីណែនាំលេខ ៣៩ ស្ដីពីការគ្រប់គ្រងការងារអប់រំបច្ចេកទេសនៅថ្នាក់រាជធានី ខេត្ត (២០១៣)
3 សេចក្ដីណែនាំលេខ ៣៩ ស្ដីពីការគ្រប់គ្រងការងារអប់រំបច្ចេកទេសនៅថ្នាក់រាជធានី ខេត្ត (២០១៤)
4 សេចក្ដីណែនាំលេខ ៣២ ស្ដីពីការអប់រំបំណិនជីវិត និងកម្មវិធីអប់រំជម្រើស (២០១៥)
5 សេចក្ដីណែនាំលេខ ១២ ស្ដីពីការបង្កើតរោងជាងនៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ (២០១៦)

ចូលរួមជាមួយសហគមន៍របស់ពួកគេ និងផ្តល់ការបណ្តុះបណ្តាលបំណិនជីវិតរបស់ពួកគេដើម្បីជំនះរាល់ការលំបាកនៅក្នុងជីវិត។ ជាមូលដ្ឋានយុវជនជាច្រើនត្រូវបានគេលើកឡើងថាមិនទាន់មានជំនាញគ្រប់គ្រាន់ស្របនឹងទីផ្សារការងារដូច្នេះទាំងសហាកគមន៍សកលនិងក្នុងតំបន់ប្តេជ្ញាលើកកម្ពស់ជំនាញឱ្យឆ្លើយតបដើម្បីជំរុញឱ្យមានការចូលរួមយ៉ាងសកម្មនៅក្នុងសង្គមជាពិសេសពីថ្នាក់ក្រោម ដូចដែលបានអះអាងនៅក្នុងរបាយការណ៍ស្តីពីការអប់រំសម្រាប់ទាំងអស់ គ្នា គោលដៅទី៣ ដែលបានលើកឡើងថា "ជំនាញសម្រាប់យុវជន និងមនុស្សពេញវ័យៈ ធានាថាតំរូវការនៃការរៀនសូត្ររបស់យុវជន និងមនុស្សពេញវ័យទាំងអស់ត្រូវបានបំពេញតាមរយៈការចូលរួមក្នុងកម្មវិធីរៀនសូត្រ និងកម្មវិធីបំណិនជីវិតប្រកបដោយសមធម៌"[6]។ ដូច្នេះតើការអប់រំបំណិនបំណិនជីវិតត្រូវបានអនុវត្តយ៉ាងដូចម្តេចនៅតាមសាលារៀននានាក្នុងប្រទេសកម្ពុជា? តើបំណិនទាំងនោះត្រូវបានពិនិត្យតាមដាននិងមានការគាំទ្រយ៉ាងដូចម្តេច? ចម្ងល់ទាំងនេះនៅតែជាបញ្ហាចាក់ឫសនៅឡើយ។ ទោះបីជាយ៉ាងណាក៏ដោយក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយដៃគូអភិវឌ្ឍន៍ជាច្រើនបានធ្វើសកម្មភាពផ្សេងៗគ្នាដែលជាមូលដ្ឋានគ្រឹះដើម្បីធ្វើឱ្យការអនុវត្តការអប់រំបំណិនជីវិតឆ្លើយតបទៅនឹងតម្រូវការសង្គម ដោយកំណត់ឡើងវិញនូវតួនាទី និងការទទួលខុសត្រូវរបស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈដែលជានាយកដ្ឋាននាំមុខ ដើម្បីគ្រប់គ្រងការអនុវត្ត។ ជាពិសេស កិច្ចសហប្រតិបត្តិការបានដាក់ចេញនូវសសរស្តម្ភសំខាន់ៗ និងសមិទ្ធិផលគួរឱ្យកត់សម្គាល់ជាមួយនឹងការអភិវឌ្ឍគោលនយោបាយបំណិនជីវិតក្នុងឆ្នាំ២០០៦ ការអភិវឌ្ឍកម្មវិធីសិក្សា ២០០៥-២០០៩ សេចក្តីណែនាំសម្រាប់ការអនុវត្តបំណិនជីវិត និងម៉ូឌុលបំណិនជីវិតតាមមូលដ្ឋានចំនួន ២០ មេរៀន។ ទោះជាយ៉ាងណាក៏ដោយការផ្សព្វផ្សាយ ការផ្គត់ផ្គង់ និងការអនុវត្តជាក់ស្តែងហាក់នៅមិនទាន់សម្រេចបានតាមដែលចង់បាន ហើយមកដល់ពេលនេះ ការអន្តរាគមន៍នានាក៏មិនទាន់បានធ្វើតាមការទាមទាររបស់ថ្នាក់ក្រោមនៅឡើយទេ។ យោងតាមរបាយការណ៍របស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ បានអោយដឹងថាការអនុវត្តនាពេលបច្ចុប្បន្ននេះហាក់ដូចជាមិនទាន់ដំណើរការ និងតម្រង់ទិសបានល្អនៅឡើយនោះទេ ដោយសារតែខ្វះការយកចិត្តទុកដាក់ឱ្យស៊ីជម្រៅលើបញ្ហាប្រឈមក្នុងការអនុវត្តការអប់រំបំណិនជីវិត[7]។ ថ្មីៗនេះមានការសិក្សាតិចតួចណាស់ដែលផ្តោតលើការងារនោះ ជាហេតុធ្វើឱ្យការយល់ដឹងអំពីបញ្ហាប្រឈមនានា ក្នុងការអនុវត្តបំណិនជីវិតប្រកបដោយជោគជ័យ ជាពិសេសបំណិនអាជីពងាយៗ ហាក់នៅមានភាពស្រពិចស្រពិល។ ស្របជាមួយគ្នានេះ អង្គការយូនីសេហ្វ (២០១២) បានលើកឡើងពីបញ្ហាប្រឈមជាច្រើនទាក់ទងនឹងការអនុវត្តបំណិនជីវិត

6 ការអប់រំសម្រាប់ទាំងអស់គ្នា ២០០០-២០១៥: សមិទ្ធផល និងបញ្ហាប្រឈម
7 របាយការណ៍សង្ខេបស្តីពីស្ថានភាពការអប់រំបំណិនជីវិត ២០១៣-២០១៨, នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ

ប្រកបដោយប្រសិទ្ធភាពនៅកម្ពុជាបណ្តាលមកពីកង្វះខាតនៃម៉ូឌុលបង្រៀន សម្ភារៈ ថវិកា អ្នកជំនាញបច្ចេកទេសនិងគ្រូជំនាញ និងកម្សោយការយល់ដឹងអំពីក្របខ័ណ្ឌគោលនយោបាយ និងការអភិវឌ្ឍសមត្ថភាពស្តីពីការអប់រំបំណិនជីវិតសម្រាប់ថ្នាក់ក្រោម។ នាយកដ្ឋាននាំមុខបានថ្លែងស្រដៀងគ្នានេះដែរ ទាក់ទងនឹងឧបសគ្គនៃការអនុវត្តការអប់រំបំណិនជីវិតនៅកម្រិតសាលារួមជាមួយនឹងកង្វះការពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំ។ វឌ្ឍនភាពនៃការអប់រំជីវិតក៏ដូចជាស្ថានភាពនៃការយល់ដឹងអំពីបំណិនជីវិតនៅប្រទេសកម្ពុជាហាក់មានសភាពទ្រឹង គឺជាការបង្ហាញភាពពិតជាក់ស្តែងមួយសម្រាប់អ្នកអនុវត្តដែលពាក់ព័ន្ធ។ ដែលសំខាន់គឺថា មានការបង្ហាញតិចតួចណាស់ដែលបានជីករកបញ្ហាពីថ្នាក់ក្រោម ហើយកំណត់បញ្ហាសំខាន់ៗជាច្រើនដែលជះឥទ្ធិពលដល់ការអនុវត្ត។ ទាក់ទងនឹងផ្នែកកម្មវិធីសិក្សា ការបង្រៀននិងការរៀនផ្តោតលើសំខាន់ចំណុចគោលធំៗ ចំនួន ៣ គឺ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ម៉្យាងវិញទៀត ការសិក្សាភាគច្រើននាពេលថ្មីៗនេះហាក់មើលរំលងបំណិនជីវិតតាមមូលដ្ឋានដែលជាមូលដ្ឋានសម្រាប់អ្នកសិក្សាដែលមានបំណងចង់សិក្សាជំនាញវិជ្ជាជីវៈ និងបច្ចេកទេសនៅថ្នាក់ឧត្តមសិក្សា(ដូចបានលើកឡើងខាងលើ) ដោយការសិក្សាទាំងនោះហាក់មានទំនោរខ្លាំងទៅលើតែការលើកកម្ពស់បំណិនទន់។ ដោយមិនមានការវិភាគបញ្ហាលក្ខណៈស៊ីជម្រៅនោះហើយ ទើបធ្វើឱ្យការប្តេជ្ញាក្នុងការពង្រឹង និងលើកកម្ពស់ការអនុវត្តការអប់រំបំណិនជីវិត ជាពិសេសបំណិនអាជីពងាយៗមិនអាចដំណើរការបានរលូន។

## ១.៣ សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផលដែលបានពីការសិក្សានេះនឹងក្លាយជាភស្តុតាង និងបណ្ណាល័យសាស្ត្រដ៏ច្បាស់លាស់មួយសម្រាប់ភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីឈ្វេងយល់ពីឧបសគ្គនៃអនុវត្ត និងបញ្ហាប្រឈមសំខាន់ៗនានា ដូចជា កង្វះសម្ភារៈបរិក្ខារសិក្សា កម្សោយក្នុងការគ្រប់គ្រងនិងការដឹកនាំរបស់នាយកសាលា កង្វះការចូលរួមពីសហគមន៍ និងកង្វះថវិកាដើម្បីទ្រទ្រង់កម្មវិធីបណ្តុះបណ្តាលបំណិនជីវិត។ ចំណុចដែលគួរឱ្យកត់សម្គាល់ លទ្ធផលបឋមពីការស្រាវជ្រាវ អាចក្លាយជាការសិក្សាមូលដ្ឋានដែលមានទំនាក់ទំនងរឹងមាំជាមួយកម្មវិធីសិក្សាលម្អិតថ្មីស្តីពីបំណិនជីវិតរៀបចំដោយនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា ដើម្បីធានាថាការកែលម្អថ្មីឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាននិងសង្គម និងផ្តល់យោបល់កម្រិតគោលនយោបាយដើម្បីរៀបចំយន្តការណាមួយលើកកម្ពស់ការអប់រំបំណិនជីវិត។ លើសពីនេះ លទ្ធផលពីការសិក្សានេះក៏នឹងផ្តល់នូវបទអន្តរាគមន៍ជាយុទ្ធសាស្ត្រដើម្បីពង្រីក និងធ្វើមូលដ្ឋានីយកម្មកម្មវិធីឱ្យកាន់តែ

មានប្រសិទ្ធិភាពផងដែរ។ ជាពិសេស ព័ត៌មានសំខាន់ៗជាច្រើនទៀតដែលបានពីការស្រាវជ្រាវនឹងជួយពង្រីកចំណេះដឹងអ្នកអនុវត្តផ្ទាល់ ទាក់ទងនឹងបំណិនជីវិតក៏ដូចជាលទ្ធផលរបស់វា។ បន្ទាប់មក ដំណោះស្រាយល្អៗដែលបានពីការសិក្សានេះនឹងជួយជំរុញការពង្រឹងការអនុវត្តការអប់រំបំណិនជីវិតនៅតាមសាលារៀនឱ្យដំណើរការទៅប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ១.៤ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងរួមនៃការសិក្សានេះ គឺដើម្បីបង្ហាញពីស្ថានភាពបច្ចុប្បន្ននៃការអនុវត្តការអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិនៅប្រទេសកម្ពុជា។ ក្នុងនោះ គោលបំណងជាក់លាក់ មានដូចខាងក្រោម៖

១) រកឱ្យឃើញពីបញ្ហាប្រឈមនៃការអនុវត្តការអប់រំបំណិនជីវិត

២) កំណត់តម្រូវការមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន

៣) កំណត់បទអន្តរាគមន៍ជាយុទ្ធសាស្ត្រ ដើម្បីឱ្យការអនុវត្តការអប់រំបំណិនជីវិត នៅកម្រិតមធ្យមសិក្សាបឋមភូមិមានប្រសិទ្ធភាព

## ១.៥ សំណួរស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ជាការសិក្សាបែបរុករកដើម្បីជាពន្លឺក្នុងការពង្រឹងគុណភាពនៃការអនុវត្តកម្មវិធីអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិនៅប្រទេសកម្ពុជា។ ដើម្បីកំណត់ពីដើមចមនៃបញ្ហាប្រឈមកំពុងកើតមានឡើង និងបទអន្តរាគមន៍នៃបញ្ហាជាក់លាក់ អ្នកស្រាវជ្រាវបានស្នើសំណួរស្រាវជ្រាវសំខាន់ៗចំនួនបី ដូចខាងក្រោម៖

១) តើការអនុវត្តការអប់រំបំណិនជីវិត នៅកម្រិតមធ្យមសិក្សាបឋមភូមិ មានស្ថានភាពដូចម្តេច?

២) តើមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋានអ្វីខ្លះដែលជាតម្រូវចាំបាច់?

៣) តើត្រូវកំណត់បទអន្តរាគមន៍ ជាយុទ្ធសាស្ត្រដូចម្តេច ដើម្បីឱ្យការអនុវត្តការអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិមានប្រសិទ្ធភាព?

## ១.៦ ក្របខ័ណ្ឌនៃទស្សនាទាន

ផ្អែកតាមការសិក្សាស្រាវជ្រាវជាច្រើនស្តីពីការអប់រំបំណិនជីវិត អ្នកពាក់ព័ន្ធទាំងក្នុងនិងក្រៅវិស័យនេះផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការសម្រិតសម្រាំងមនុស្សឱ្យមានជំនាញ

ពិតប្រាកដ និងផុសខាត់ចរិយាសម្បទាដើម្បីឱ្យពួកគេមានទំនាក់ទំនងល្អជាមួយអ្នកដទៃតាំងពីឆ្នាំ១៩៩០ មកម្ល៉េះ។ ការសិក្សាបែបវិទ្យាសាស្ត្រជាច្រើន បានគូសបញ្ជាក់ចំណុចជាច្រើនទាក់ទងនឹងវិសាលភាពនៃការអនុវត្តការអប់រំបំណិនជីវិត វិធីសាស្ត្រដែលបានអនុវត្ត តម្រូវការ និងបញ្ហាប្រឈមក្នុងបរិបទផ្សេងៗគ្នា ការវាស់វែងប្រសិទ្ធភាពនៃការអនុវត្ត ពិសេសកត្តាដែលរារាំងដល់ការអនុវត្ត។

ជាក់ស្តែង ការវិភាគការអនុវត្តការអប់រំបំណិនជីវិតដែលលើកឡើងដោយអង្គការសុខភាពពិភពលោកបានចង្អុលបង្ហាញថាមានជំនាញស្នូលមួយប្រភេទ ដែលជាមូលដ្ឋានក្នុងការលើកកម្ពស់បំណិនផ្អែកលើសុខភាព និងសុខុមាលភាពកុមារនិងក្មេងជំទង់រួមមាន ការសម្រេចចិត្តដោះស្រាយបញ្ហា គំនិតច្នៃប្រឌិត ការត្រិះរិះពិចារណា ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ជំនាញទំនាក់ទំនងអន្តរបុគ្គល ការស្គាល់ខ្លួនឯង ការអាណិតអាសូរ ការគ្រប់គ្រងអារម្មណ៍ និងភាពតានតឹង (អង្គការសុខភាពពិភពលោក, ២០០៥)។ ស្រដៀងគ្នានេះដែរ ការតាមដានការអនុវត្តការអប់រំបំណិនជីវិតក្នុងបរិបទផ្សេងៗគ្នា ផ្តោតចម្បងលើបំណិនទន់ ការថែទាំសុខភាព និងបញ្ហាសង្គម (យូនីសេហ្វ, ២០១១)។

ការសិក្សាស្រាវជ្រាវភាគច្រើនបានប្រើវិធីសាស្ត្រចម្រុះ ដើម្បីបង្ហាញពីលទ្ធផលនៃការសិក្សារបស់ពួកគេ តួយ៉ាងដូចជា ការស្ទង់មតិបែបពណ៌នា បទសម្ភាសន៍ និងការពិភាក្សាក្រុម (Okech & Role, ២០១៦; Paola, Lane, & Bredenberg, ២០១២)។ បញ្ហាប្រឈម និងកត្តាជាច្រើន ដែលជះឥទ្ធិពលដល់ការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងមិនមានប្រសិទ្ធភាព ផ្តោតសំខាន់លើការគាំទ្រប្រតិបត្តិកម្មវិធីនៅកម្រិតសាលា។ ការសិក្សាទាំងនោះបានប្រើវិធីសាស្ត្របែបគុណវិស័យ ដូចជាការសម្ភាសដែលដកស្រង់ចេញពីទិន្នន័យស្ទង់មតិ ព័ត៌មានលម្អិតនៅក្នុងបណ្ណាល័យសាស្ត្រ (Marieta M., ២០១៤)។

ការអប់រំបំណិនជីវិត ត្រូវបានគេកំណត់និងយកចិត្តទុកដាក់ខ្ពស់ដូចដែលបានបង្ហាញពិស្តារនៅក្នុងបណ្ណាល័យសាស្ត្រ។ ជាសញ្ញាណដូចគ្នា ការសិក្សាភាគច្រើនហាក់ដូចជានៅប្រើវិធីសាស្ត្រប្រហាក់ប្រហែលក្នុងការឈ្វេងយល់ការអប់រំបំណិនជីវិត ដោយមើលទិដ្ឋភាពបំណិនមូលដ្ឋានដូចៗគ្នា។ទោះជាយ៉ាងនេះក្តីក្របខ័ណ្ឌទស្សនទាននៃការសិក្សានេះមានគោលបំណងដើម្បីបង្ហាញនូវព័ត៌មានពាក់ព័ន្ធជាក់លាក់នៃការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន។ អ្នកនិពន្ធជាច្រើន បានខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីបង្ហាញនិយមន័យ បញ្ហាប្រឈម និងសកម្មភាពក្នុងបរិបទផ្សេងៗគ្នា តាមរយៈការប្រមូលព័ត៌មានសំខាន់ៗជាច្រើនពីការសិក្សានានាកន្លងមក

ទាក់ទងនឹងការអប់រំបំណិនជីវិត។ ក្រុមការងារស្រាវជ្រាវបានកំណត់គំនិតជាក់លាក់ឱ្យស្រប នឹងបរិបទ ដែលបានពីទិដ្ឋភាពផ្សេងៗជាច្រើន ដើម្បីបង្កើតក្របខ័ណ្ឌទស្សនទានដូចបង្ហាញនៅក្នុងដ្យាក្រាមដូចខាងក្រោម៖




*រូបភាព ១.១: ក្របខ័ណ្ឌទស្សនាទានសម្រាប់ការពិនិត្យតាមដាន និងពង្រឹងការអនុវត្តការអប់រំបំណិនជីវិត*

## ១.៧ និយមន័យពាក្យគន្លឹះ

ដើម្បីយល់ពីគោលគំនិតសំខាន់ៗនៃការសិក្សាបច្ចុប្បន្ន ទាក់ទងនឹងការអនុវត្តការអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិនៅប្រទេសកម្ពុជា "បំណិនជីវិត" គឺជាពាក្យគន្លឹះសំខាន់មួយដែលទាមទារឱ្យមានការបកស្រាយឱ្យបានច្បាស់លាស់ និងស្របតាមបរិបទ។

យោងតាម The Dakar Framework "បំណិនជីវិត" មិនសំដៅត្រឹមតែមានសមត្ថភាពបង្កើត ឬបន្ថែមគុណតម្លៃដល់ផលិតផលសេដ្ឋកិច្ច (ក្នុងន័យសេដ្ឋកិច្ចហៅថា "មូលធនមនុស្ស") ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានបំណិនដើម្បីបំពេញតម្រូវការជីវិតរបស់បុគ្គលម្នាក់ៗឱ្យមានផាសុកភាព និងការចូលរួមពេញលេញនៅក្នុងសង្គម, (យូណេស្កូ, ២០១៥, ទំព័រ ១១)។ ផ្អែកតាមទស្សនៈខាងសុខភាពផ្លូវចិត្តរបស់អង្គការសុខភាពពិភពលោកបានកំណត់ថា "បំណិនជីវិត" គឺជាសមត្ថភាពក្នុងការសម្របខ្លួន និងឥរិយាបថវិជ្ជមានដែលអាចឱ្យបុគ្គលម្នាក់ៗចេះដោះស្រាយតម្រូវការ និងបញ្ហាប្រឈមក្នុងជីវិតប្រចាំថ្ងៃបានយ៉ាងមានប្រសិទ្ធិភាព" (អង្គការសុខភាពពិភពលោក, ២០០៥)។ គួរបញ្ជាក់ដែរថា អង្គការយូនីសេហ្វ (២០១២) បានអះអាងអំពីនិយមន័យនៃបំណិនជីវិតដោយផ្អែកលើការស្រាវជ្រាវបែបវិទ្យាសាស្ត្រថា "បំណិនជីវិត" សំដៅទៅលើបណ្តុំចិត្តសង្គម និងជំនាញអន្តរបុគ្គលដែលអាចជួយមនុស្សក្នុងការធ្វើការសម្រេចចិត្ត ប្រាស្រ័យទាក់ទងគ្នាប្រកបដោយប្រសិទ្ធភាព និងអភិវឌ្ឍបំណិនក្នុងការដោះស្រាយបញ្ហា និងការគ្រប់គ្រងខ្លួនឯងដែលអាចជួយឱ្យជីវិតប្រសើរឡើង មានសុខភាពល្អ និងផលិតភាពការងារខ្ពស់។ បន្ថែមលើនេះទៀត របាយការណ៍របស់អង្គការ គំនិតផ្តួចផ្តើមរបស់ក្មេងស្រីវ័យជំទង់ (Adolescent Girls Iniative) (២០១៣) កំណត់ថា "បំណិនជីវិត គឺជាសំណុំនៃជំនាញសង្គមនិងចរិយាសម្បទានិយាយឱ្យចំគឺ បំណិនទន់ ដែលអាចឱ្យបុគ្គលម្នាក់ៗចេះដោះស្រាយតម្រូវការក្នុងជីវិតយ៉ាងមានប្រសិទ្ធិភាព"។ ពាក់ព័ន្ធនឹងច្បាប់ស្តីពីការអប់រំ (២០០៧) "បំណិនជីវិត" សំដៅដល់ចំណេះដឹងដែលផ្តោតលើសុខភាព ការបង្ការទប់ស្កាត់ អាហារូបត្ថម្ភ ការយល់ដឹងពីកិច្ចការពលរដ្ឋ និងបរិស្ថាន ជំនាញសង្គម និងជំនាញក្នុងប្រាស្រ័យទាក់ទងគ្នារបស់អ្នកសិក្សា។ ស្រដៀងគ្នានេះដែរ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានកំណត់និយមន័យ "បំណិនជីវិត" ថាជាបំណិនបញ្ញា បុគ្គលិកលក្ខណៈអន្តរបុគ្គល និងវិជ្ជាជីវៈ ដែលអាចជួយដល់ការធ្វើការសម្រេចចិត្ត ការទំនាក់ទនងប្រកបដោយប្រសិទ្ធភាព ព្រមទាំងអាចដោះស្រាយនិងគ្រប់គ្រងខ្លួនឯងបាន (ក្រសួង.អយក, ២០០៦)។

ដោយយោងតាមនិយមន័យ បំណិនជីវិត ដែលបានគូសបញ្ជាក់ខាងលើ បំណិនជីវិតរួមបញ្ចូលនូវបំណិនមូលដ្ឋាន បំណិនទន់ និងបំណិនវិជ្ជាជីវៈដើម្បីធានាថានូវរាល់តម្រូវការ

របស់យុវជន និងមនុស្សពេញវ័យ និងបំណិនជីវិតសំខាន់ៗត្រូវបានបំពេញ ខណៈដែលវាមានភាពប្រហាក់ប្រហែលគ្នានឹងការបណ្តុះបណ្តាលការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដែលក៏ជាផ្នែកមួយរួមចំណែក ការសម្រេចបាននូវការអបរំសម្រាប់ទាំងអស់គ្នាគោលទី ៣ និង ៦។ និយាយពីព្រំដែននៃការសិក្សានេះ គឺនៅកម្រិតមធ្យមសិក្សាបឋមភូមិដែលទាំងបំណិនមូលដ្ឋាន និងអាជីពត្រូវបានដាក់បញ្ចូល។ អាស្រ័យហេតុនេះ ក្រុមការងារស្រាវជ្រាវបានសម្រេចប្រើនិយមន័យមួយផ្នែកដែលបានមកពីគោលនយោបាយរបស់ក្រសួង និងកម្មវិធីសិក្សាលម្អិតសម្រាប់ការអនុវត្តបំណិនជីវិត តាមមូលដ្ឋាននៅកម្រិតមធ្យមសិក្សាបឋមភូមិតាមរយៈការបង្រួមវិសាលភាពនៃការសិក្សាដោយផ្តោះផ្តោតការយកចិត្តទុកដាក់ខ្លាំងទៅលើបំណិនអាជីពងាយៗ ឬបំណិនជីវិតតាមមូលដ្ឋាន ដូចដែលបានបញ្ជាក់ក្នុង១.១។

## ១.៨ វិសាលភាពនៃការសិក្សា

ការសិក្សាស្រាវជ្រាវនេះផ្តោតជាចម្បងលើ" បំណិនជីវិត" ដែលត្រូវបានអនុវត្តនៅកម្រិតមធ្យមសិក្សាមបឋមភូមិនៅប្រទេសកម្ពុជា ខណៈដែលមានហេតុផលជាច្រើននៅពីក្រោយការសម្រេចចិត្តនេះ។ ជាក់ស្តែង ការអនុវត្តការអប់រំបំណិនជីវិតត្រូវបានគេលើកឡើងថាមិនទាន់មានប្រសិទ្ធភាព និងមិនឆ្លើយតបនៅឡើយជាពិសេសនៅអនុវិទ្យាល័យ។ ទោះបីជាយ៉ាងណាក៏ដោយ សាលារៀនជាច្រើនបានរាយការណ៍ថា បានទទួលឯកសារច្បាប់ជាច្រើនដែលបានបោះពុម្ព និងធនធានដែលពាក់ព័ន្ធបានគាំទ្រដល់ការអនុវត្តការអប់រំបំណិនជីវិត ការគ្រប់គ្រងសាលារៀនទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធនិងមូលធនមនុស្សនៅតែជាបន្ទុក ខណៈពេលដែលសាលាទាំងនោះ កំពុងប្រឈមនឹងបុគ្គលិកជំនាញ និងការផ្គត់ផ្គង់មិនទាន់បំពេញតម្រូវការ។ ដូច្នេះការសិក្សានេះមិនមានគោលបំណងវាយតម្លៃការអនុវត្តការអប់រំបំណិនជីវិតនោះទេ ប៉ុន្តែដើម្បីរកឱ្យឃើញនូវឧបសគ្គដែលរារាំងការរីកចម្រើននៃការអនុវត្តបំណិនជីវិត កំណត់បំណិនជីវិតតាមមូលដ្ឋានដែលជាតម្រូវការ និងស្នើបទអន្តរាគមន៍ជាយុទ្ធសាស្ត្រជំរុញការអនុវត្ត រាប់ចាប់ពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត រហូតដល់កម្រិតសាលា (អនុវិទ្យាល័យ) និងសហគមន៍។ គួរកត់សម្គាល់ថា ការសិក្សានាពេលបច្ចុប្បន្ននេះមាននិន្នាការទៅពិនិត្យពិច័យសាលារៀនដែលមានការគាំទ្រពីខាងក្រៅលើការអនុវត្តបំណិនជីវិត ធៀបនឹងសាលារៀនដែលពុំបានទទួលការគាំទ្រពីខាងក្រៅ។

## ១.៩ រចនាសម្ព័ន្ធនៃរបាយការណ៍ស្រាវជ្រាវ

ការសិក្សានាពេលនេះបានគូសបញ្ជាក់ជាទម្រង់នៃរបាយការណ៍ស្រាវជ្រាវដែលមាន ៥ ជំពូកផ្សេងគ្នា។ ជំពូកទី១ បានចាប់ផ្តើមដោយ "សេចក្តីផ្តើម" ដែលបង្ហាញពីព័ត៌មានសំខាន់ៗ ដើម្បីស្វែងយល់អំពីសារៈតា និងបញ្ហានៃការអនុវត្តការអប់រំបំណិនជីវិតនៅក្នុងបរិបទកម្ពុជា។ ជាមួយគ្នានេះ សំណួរនិងគោលបំណងនៃការស្រាវជ្រាវក៏ត្រូវបានកំណត់ និងដាក់បញ្ចូលក្នុងផ្នែកនេះផងដែរ។ ការពង្រឹងការអប់រំបំណិនជីវិតពិតជាចាំបាច់បំផុត ក្នុងការជួយជំរុញភាពមានការងារធ្វើឱ្យបានទូលំទូលាយទៅក្នុងសង្គម។ បន្តពីជំពូកទី១ ជំពូកទី២ "បណ្ណាល័យសាស្ត្រ" ផ្តោតជាពិសេសទៅលើបញ្ហាប្រឈម និងបទពិសោធន៍ជោគជ័យនៃការអនុវត្តបំណិនជីវិតនៅតាមបណ្តាប្រទេសនានា។ លើសពីនេះទៅទៀត ជំពូកនេះបានគិតអំពីប្រធានបទនៃបំណិនជីវិតថ្មីៗ និងអាចអនុវត្តបាននៅក្នុងបរិបទផ្សេងៗគ្នា។ ផ្នែកក៏បានពិនិត្យបន្ថែមទៀតនូវវិធីសាស្ត្រ និងគម្លាតសូចនាករនៃការវិភាគនៅក្នុងបរិបទផ្សេងៗគ្នា។ ជំពូកទី៣ "វិធីសាស្ត្រស្រាវជ្រាវ" បានផ្តល់ការបញ្ជាក់លម្អិតអំពីរបៀបនៃការបង្កើតទិន្នន័យ និងវិធីសាស្ត្រវិភាគ។ ផ្នែកនេះបានបង្ហាញពីសុពលភាពនិងភាពជឿជាក់នៃការសិក្សាទាំងមូល។បន្ទាប់មកទៀត លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា បានសំយោគលទ្ធផលសំខាន់ៗនៃការសិក្សា ដែលបានបញ្ជាក់ពីស្ថានភាពនៃការអនុវត្តការអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិនៅប្រទេសកម្ពុជា ដោយមានហេតុផលគាំទ្រតាមរយៈលទ្ធផលស្ថិតិ។ ចុងបញ្ចប់ ជំពូកចុងក្រោយបានបង្ហាញពីទស្សនៈរបស់ក្រុមអ្នកស្រាវជ្រាវដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវ និងដែនកំណត់នៃការសិក្សា។ លើសពីនេះទៀត ផ្នែកនេះបានបង្ហាញពីឱកាស និងទិដ្ឋភាពសម្រាប់ការវិភាគបន្ត។ ឯកសារយោង និងឯកសារបន្ថែមនានា ត្រូវបានបញ្ចូលជាផ្នែកបន្ថែមសម្រាប់ប្រភពស្រាវជ្រាវបន្តនៃការងារស្រាវជ្រាវ។

## ជំពូកទី ២៖ បណ្ណាល័យសាស្ត្រ

"បំណិនជីវិត គឺជាផ្នែកមួយនៃសមត្ថភាពសម្រាប់ជីវិត និងការងារនៅក្នុងបរិបទសង្គមវប្បធម៌និងបរិស្ថានជាក់លាក់។ ប្រភេទនៃបំណិនជីវិតលេចឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់បុគ្គលម្នាក់ៗនៅក្នុងស្ថានភាពជីវិតពិត។" Petra Javrh and Estera Mozina, 2018.

ការសិក្សារបស់ Petra Javrh និង Estera Mozina ស្តីពីបំណិនជីវិតរបស់គម្រោងអឺរ៉ុបនៅឆ្នាំ២០១៨ មានគោលបំណងបង្ហាញការយល់ដឹងទូទៅនៃបំណិនជីវិត និងលើកកម្ពស់វិធីសាស្ត្រក្នុងការអនុវត្តតាមរយៈឧត្តមានុវត្តន៍នានាពីបណ្តាប្រទេសដៃគូទាំង៥នៅអឺរ៉ុប។ ព័ត៌មានទាំងនោះអាចជាសារតាគាំទ្រដ៏រឹងមាំមួយ និងពង្រីកគំនិតទាក់ទងនឹងបំណិនជីវិតសម្រាប់ទស្សនទាន ដើម្បីជាប្រយោជន៍ដល់ការអនុវត្តជាក់ស្តែងបន្ថែមទៀត។ ដើម្បីកំណត់បានយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីលើកកម្ពស់ការអប់រំបំណិនជីវិត វាចាំបាច់ត្រូវបន្លិចបញ្ហាប្រឈមនិងតម្រូវការដែលបានពីការពិនិត្យឡើងវិញ នូវដើមចមនៃការអនុវត្តការអប់រំបំណិនជីវិត ដើម្បីឈ្វេងយល់ឱ្យបានច្បាស់លាស់ នូវស្ថានភាពនៃការអនុវត្តនាពេលបច្ចុប្បន្ន។ នៅចុងបញ្ចប់នៃជំពូកនេះ សេចក្តីសន្និដ្ឋានបណ្ណាល័យសាស្ត្រ បានបង្ហាញពីគម្លាតនៃការសិក្សា ដែលបានពីការសិក្សាស្រាវជ្រាវ និងរបាយការណ៍ពីមុនៗ និងបានសំយោគលក្ខណៈសំខាន់ៗនៃការអនុវត្តការអប់រំបំណិនជីវិតជាមូលដ្ឋាន។

### ២.១ ការអនុវត្តការអប់រំបំណិនជីវិតក្នុងបរិបទសកលលោក

ការសិក្សាបានបង្ហាញថាការអភិវឌ្ឍបំណិនជីវិតបានជួយពង្រឹងសុខុមាលភាពទូទៅ និងជាមូលដ្ឋានគ្រឹះដើម្បីជោគជ័យនៅក្នុងជីវិត។ ការអប់រំបំណិនជីវិតមានគោលបំណងជាក់លាក់ដើម្បីបណ្តុះបុគ្គលម្នាក់ៗឱ្យមានឥរិយាបថចេះបត់បែន និងមានជំនាញចិត្តសង្គម។ ដោយមើលឃើញដូច្នេះ ការអប់រំបំណិនជីវិត ត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សានៅកម្រិតបឋមសិក្សានិងមធ្យមសិក្សា នៅ១៥៥ប្រទេសទាំងបរិបទប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍន៍ និងមានប្រទេសប្រមាណជា ៧០បានរៀបចំជាមុខវិជ្ជាកាតព្វកិច្ច (យូនីសេហ្វ ២០១២)។ ការសិក្សាបានបង្ហាញពីភាពខុសគ្នាៗនៃការអនុវត្តការអប់រំបំណិនជីវិតនៅតាមសាលារៀន ខណៈដែលនៅក្នុងបរិបទប្រទេសអភិវឌ្ឍន៍ការអប់រំបំណិនជីវិតផ្តោតសំខាន់លើបំណិនទន់ ដោយឡែកបរិបទប្រទេសកំពុងអភិវឌ្ឍន៍ការអប់រំបំណិនជីវិតផ្តោតទៅលើបំណិនពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ ការថែទាំសុខភាព យេនឌ័រ និងបញ្ហាសង្គម។ គេនិយាយថាបរិបទទាំងពីរមានគោលបំណងលើកស្ទួយសិស្សឱ្យចេះប្រែក្លាយចំណេះដឹង ឥរិយាបថ និងគុណតម្លៃទៅជាសមត្ថភាព

អនុវត្តជាក់ស្តែង ដែលអាចឱ្យសិស្សមានអាកប្បកិរិយាសមរម្យ និងប្រកបដោយផលិតភាព (Prajapati, Sharma, & Sharma, ២០១៧ និង WHO, ២០០៥ ដែលត្រូវបានដកស្រង់ខ្លឹមសារពី Nasheeda,Abdullah, Krauss, & Ahmed, ២០១៨)។ យូនីសេហ្វ (២០១២) ក៏បានបន្ថែមទៀតថា ការអប់រំបំណិនជីវិតមានសារៈសំខាន់ និងមានឥទ្ធិពលមិនត្រឹមតែចំពោះមនុស្សពេញវ័យនោះទេ តែចាប់តាំងពី

មត្តេយ្យមកម្ល៉េះ។ ហេតុដូច្នេះ ការអប់រំបំណិនជីវិតត្រូវបានបញ្ជ្រាបតាំងពីការថែទាំ និងការអប់រំថ្នាក់ដំបូងមកម្ល៉េះដើម្បីអភិវឌ្ឍបំណិនជីវិត និងឥរិយាបថដែលទទួលបានពីមជ្ឈដ្ឋានគ្រួសារ និងសហគមន៍។ កន្លងមក អង្គការសុខភាពពិភពលោក (២០០៥) បានបំផុសបំណិនជីវិតសំខាន់ៗចំនួន១០រួមមាន (១) ការសម្រេចចិត្ត (២) ការដោះស្រាយបញ្ហា (៣) គំនិតច្នៃប្រឌិត (៤) ការត្រិះរិះពិចារណា (៥) ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព (៦) ទំនាក់ទំនងអន្តរបុគ្គល (៧) ការស្គាល់ខ្លួនឯង (៨) ការអាណិតអាសូរ (៩) ការគ្រប់គ្រងអារម្មណ៍ និង(១០) ការគ្រប់គ្រងភាពតានតឹង។ ការចាប់ផ្តើមការអនុវត្តការអប់រំបំណិនជីវិតនៅតែជាបញ្ហា ហេតុដូច្នេះ អ្នកស្រាវជ្រាវជាច្រើនបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីស្រាយនូវបញ្ហាដែលកើតមានឡើងនោះ។

យោងតាមរបាយការណ៍ដោយយូនីសេហ្វ (២០១២) បានបង្ហាញពីករណីសិក្សាស្តីពីប្រវត្តិសង្ខេបនៃកម្មវិធីអប់រំបំណិនជីវិតនៅបណ្តាប្រទេសនានា។ នៅប្រទេស អាមេននៀ ការអប់រំបំណិនជីវិតបានអនុវត្តចាប់តាំងពីថ្នាក់ទី១ ដល់ទី៧ ដោយមានបញ្ចូលនូវប្រធានបទស្តីពីបំណិនទន់ និងបញ្ហាសង្គមនានា។ កន្លងមក ការអនុវត្តមានការប្រឈមនឹងបញ្ហាជាច្រើនទាក់ទងនឹងប្រសិទ្ធភាព និងគុណភាពដោយសារតែកម្មវិធីទាមទារឱ្យមានការបន្តជួយគាំទ្រ និងឧបត្ថម្ភពីបណ្តាដៃគូអភិវឌ្ឍជាក់ស្តែងដូចជាអង្គការយូនិសេហ្វ។ នៅប្រទេសបាបាដុស ការអប់រំបំណិនជីវិត ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀន ដោយប្រើក្របខណ្ឌកម្មវិធីសិក្សាសម្រាប់ការអប់រំសុខភាព និងជីវិតគ្រួសារដែលរួមមានប្រធានបទធំគឺ (ក) ទំនាក់ទំនងបុគ្គល និងអន្តរបុគ្គល (ខ) សុខភាពផ្លូវភេទ និងបន្តពូជ (គ) សុខភាពចំណីអាហារ និងរាងកាយ និង(ឃ) ការគ្រប់គ្រងបរិស្ថាន។ ការអប់រំបំណិនជីវិតនៅប្រទេសនោះមានគោលបំណងរួមចំណែកក្នុងការអភិវឌ្ឍក្នុងតំបន់ ការកំណត់អត្តសញ្ញាណ និងកិច្ចសហប្រតិបត្តិការ ការរៀបចំយុវជនឱ្យក្លាយជាពលរដ្ឋខារីប៊ីនប្រកបដោយឧត្តមភាព។ នៅប្រទេសជរខ្ជែន ជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញនៅលើផ្លូវដឹកនាំលទ្ធិប្រជាធិបតេយ្យ បានចាប់អនុវត្តការអប់រំបំណិនជីវិតដោយផ្តោតសំខាន់លើបំណិនមូលដ្ឋានរួមជាមួយ

នឹងការអប់រំក្រៅប្រព័ន្ធ និងកម្មវិធីសិក្សាបន្ថែមតាំងពីឆ្នាំ១៩៩៩។ ការគាំទ្រពីដៃគូអភិវឌ្ឍន៍កំពុងបន្ត រហូតដល់ការអប់រំបំណិនជីវិតអាចមានលទ្ធភាពរួមបញ្ចូលក្នុងប្រព័ន្ធអប់រំផ្លូវការ និយាយរួមគឺការអប់រំមូលដ្ឋាន (ថ្នាក់ទី ១-១០) ដែលរួមមានអប់រំកាយ និងការអប់រំបំណិនបុរេវិជ្ជាជីវៈ។ ក្នុងនោះផងដែរ ប្រធានបទគឺផ្តោតលើការថែទាំសុខភាព បញ្ហាសង្គម និងការអភិវឌ្ឍសង្គម (ព័ត៌មានវិទ្យា និងសេដ្ឋកិច្ច)។ ដោយសារតែនៅប្រទេសកេនយ៉ាមានការលេចឡើងធ្ងន់ធ្ងរនូវបញ្ហាសុខភាពកាលពីឆ្នាំ១៩៩៩ ទើបការអប់រំសុខភាពត្រូវបានស្នើឱ្យដាក់បញ្ចូលក្នុងកម្មវិធីសិក្សាលម្អិត។ មុខវិជ្ជានេះត្រូវបានបញ្ជ្រាបចូលក្នុងសា លាបឋមសិក្សានិងមធ្យមសិក្សាដើម្បីរួមចំណែកជួយដោះស្រាយនូវបញ្ហាទាំងនោះ។ នៅឆ្នាំ២០០៨ ការអប់រំបំណិនជីវិតនៅប្រទេសកេនយ៉ា បានអនុវត្តជាប្រធានបទដាច់ដោយឡែកមួយម៉ោងមួយសប្តាហ៍ ដោយមានកម្មវិធីលម្អិតជាក់លាក់ ដែលត្រូវគ្នាជាមួយអង្គការសុខភាពពិភពលោក ទាក់ទងនឹងបំណិនបុគ្គលបំណិនអន្តរបុគ្គល និងការអប់រំពីសន្តិភាព។ ដោយឡែក ការអប់រំសុខភាពបន្តពូជត្រូវបានដាក់បញ្ចូលក្នុងមុខវិជ្ជាមួយចំនួនដូចជាវិទ្យាសាស្ត្រ សិក្សាសង្គម និងការអប់រំទាក់ទងនឹងសាសនា។ ដើម្បីពង្រឹងអាកប្បកិរិយា និងឥរិយាបថរបស់សិស្ស វិទ្យាស្ថានអប់រំ ក្រសួងអប់រំ និងដៃគូពាក់ព័ន្ធនានានៅប្រទេសម៉ាឡាវី បានធ្វើការកំណែទម្រង់កម្មវិធីសិក្សា និងដាក់មុខវិជ្ជាបំណិនជីវិតជាមុខវិជ្ជាកាតព្វកិច្ចនៅកម្រិតបឋមសិក្សាអំឡុងឆ្នាំ២០០៦-២០០៧។ នៅឆ្នាំ២០១០ ការអប់រំបំណិនជីវិតក៏ត្រូវបានដាក់ជាមុខវិជ្ជាកាតព្វកិច្ចនៅកម្រិតមធ្យមសិក្សា និងជាមុខវិជ្ជាបន្ទាប់បន្សំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ ដើម្បីធានាការអនុវត្តការអប់រំបំណិនជីវិតនៅតាមសាលារៀនអង្គការយូនីសេហ្វបានជួយរ៉ាប់រងនូវធនធាននិងការគ្រប់គ្រង។ស្រដៀងគ្នានេះដែរប្រទេសម៉ូហ្សាមប៊ីកដែលជាប្រទេសដែលមានចំណូលសេដ្ឋកិច្ចទាប ក៏បានបញ្ចូលកម្មវិធីអប់រំបំណិនជីវិតនេះផងដែរដោយផ្តោតលើការអប់រំអំពីបញ្ហាសុខភាពស្តីពីវីរុសហ៊ីវ និងមេរោគអេដស៍ទៅក្នុងកម្មវិធីសិក្សាថ្នាក់ទី៥រួមមានក្នុងមុខវិជ្ជាសីលធម៌និងពលរដ្ឋវិទ្យា និងវិទ្យាសាស្ត្រធម្មជាតិ។ ដោយឡែក នៅកម្រិតមធ្យមសិក្សាបឋមភូមិ ការអប់រំបែបនេះ មិនត្រូវបានគេបង្កើតឡើងលក្ខណៈស៊ីជម្រៅឡើយ ពោលគឺបញ្ហាទាំងនោះត្រូវបានគេបង្កើតឡើងក្នុងគោលបំណងគ្រាន់តែជាការផ្តល់ការប្រឹក្សាដល់មនុស្សពេញវ័យ និងការពិភាក្សាគ្នាទៅវិញទៅមកទាក់ទងនឹងសេវាសុខភាព។ មិនខុសពីបរិបទការអប់រំដទៃទៀត បញ្ហាសមត្ថភាពនិងគុណភាពនៅតែស្ថិតក្នុងការព្រួយបារម្ភនៅឡើយ។ ការអនុវត្តការអប់រំបំណិនជីវិតនៅប្រទេសមីយ៉ាន់ម៉ាត្រូវបានផ្តួចផ្តើមឡើងតាំងពីឆ្នាំ១៩៩៣ ទាក់ទងនឹងសុខភាពសាធារណៈ។ នៅឆ្នាំ២០១០ ក្រសួងអប់រំនៃប្រទេសមីយ៉ាន់ម៉ា សហការជាមួយដៃគូអភិវឌ្ឍន៍បញ្ចូលកម្មវិធីដោយផ្តល់នូវក្របខ័ណ្ឌអនុវត្ត

រួមជាមួយនឹងការបណ្តុះបណ្តាលនិងការណែនាំ។ កម្មវិធីអប់រំបំណិនជីវិតចំនួន ៣ ត្រូវបានអនុវត្តរួមមាន (១) ការណែនាំអំពីការអប់រំបំណិនជីវិតទៅក្នុងកម្មវិធីសិក្សាបឋមសិក្សាតាមរយៈការធ្វើសមាហរណកម្មទៅក្នុងមុខវិជ្ជាសិក្សាសង្គម (២) កម្មវិធីសិក្សាបំណិនជីវិតមធ្យមថ្នាក់ជាតិ តាមរយៈមុខវិជ្ជាសហាកម្មវិធីសិក្សាថ្នាក់ជាតិ និង (៣)ការពង្រីកការអប់រំនិងរៀនសូត្របន្តគោលដៅសម្រាប់កុមារនៅក្រៅសាលា។ ដោយអនុលោមទៅតាមសារតានៃការសិក្សានៅក្នុងស្ថានភាពផ្សេងៗខាងលើ មានការសិក្សាជាច្រើនស្តីពីការអនុវត្តការអប់រំបំណិនជីវិតដោយកំណត់គោលបំណងផ្សេងៗគ្នា។ ក្រៅពីការបង្ហាញការកកើតឡើងនៃការអប់រំបំណិនជីវិតនៅក្នុងបរិបទផ្សេងៗកន្លងមក Abobo (២០១២) បានរកឃើញថាការអនុវត្តការអប់រំបំណិនជីវិតដំណើរការមិនរលូន ដោយកត្តាបរិយាកាសសាលារៀន និងកត្តាមួយចំនួនទៀតដែលធ្វើបង្កការរាំងស្ទះដល់គ្រូ ក្នុងការបង្រៀនកម្មវិធីបំណិនជីវិតនៅអនុវិទ្យាល័យប្រកបដោយប្រសិទ្ធភាព។ បញ្ហាប្រឈមសំខាន់ៗត្រូវបានគេអះអាងជាអាទិ៍ កង្វះការបណ្តុះបណ្តាលសម្រាប់គ្រូបង្រៀនបំណិនជីវិតជាហេតុធ្វើឱ្យគ្រូមានឥរិយាបថអវិជ្ជមានចំពោះការបង្រៀនមុខវិជ្ជានេះ ការផ្គត់ផ្គង់ធនធានបង្រៀននិងរៀនមិនទាន់បានគ្រប់គ្រាន់នៅឡើយ ឯវិធីសាស្ត្រក្នុងការបង្រៀនមុខវិជ្ជាបំណិនជីវិតក៏មិនទាន់បានអនុវត្តសមស្របនៅឡើយ។ ការសិក្សានោះក៏បានផ្តោតការយកចិត្តទុកដាក់លើការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រូផងដែរ។ Adhiambo (២០១៣)បានពិនិត្យតាមដានការអនុវត្តការអប់រំបំណិនជីវិតនៅក្នុងស្រុកចំនួន២នៅប្រទេសកេនយ៉ា និងបានរកឃើញនូវបញ្ហាប្រឈមមួយចំនួន។ បញ្ហាប្រឈមបន្ថែមបានលេចឡើង ពោលគឺសាលារៀនភាគច្រើន មិនទាន់មានកម្មវិធីសិក្សាលម្អិតស្តីពីការអប់រំបំណិនជីវិតសម្រាប់បង្រៀននៅឡើយ ហើយកង្វះគ្រូដែលមានគុណវុឌ្ឍិ និងកង្វះពេលវេលានៅតែជាបញ្ហាចោទដែលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្ត កង្វះការពិនិត្យតាមដាន និងវាយតម្លៃដំណាក់កាលនៃការអនុវត្តកម្មវិធី។ លើសពីនេះទៀត Marieta.M (២០១៤) បានកំណត់នូវបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងការអនុវត្តការអប់រំបំណិនជីវិតនៅបរិបទប្រទេសក្វេល ហើយបញ្ហាទាំងនោះហាក់មិនសូវជាខុសគ្នាប៉ុន្មាននឹងបណ្តាប្រទេសដទៃក៏ដូចជាប្រទេសកម្ពុជា។ លទ្ធផលនៃការសិក្សាបានបង្ហាញថា កង្វះគ្រូបង្រៀនបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការអនុវត្តដោយសារតែគ្រូម្នាក់មានបន្ទុកការងារច្រើន។ បញ្ហាទាំងនោះហាក់ធ្វើឱ្យគ្រូមានឥរិយាបថអវិជ្ជមានចំពោះការអនុវត្តការអប់រំបំណិនជីវិត។ វឌ្ឍនភាព និងស្ថានភាពការអនុវត្តការអប់រំបំណិនជីវិតហាក់នៅមានភាពស្រពិចស្រពិលនៅឡើយ។ការបែងចែកពេលវេលាបង្រៀនបំណិនជីវិតមិនទាន់គ្រប់គ្រាន់ឯការផ្គត់ផ្គង់សម្ភារៈសម្រាប់បង្រៀននិងរៀនក៏ដូចគ្នា។ មិនមានការគាំទ្រណាមួយលើការបណ្តុះ

បណ្តាលគ្រូបង្រៀនបំណិនជីវិតអំឡុងពេលមុននិងក្រោយការអនុវត្ត។ ការងារទាំងនោះត្រូវការការយកចិត្តទុកដាក់ និងសកម្មភាពច្បាស់លាស់ដើម្បីធ្វើឱ្យការអនុវត្តកាន់តែប្រសើរឡើង។

ស្រដៀងគ្នានេះដែរលោក Wairimu (២០១៥) បានពិនិត្យភាពខុសគ្នាសំខាន់ៗនៃភេទនិងគុណវុឌ្ឍិគ្រូបង្រៀនលើការអនុវត្តការអប់រំបំណិនជីវិត និងស្វែងរកបញ្ហាប្រឈមរបស់គ្រូក្នុងពេលអនុវត្ត។ ការសិក្សាបានបង្ហាញថាមានការលំបាកក្នុងការអនុវត្តមាតិកានៃការអប់រំបំណិនជីវិតជាក់លាក់ដែលសក្តិសមសម្រាប់ទាំងក្មេងប្រុសនិងក្មេងស្រី។ ការសិក្សាក៏ត្រូវបានរកឃើញផងដែរនូវភាពខុសគ្នាដ៏សំខាន់រវាងគ្រូមានសមត្ថភាពខ្ពស់និងគ្រូទាប។ បញ្ហាប្រឈមបន្ថែមមួយចំនួនទៀត ដែលត្រូវបានគេផ្តោតការយកចិត្តទុកដាក់ទៅលើការបណ្តុះបណ្តាលលើវិធីសាស្ត្របង្រៀនបំណិនជីវិត ការផ្តល់តម្លៃតិចតួចលើសារៈសំខាន់នៃការអប់រំបំណិនជីវិត និងឥរិយាបថអវិជ្ជមានរបស់សិស្សទៅលើកម្មវិធីនេះ ដោយមានទស្សនៈថា កម្មវិធីនេះ គឺជាបន្ទុកបន្ថែម។ ជាការឆ្លើយតបបន្ថែម Okech & Role (២០១៥) បានបង្ហាញពីការព្រួយបារម្ភទាក់ទងនឹងសមាសធាតុនៃកម្មវិធីសិក្សា សម្រាប់ការបង្រៀនច្រើន ហើយពិបាកក្នុងការវាស់វែងនូវលទ្ធផលចុងក្រោយដែលថាធ្វើឱ្យបានល្អនៅពេលប្រឡងថ្នាក់ជាតិ។

Chirwa & Naidoo (២០១៤) បានពិនិត្យបន្ថែមទៀតលើកត្តាដែលជះឥទ្ធិពលដល់ការបង្រៀនបំណិនជីវិត នៅក្នុងបរិបទកម្រិតបឋមសិក្សានៅប្រទេសម៉ាឡាវី។ លទ្ធផលបានបង្ហាញថាមានកត្តាសំខាន់មួយចំនួនដែលជះឥទ្ធិពលដល់ការអនុវត្តរួមមាន១)កត្តាគ្រូ ពោលគឺការយល់ដឹងពីការអនុវត្តកម្មវិធីអប់រំបំណិនជីវិតនៅមានកម្រិតទាប ភាពខ្សោយលើវិធីសាស្ត្រនៃការបង្រៀន បញ្ហាសុខភាពផ្ទាល់ខ្លួនរបស់គ្រូ ២) កត្តាសិស្ស ពោលគឺបញ្ហាការរាលដាលនៃមេរោគអេដស៍ ៣) កត្តាសាលារៀន ពោលគឺគ្រូនៅក្រុងមានភាពសកម្មក្នុងការបង្រៀន និងទទួលបានការគាំទ្រលើផ្នែកបង្រៀនជាច្រើនដូចជាវិធីសាស្ត្របង្រៀន គរុកោសល្យ កម្មវិធីសិក្សាមិនទាន់មានភាពឆ្លើយតបនឹងកម្រិតសិស្សបញ្ហាទីតាំងភូមិសាស្ត្រ និងការគាំទ្រលើផ្នែកធនធានសម្រាប់អនុវត្ត។

## ២.២ ការអនុវត្តការអប់រំបំណិនជីវិតនៅក្នុងបរិបទកម្ពុជា

ដូចដែលបានបញ្ជាក់ខាងលើ ការអប់រំបំណិនជីវិតត្រូវបានអនុវត្តក្នុងបរិបទកម្ពុជាប្រមាណជាជាង១០ឆ្នាំមកហើយ ដែលបំណិនទាំងនេះត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាបឋមសិក្សា និងបង្រៀននៅអនុវិទ្យាល័យជាកម្មវិធីជំបំណិនជីវិតតាមមូលដ្ឋាន ប៉ុន្តែនៅវិទ្យាល័យបំណិន

ទាំងនេះត្រូវបានបង្រៀនតាមទម្រង់បែបការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ដើម្បីសំរេចបានគោលដៅចុងក្រោយនៃការអនុវត្តកម្មវិធីបំណិនជីវិត ក្រសួងអប់រំ យុវជន និងកីឡាសហការជាមួយម្ចាស់ជំនួយនានាបានបង្កើតឯកសារច្បាប់ជាច្រើនសម្រាប់ជួយដល់អ្នកអនុវត្ត។ ក្រៅពីនេះ ក៏មានការសិក្សាមួយចំនួនបានបង្ហាញពីស្ថានភាពនៃការអនុវត្តការអប់រំបំណិនជីវិត។

Paola et al (២០១២) បានវិភាគស្ថានភាពនៃការអនុវត្តការអប់រំបំណិនជីវិតនៅកម្រិតអប់រំមូលដ្ឋាន(ថ្នាក់ទី ១ ដល់ទី ៩) និងបានរកឃើញបញ្ហាប្រឈមមួយចំនួនដែលរំខានដល់ការអនុវត្តប្រកបដោយជោគជ័យដែលត្រូវបានជូនដំណឹងដោយកម្រិតផ្សេងៗគ្នារួមមាន៖ ១) អង្គការក្រៅរដ្ឋាភិបាល ក្រសួង អយក និងសាលារៀន៖ កង្វះម៉ូឌុលសម្រាប់បង្រៀន និងការគាំទ្រផ្នែកសម្ភារៈ កង្វះថវិកា និងអ្នកជំនាញបច្ចេកទេស ២) ថ្នាក់ខេត្ត ស្រុក និងសាលារៀន៖ កង្វះការយល់ដឹងពីក្របខណ្ឌគោលនយោបាយ និងសារៈសំខាន់នៃការអប់រំបំណិនជីវិត។

យោងតាមរបាយការណ៍សង្ខេបរបស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈឆ្នាំ២០១៣-២០១៨ ការអប់រំបំណិនជីវិតបានអនុវត្តស្ទើរតែគ្រប់សាលារៀនប៉ុន្តែមិនបានអនុវត្តពេញលេញទេ ខណៈពេលដែលការអនុវត្តជាក់ស្តែងកំពុងប្រឈមនឹងបញ្ហាជាច្រើន តួយ៉ាងដូចជាកង្វះគ្រូឯកទេស (ឧ.គ្រូកសិកម្ម រោងជាង សិល្បៈ និងកុំព្យូទ័រ) សម្ភារបរិក្ខា សៀវភៅសិក្សា និងឯកសារជំនួយផ្សេងៗថវិកាគាំទ្រមានតិចតួច ការយល់ដឹងពីសារៈសំខាន់នៃការអប់រំបំណិនជីវិតនៅមានកម្រិតទាបពិសេសខាងសហគមន៍ ភាពជាអ្នកដឹកនាំ និងការចូលរួមរបស់នាយក-នាយិកាសាលានៅមានកម្រិត។ ដោយមើលឃើញដូច្នេះ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈបានលើកផែនការសកម្មភាពដើម្បីអន្តរាគម និងលើកកម្ពស់ការអនុវត្តការអប់រំបំណិនជីវិត។

ស្រដៀងនេះដែរ យូនីសេហ្វ(២០១២) បានខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការបង្កើតគោលការណ៍ (benchmarks) និងសូចនាករសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃបទដ្ឋាននៃការអនុវត្តការអប់រំបំណិនជីវិតទាក់ទងនឹងលទ្ធផល ការវាយតម្លៃ សកម្មភាព ការបង្រៀន និងបរិយាកាសសិក្សា។ ទោះយ៉ាងណាក៏ដោយ ក្នុងចំណោមបទដ្ឋានដែលបានរៀបរាប់ខាងលើ ការវាយតម្លៃការផ្លាស់ប្តូរអាកប្បកិរិយារបស់បុគ្គលម្នាក់ៗគឺមាន

លក្ខណៈបែបប្រធានវិស័យភាព (subjective)។ គោលការណ៍ណែនាំសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការអប់រំបំណិនជីវិតផ្តោតសំខាន់លើការអប់រសុខភាព។

សរុបសេចក្តីមក គេសង្កេតឃើញថា ការអនុវត្តការអប់រំបំណិនជីវិតនៅកម្ពុជាបានជួប

ប្រទះនូវបញ្ហាប្រឈមសំខាន់ៗមួយចំនួនដូចជាការណែនាំអនុវត្ត អ្នកជំនាញ គ្រឿងបរិក្ខារ ធនធានសម្ភារៈ ការសហការ ការគាំទ្រផ្នែកបច្ចេកទេស និងការប្តេជ្ញាចិត្តពីសាលារៀនទោះបីជាមានបទប្បញ្ញត្តិជាច្រើនត្រូវបានចេញផ្សាយដើម្បីជំរុញការអនុវត្តក៏ដោយ។

## ២.៣ សេចក្តីសន្និដ្ឋានបណ្ណាល័យសាស្ត្រ

យោងតាមការធ្វើបណ្ណាល័យសាស្ត្រស្តីពីការអប់រំបំណិនជីវិត ដូចដែលបានពណ៌នាខាងលើ សេចក្តីសន្និដ្ឋានមួយចំនួនត្រូវបានសន្មត់។ គួរកត់សម្គាល់ថាការអប់រំបំណិនជីវិតបានអនុវត្តក្នុងបរិបទផ្សេងៗជាច្រើន ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍រួមទាំងកម្ពុជាផង ក្នុងគោលបំណងធានានូវឱ្យបាននូវបំណិន និងតម្លៃជីវិតសម្រាប់ការរស់នៅប្រសើរជាងមុន។ បណ្ណាល័យសាស្ត្រខាងលើ ក៏បានបង្ហាញពីបញ្ហាប្រឈមសំខាន់ៗដែលអាចប្រៀបធៀបបាននៅក្នុងកម្រិតនៃការអប់រំខុសៗគ្នាដូចជាពីកម្រិតបឋមសិក្សារហូតដល់មធ្យមសិក្សា និងការអប់រំក្រៅប្រព័ន្ធជាដើម។ រីឯវិធីសាស្ត្រនៃការស្រាវជ្រាវ ក៏មិនទាន់មានលក្ខណៈបែបវិទ្យាសាស្ត្រ និងច្បាស់លាស់នៅឡើយ ពោលគឺមិនមានចូលរួមពីរាល់ភាគីពាក់ព័ន្ធ ហើយបញ្ហាប្រឈមគួរត្រូវបានរាយការណ៍តាមរយៈការសិក្សាស្រាវជ្រាវច្បាស់លាស់ណាមួយ។ លើសពីនេះទៅទៀត ការសិក្សាភាគច្រើនបានគូសបញ្ជាក់ពីបំណិនជីវិត ដែលទាក់ទងនឹងបំណិនទន់ជាពិសេសការអប់រំសុខភាព ជាជាងជំនាញវិជ្ជាជីវៈ។ វាជារឿងដែលមិនអាចបដិសេធបានដែលថារបាយការណ៍ស្រាវជ្រាវភាគច្រើនបានព្យាយាមផ្តោតតែលើបញ្ហានានា ដែលរារាំងដល់វឌ្ឍនភាពនៃការអនុវត្តការអប់រំបំណិនជីវិតខណៈដែលវាចាំបាច់ណាស់ ដើម្បីស្វែងរកជំនាញអ្វីកំពុងតែត្រូវការដើម្បីឆ្លើយតបទៅនឹងបរិបទរបស់ពួកគេ។ ទោះបីជាសំណូមពរនិងសកម្មភាពមួយចំនួនត្រូវបានគ្រោងនិងស្នើឡើងក៏ដោយ ប៉ុន្តែបញ្ហាប្រឈមក្នុងការអនុវត្តការអប់រំបំណិនជីវិត និងតម្រូវការជំនាញ ជាពិសេសបំណិនជីវិតតាមមូលដ្ឋានដែលបម្រើដល់សេចក្តីត្រូវការក្នុងមូលដ្ឋានរបស់ពួកគេ គួរតែត្រូវបានគេយកចិត្តទុកដាក់ខ្ពស់ ហើយអនុសាសន៍គួរតែលើកឡើងនូវចំណុចណាដែលអាចអនុវត្តបាន និងងាយយល់។

## ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះ ផ្តោតជាចម្បងលើស្ថានភាពនៃការអនុវត្តការអប់រំជំនាញជីវិត នាពេលបច្ចុប្បន្ននៅកម្រិតមធ្យមសិក្សាបឋមភូមិនៅកម្ពុជា និងមានគោលបំណងដើម្បីឈ្វេងយល់ពីបញ្ហាប្រឈមដែលកើតមានឡើង។ ដូច្នេះ ជំពូកទី៣ និយាយពីវិធីសាស្ត្រស្រាវជ្រាវនេះនឹងបង្ហាញលទ្ធផលនៃការសិក្សាដោយប្រើវិធីសាស្ត្រហ្មត់ចត់។ ការសិក្សានេះ ត្រូវបានធ្វើឡើងដោយប្រើវិធីសាស្ត្របែបបរិមាណវិស័យដោយមានការសម្ភាសបែបពាក់កណ្ដាល ផ្លូវការផងដែរ។ បន្ទាប់ពីនោះ ផ្នែកនេះក៏បានលើកឡើងយ៉ាងច្បាស់ពីរបៀបដែលអ្នកស្រាវជ្រាវធ្វើការវាស់វែងនៃគំនិតសំខាន់ៗនិងការប្រើប្រាស់ឧបករណ៍ស្រាវជ្រាវ។ លើសពីនេះទៀត ដំណើរការប្រមូល និងវិភាគទិន្នន័យក៏ត្រូវបានពន្យល់ផងដែរ។ បច្ចេកទេសវិភាគទិន្នន័យ និងសេចក្តីសន្ទតក៏ត្រូវបានបញ្ជាក់យ៉ាងល្អិតល្អន់ផងដែរ។ នៅចុងបញ្ចប់ ជំពូកនេះបានបង្ហាញពីសុពលភាព និងភាពជឿជាក់នៃលទ្ធផលដើម្បីបង្កើនគុណភាពនៃការសិក្សាស្រាវជ្រាវ។

### ៣.១ អ្នកចូលរួម និងវិធីសាស្ត្រជ្រើសរើសសំណាកគម្រូ

ការសិក្សានេះ ទទួលបានព័ត៌មានពីអ្នកចូលរួមចម្រុះ ចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋានរួមមាន ថ្នាក់មន្ទីរអប់រំ យុវជននិងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាស្រុក នាយកឬនាយិកាសាលា គណៈកម្មការទ្រទ្រង់សាលា គ្រូបង្រៀន អាជ្ញាធរមូលដ្ឋាន អាណាព្យាបាល និងសិស្ស។ ក្រុមស្រាវជ្រាវបានជ្រើសរើសខេត្តចំនួន ៩និង២៨ឃុំផ្សេងគ្នាដើម្បីបំពេញលក្ខខណ្ឌទំហំសំណាកគម្រូនៃការសិក្សា ក៏ដូចជាដើម្បីទទួលបានទិន្នន័យច្បាស់លាស់សម្រាប់ពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តដែលមានចូលរួមពីទិដ្ឋភាពផ្សេងៗគ្នា ជាពិសេសអ្នកអនុវត្ត និងដើម្បីកំណត់ពីបញ្ហាប្រឈមសំខាន់ៗក្នុងពេលអនុវត្ត។ ការស្រាវជ្រាវនេះបានជ្រើសរើសដោយកំណត់ យកតំណាងមួយរូបមកពីថ្នាក់មន្ទីរ និងថ្នាក់ការិយាល័យ.អយកក្នុងខេត្តនីមួយៗ។ នៅកម្រិតសាលាអ្នកចូលរួមត្រូវបានជ្រើសរើសដោយចេតនាឬគេហៅថាវិធីជ្រើសរើសតាមបែបងាយៗ។ គួរកត់សម្គាល់ផងដែរថា ការសិក្សានេះកំណត់យកតែកម្រិតមធ្យមសិក្សាបឋមភូមិប៉ុណ្ណោះ ដោយមាន ៥៣សាលាចូលរួម (ប្រមាណជា ៩,៣ភាគរយនៃអនុវិទ្យាល័យទាំងអស់នៅកម្ពុជា)។ សាលាទាំងនោះត្រូវបានជ្រើសរើសដោយចៃដន្យជា២ប្រភេទ៖ (១) ១,២ភាគរយ ជាសាលាដែលមានការគាំទ្រដោយដៃគូអភិវឌ្ឍន៍លើការអប់រំបំណិនជីវិត និង(២) ៣,១ភាគរយ ជាសាលាដែលមិនដែលទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍន៍លើការអប់រំបំណិនជីវិត។ នៅតាមសាលារៀននីមួយៗ អ្នកស្រាវជ្រាវបានកំណត់ឱ្យមានអ្នកចូលរួមដូច

ជា នាយកឬនាយិកាសាលា ១រូប គ្រូបង្រៀនថ្នាក់ផ្សេងៗគ្នា ៣រូប៖ គណៈកម្មការទ្រទ្រង់សាលា ១រូប អាណាព្យាបាល ៣រូប និងសិស្សមកពីថ្នាក់ផ្សេងៗគ្នា ៣នាក់ (សូមមើលឧបសម្ព័ន្ធទី ១ និង២)។

## ៣.២ ការប្រមូលទិន្នន័យ

### ៣.២.១ ឧបករណ៍ស្រាវជ្រាវ

ឧបករណ៍ស្រាវជ្រាវ (ពោលគឺកម្រងសំណួរ) ត្រូវបានបង្កើតឡើងដើម្បីទាញយកទិន្នន័យសម្រាប់វិភាគ។ សំណួរសំខាន់ៗជាច្រើន បង្កើតឡើងដោយមានយោងពីការសិក្សា និងរបាយការណ៍ដែលមានសុពលភាពជាច្រើន ដោយសង្កេតមើលការអនុវត្តបំណិនជីវិតបច្ចុប្បន្ន និងកំណត់បញ្ហាប្រឈមនៃការអនុវត្តជាក់ស្តែងសម្រាប់កម្រិតការអប់រំមូលដ្ឋាន ហើយសំណួរមួយចំនួនត្រូវបានកែប្រែដោយអ្នកស្រាវជ្រាវដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ និងតំណាងនៅថ្នាក់ក្រោមជាតិ។

កម្រងសំណួរត្រូវបានរៀបចំជា ៣ ផ្នែកធំ ៗ រួមមាន៖ (១) ផ្នែក ក បញ្ជាក់ពីព័ត៌មានទូទៅរបស់អ្នកចូលរួម (២) ផ្នែក ខ ពិនិត្យមើលឱ្យស៊ីជម្រៅទៅលើវឌ្ឍនភាពនិងបញ្ហាប្រឈមនៃការអនុវត្តការអប់រំបំណិនជីវិតនៅអនុវិទ្យាល័យ និង(៣) ផ្នែក គ កំណត់អន្តរាគមន៍ តម្រូវការ និងមតិយោបល់ដើម្បីឱ្យការអនុវត្តការអប់រំបំណិនជីវិតប្រសើរជាងមុន។ កម្រងសំណួរត្រូវបានកែសម្រួលឱ្យស្របទៅនឹងលក្ខណៈផ្សេងៗគ្នានៃអ្នកចូលរួម (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី ៣)។ ការកែសម្រួល គឺផ្អែកលើគោលការណ៍ណែនាំស្តីពីការអប់រំបំណិនជីវិតរបស់ក្រសួងអប់រំ យុវជន និងកីឡា គោលនយោបាយអប់រំបំណិនជីវិត ឯកសារពាក់ព័ន្ធនានា និងព័ត៌មានត្រឡប់ពីអ្នកអនុវត្តជាក់ស្តែងក្នុងសិក្ខាសាលាពិគ្រោះយោបល់ដែលបានធ្វើឡើងនៅខេត្តកំពង់ចាម នាថ្ងៃទី ១៣-១៤ ខែសីហាឆ្នាំ២០១៨ ដែលមានការចូលរួមពីតំណាងមកពីនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងនាយក ឬនាយិកាសាលា។

មុននឹងចុះប្រមូលទិន្នន័យផ្លូវការ ក្រុមស្រាវជ្រាវបានជ្រើសរើសយកសាលាចំនួន ៩ មកពីស្រុកនិងខេត្តចំនួន ៣ ផ្សេងគ្នាដើម្បីសាកល្បងការសិក្សាដែលបានគ្រោងទុកចាប់ពីថ្ងៃទី ១៧-១៩ ខែកញ្ញាឆ្នាំ២០១៨។ ផ្អែកលើការវិភាគសាកល្បង ក្រុមអ្នកស្រាវជ្រាវបានធ្វើការកែសម្រួលកម្រងសំណួរទៅលើពាក្យពេចន៍ និងទម្រង់ឱ្យកាន់តែមានសុពលភាពដើម្បីឱ្យស្របតាមបរិបទនៃការសិក្សាស្រាវជ្រាវនេះ។

## តារាង ៣.១:សមាមាត្រនៃអ្នកចូលរួមសម្រាប់កម្រងសំណួរសាកល្បង

| ខេត្ត (3) | ឃុំ/ស្រុក (3) | សាលារៀន (៩) | ថ្នាក់មន្ទីរ.អយក (1) | ថ្នាក់ការិយាល័យ.អយក (1) | នាយកឬនាយិកាសាលា (1) | គ្រូបង្រៀន (៣) | គណៈកម្មការទ្រទ្រង់សាលា (1) | សិស្ស (6) | អាជ្ញាធរមូលដ្ឋាន (1) | អាណាព្យាបាល (3) | |
|---|---|---|---|---|---|---|---|---|---|---|---|
| ១ | DP-1 | S-1 | 1 | 1 | 1 | 3 | 1 | 3 | 1 | 3 | |
| | | S-2 | | | 1 | 1 | 1 | 3 | 1 | 1 | |
| | | S-3 | | | 1 | 1 | 1 | 2 | 1 | 1 | |
| ២ | DP-2 | S-4 | 1 | 1 | 1 | 3 | 1 | 6 | 1 | 2 | |
| | | S-5 | | | 1 | 3 | 1 | 6 | 1 | 3 | |
| | | S-6 | | | 1 | 3 | 1 | 6 | 1 | 2 | |
| ៣ | DP-3 | S-7 | 1 | 1 | 1 | 3 | 1 | 6 | 1 | 3 | |
| | | S-8 | | | 1 | 3 | 1 | 6 | 1 | 3 | |
| | | S-9 | | | 1 | 3 | 1 | 6 | 1 | 3 | |
| សរុប | ចំនួនអ្នកចូលរួមជាក់ស្តែង | | 3 | 3 | 9 | 23 | 9 | 44 | 9 | 21 | *(85ភាគរយ) 121* |
| | ចំនួន អ្នកចូលរួមដែលរំពឹងទុក | | 3 | 3 | 9 | 27 | 9 | 54 | 9 | 27 | *141* |

### ៣.២.២ ដំណាក់កាលនៃការប្រមូលទិន្នន័យ

មុនពេលចែកកម្រងសំណួរដល់អ្នកចូលរួមទាំងអស់ ក្រុមអ្នកស្រាវជ្រាវបានរៀបចំការងាររដ្ឋបាលមួយចំនួន រួចទាក់ទងទៅអ្នកដែលត្រូវចូលរួមពីតាមតំបន់គោលដៅនីមួយៗដើម្បីបង្កភាពងាយស្រួលអំឡុងពេលប្រមូលទិន្នន័យ មានន័យថារៀបចំការណាត់ជួបជាមួយអ្នកឆ្លើយតបសំខាន់ៗដែលបានរៀបរាប់ខាងលើដើម្បីបំពេញកម្រងសំណួរ និងសម្ភាសន៍។

កម្រងសំណួរត្រូវបានពិនិត្យទ្វេដង និងចែកជាក្រុមផ្សេងៗគ្នា រួចចែកជូនក្រុមស្រាវជ្រាវនីមួយៗដើម្បីបន្តដំណើរការប្រមូលទិន្នន័យដែលបានធ្វើឡើងជា ៣ ដំណាក់កាលគឺ (១)ចាប់ពីថ្ងៃទី២៩ ខែកញ្ញាដល់ថ្ងៃទី ១ ខែតុលាឆ្នាំ២០១៨ (២) ចាប់ពីថ្ងៃទី ០៤-០៦ ខែតុលា ឆ្នាំ២០១៨ និង(៣)ចាប់ពីថ្ងៃទី ៣០ ខែតុលាដល់ថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០១៨។ ដើម្បីធានាឱ្យបាននូវទិន្នន័យដែលមានភាពជឿជាក់ ក្រុមស្រាវជ្រាវ (សមាជិក ៥ នាក់ក្នុងមួយក្រុម) បានធ្វើការសម្ភាសមួយទល់នឹងមួយ (ពោលគឺ សម្ភាសន៍បែបពាក់កណ្តាលផ្លូវការ) និងបំពេញចម្លើយទៅក្នុងកម្រងសំណួរ។

## ៣.៣ ការវិភាគទិន្នន័យ

ជាជំហានដំបូង ទិន្នន័យនឹងត្រូវបានវិភាគដោយឡែកពីគ្នាទៅតាមគោលបំណងជាក់លាក់នៃការស្រាវជ្រាវ ហើយបន្ទាប់មកទាញសេចក្តីសន្និដ្ឋានរួមមួយ ក្នុងការកំណត់នូវបញ្ហាប្រឈមសំខាន់ៗក្នុងការ អនុវត្តជាក់ស្តែងនៃការអប់រំបំណិនជីវិតនៅកម្ពុជា និងផ្តល់នូវបទអន្តរាគមន៍ជាយុទ្ធសាស្ត្រនានា ដើម្បីលើកកម្ពស់គុណភាពនៃការអនុវត្តនៅកម្រិតមធ្យមសិក្សាបឋមភូមិ។

ដើម្បីសំរេចគោលបំណងនៃការសិក្សានេះ សំណួរស្រាវជ្រាវសំខាន់ៗចំនួនបីត្រូវបានដាក់បញ្ចូល។ សំណួរស្រាវជ្រាវទីមួយបានពិនិត្យមើលការអនុវត្តជាក់ស្តែងនៃការអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិនៅកម្ពុជា ដែលត្រូវបានរាយការណ៍ដោយប្រើស្ថិតិពិពណ៌នាដែលប្រមូលបានពីផ្នែកខ្លះនៃការស្ទង់មតិ។ ចំណុចគន្លឹះដែលត្រូវបានយកមកសម្រាប់ពិនិត្យមើលការអនុវត្តការអប់រំបំណិនជីវិតគឺផ្អែកលើចំណុចគោលចំនួនពីរ ដែលមានចំណុចរងចំនួន ១០ (ដូចដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ៣)។ រាល់ទិន្នន័យដែលប្រមូលបានត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ SPSS (កម្មវិធីទី ២៣)។ ការវិភាគទិន្នន័យធ្វើឡើងដោយប្រើកម្មវិធីវិភាគការស្ទង់មតិ ពោលគឺ ស្ថិតិពិពណ៌នា។ ទិន្នន័យត្រូវបានពណ៌នាដោយបង្ហាញតាមបែបស្ថិតិទៅតាមចំណុចគោលនីមួយៗ និងដាក់ជាតារាងដើម្បីបង្ហាញពីការអនុវត្តជាក់ស្តែងនៃការអប់រំ

បំណិនជីវិតនៅក្នុងបរិបទកម្ពុជា។ ការធ្វើបែបនោះនាំឱ្យមើលឃើញពីបញ្ហាប្រឈមសំខាន់ៗនៃការអនុវត្តកម្មវិធី។ ដើម្បីទទួលបានចម្លើយកាន់តែច្បាស់ជានេះ អ្នកចូលរួមតម្រូវឱ្យឆ្លើយនូវប្រភេទសំនួរបើកដែលមាននៅក្នុងកម្រងសំណួរ។

សំណួរស្រាវជ្រាវទីពីរ មានគោលដៅកំណត់បំណិនអាជីពងាយៗដែលចាំបាច់នៅក្នុងតំបន់គោលដៅនានាដោយប្រើមាត្រដ្ឋាន ៥កម្រិត។ ក្រុមស្រាវជ្រាវបានប្រើប្រាស់ស្ថិតិពណ៌នាដើម្បីបកស្រាយតម្រូវការទាំងនោះ។ ម្យ៉ាងទៀត ដើម្បីឆ្លើយតបបានល្អិតល្អន់ អ្នកចូលរួមត្រូវបញ្ជាក់ពីអ្វីដែលមានតម្រូវការខ្ពស់។លទ្ធផលត្រូវបានបង្ហាញតាមបែបពណ៌នានិងស្ថិតិពណ៌នា (ជាប្រេកង់) ដើម្បីរាប់ចម្លើយ។

សំណួរស្រាវជ្រាវទីបី បានលើកឡើងដើម្បីបង្ហាញបទអន្តរាគមន៍ជាក់ស្តែងដែលអាចយកទៅអនុវត្តបានដោយអ្នកចូលរួមក្នុងការដោះស្រាយបញ្ហាប្រឈមទាក់ទងនឹងការអនុវត្តការអប់រំបំណិនជីវិត និងផ្តល់យោបល់បន្ថែមដើម្បីឆ្លើយតបនឹងតម្រូវការមូលដ្ឋានរបស់ពួកគេ។ រាល់ទិន្នន័យដែលបានប្រមូលត្រូវបានបញ្ចូលទៅក្នុងកម្មវិធី Microsoft Excel សម្រាប់ដំណើរការវិភាគទិន្នន័យដែលមានគុណភាព (ឧ. ការសរសេរកូដ រាប់ប្រេកង់។ល។)។

តាមលក្ខណៈបច្ចេកទេស មុននឹងវិភាគទិន្នន័យ គេត្រូវសម្អាត និងពិនិត្យដើម្បីចៀសវាងកំហុសដែលអាចកើតមាននៅពេលកសរសេរកូដ បញ្ចូល និងកំហុសស្ថិតិផ្សេងទៀតរួមមានការបាត់ទិន្នន័យឬទិន្នមានបញ្ហាជាដើម។

## ៣.៨ សុពលភាព និងសុក្រឹតភាពនៃការស្រាវជ្រាវ

ការសិក្សាជាច្រើន បានព្យាយាមធានានូវសុពលភាពនៃការស្រាវជ្រាវ និងភាពជឿជាក់ឯការសិក្សាស្រាវនេះក៏មិនខុសគ្នាដែរ។ ហេតុដូច្នេះហើយក្រុមស្រាវជ្រាវបានវិភាគលក្ខណៈអថេរដែលត្រូវពិនិត្យ និងបង្កើតកម្រងសំណួរ ដែលបានវាស់វែងយ៉ាងជាក់លាក់ និងមានសង្គតិភាពទៅនឹងអ្វីដែលបានព្រៀងទុក។ ជាការឆ្លើយតប ក្រុមស្រាវជ្រាវបានបង្កើតកម្រងសំណួរដែលមានយោងដោយឯកសារផ្លូវការជាច្រើន (ឧ.MoEYS, ២០០៦, MOEYS, ២០០៩, ២០១៧; Paola, Lane, & Bredenberg, ២០១២; Prajapati, Sharma, & Sharma, ២០១៧)។ លើសពីនេះទៀត ធាតុនីមួយៗក្នុងកម្រងសំណួរ ត្រូវបានពិគ្រោះយោបល់យ៉ាងហ្មត់ចត់ជាមួយអ្នកតំណាងមកពីនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ថ្នាក់មន្ទីរ.អយក ថ្នាក់ការិយាល័យ.អយក និងនាយកឬនាយិកាសាលា។ ជាក់ស្តែង ឧបករណ៍នេះបង្កើតឡើង ដើម្បីវាស់ចំណុចសំខាន់ដែលបានគ្រោងទុកធ្វើយ៉ាងណាឱ្យមានសង្គតិភាព។ ឧបករណ៍នេះត្រូវបានសាកល្បងពិសោធន៍កម្រិត

ជឿជាក់ ដើម្បីធានានូវអ្វីដែលត្រូវវាស់ដោយសំណួរទាំងនោះត្រូវសាកល្បងយ៉ាងល្អិតល្អន់។ ការសិក្សាថ្មីនេះមានគោលបំណងដើម្បីរកឱ្យឃើញនូវបញ្ហាប្រឈមនៅក្នុងការអនុវត្តជាក់ស្តែង (សំណួរស្រាវជ្រាវទី១) ដូចបានបង្ហាញក្នុងតារាង ៣.២។ ជាលទ្ធផល សំណួរស្រាវជ្រាវទី១ បានបង្ហាញថាពិតជាវាស់អំពីការអនុវត្តការអប់រំបំណិនជីវិតជាក់ស្តែងប្រាកដមែន។

**តារាង ៣.២៖ ការបង្ហាញស្ថិតិនៃកម្រិតជឿជាក់ (សំណួរស្រាវជ្រាវទី១)**

| **គំនិតគោល** | Cronbach's Alpha (α) | **ចំនួនសំណួរ** |
|---|---|---|
| ការតម្រង់ទិស | .៧១៦ | ៣ |
| ការប្រតិបត្តិ | .៩៨៩ | ៣៨ |
| ការគាំទ្រផ្នែកធនធានមនុស្ស | .៩០១ | ១២ |
| ការពិនិត្យតាមដាន | .៨៩៨ | ២ |
| ការពិនិត្យមើលវឌ្ឍនភាព | .៩៦២ | ៧ |
| ការសហការគាំទ្រ | .៩៧៤ | ៩០ |

Remarks៖ a≥0.9ឥតខ្ចោះ; a≥0.8ល្អ; a≥0.7អាចទទួលយកបាន; a≥0.6 គួរពិចារណា; a≥0.5ខ្សោយ; a≤0.5 មិនអាចទទួលយកបាន

ក្នុងពេលជាមួយគ្នានេះដែរ សំណួរស្រាវជ្រាវទី២ ដែលនិយាយអំពីតម្រូវការបំណិនជីវិតតាមមូលដ្ឋានដោយប្រើឧបករណ៍មាត្រដ្ឋានដែលមាន៥កម្រិត និង Cronbach alpha ស្មើនឹង .៧៣៧ ដែលកម្រិតមួយដែលអាចទទួលយកបាន។ ដើម្បីបញ្ជាក់ពីសុក្រឹតភាពនៃការស្រាវជ្រាវ សំណួរភាគច្រើនត្រូវបានបញ្ជាក់បន្ថែម និងពិនិត្យមើលឡើងវិញនូវការឆ្លើយរបស់អ្នកចូលរួម។ ជាពិសេសសំណួរនីមួយៗត្រូវបានសម្ភាសផ្ទាល់ និងបំពេញដោយក្រុមស្រាវជ្រាវដើម្បីធានាថា អ្នកឆ្លើយសំណួរបានយល់ច្បាស់។

## ជំពូកទី ៤៖ របកគំហើញ និងការពិភាក្សា

ការសិក្សាបែបរុករកនេះបានបង្ហាញនូវរបកគំហើញដែលមានភាពច្បាស់លាស់ និងជាមូលដ្ឋានដោយមានការពិភាក្សាយ៉ាងលម្អិត។ ជាបឋម ការសិក្សានេះបានគូសបញ្ជាក់អំពីការពិពណ៌នាបែបស្ថិតិ និងក្រាហ្វិកបង្ហាញពីប្រធានបទចម្បងៗស្តីពីការអនុវត្តការអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិនៅកម្ពុជា និងបង្ហាញពីបញ្ហាប្រឈមដែលកំពុងតែជួបប្រទះ។ បន្ទាប់មក សំណួរស្រាវជ្រាវទី ២ បានបង្ហាញពីភាគរយនៃបំណិនអាជីពងាយៗដែលចាំបាច់ និងមានលម្អិតបន្ថែមជាមួយនឹងទិន្នន័យបែបគុណវិស័យ។ សម្រាប់សំណួរស្រាវជ្រាវទី៣ បានរៀបចំផែនការ និងបទអន្តរាគមន៍សំខាន់ៗមួយចំនួនដើម្បីឱ្យការអនុវត្តប្រកបដោយឧត្តមានុវត្តន៍តាមការរំពឹងទុក។

### ៤.១ ព័ត៌មានប្រជាសាស្ត្ររបស់អ្នកចូលរួម

ការស្រាវជ្រាវនេះ បានបញ្ចូលព័ត៌មានពីអ្នកចូលរួមផ្សេងៗជាច្រើនដូចដែលបានលើកឡើងនៅក្នុងជំពូកទី ៣។ ចំណុចដែលគួរឱ្យកត់សម្គាល់គឺថាអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជា ៣ ប្រភេទធំៗគឺ អ្នកគាំទ្រ អ្នកអនុវត្ត និងអ្នកទទួលផល។ តារាង ៤.១ បានបង្ហាញពីប្រេកង់ និងភាគរយនៃអ្នកចូលរួមដែលបានជ្រើសរើស។ ចំនួនសំណាកសរុបក្នុងការវិភាគនេះបានធ្លាក់ចុះមកនៅត្រឹម ៦៨៥នាក់បន្ទាប់ពីកម្រងសំណួរមួយចំនួនមិនត្រូវបានដាក់បញ្ចូលដោយសារពុំមានព័ត៌មានគ្រប់គ្រាន់និងច្បាស់លាស់។

លទ្ធផលនៃការសិក្សាបានបង្ហាញថាភាគរយនៃអ្នកចូលរួមជាបុរស (៥៤,៥ភាគរយ) មានកម្រិតសិក្សាខ្ពស់ជាងនារីដែលមានត្រឹមតែ៤៥,៥ភាគរយ។តែទោះជាយ៉ាងណាក្តីក៏គម្លាតហាក់មិនសូវជាខុសគ្នាច្រើនប៉ុន្មាននោះទេ។ ប្រហែលជា១.៨ភាគរយ នៃអ្នកគាំទ្របច្ចេកទេសដែលមានប្រមាណជា១,៨ភាគរយមានអាយុចន្លោះពី២១ទៅ៣០ ២១ភាគរយមានអាយុចន្លោះពី៣១ទៅ៤០ ៣៩.១ភាគរយមានអាយុចន្លោះពី៤១ទៅ៥០និងប្រហែលជា ៣៧.៤មានអាយុ៥០ឡើង។ គួរបញ្ជាក់ផងដែរថា អ្នកគាំទ្របច្ចេកទេសភាគច្រើនជាមនុស្សវ័យចំណាស់ (អាយុជាង ៤០ ឆ្នាំ)។ ឯអ្នកអនុវត្តភាគច្រើន (៤១,៩ភាគរយ) មានអាយុចាប់ពី ៣១ដល់៤០ឆ្នាំដែលគេនិយាយថាការលើកទឹកចិត្តរបស់គ្រូក្នុងវ័យនោះមានភាពស្វាហាប់និងគំនិតផ្តួចផ្តើមជាងអ្នកមានវ័យចំណាស់។ ទាក់ទងនឹងបទពិសោធន៍ការងារ លទ្ធផលបានបង្ហាញថាប្រហែលជា ៣៨,៩ភាគរយ នៃអ្នកគាំទ្របច្ចេកទេសបានធ្វើការអស់រយៈពេលពី ១ទៅ៥ ឆ្នាំ។ ២៥,៣ភាគរយ ធ្វើការរយៈពេលពី ៦ទៅ១០ ឆ្នាំ ៩ភាគរយ រយៈពេល ១១ទៅ១៥ ឆ្នាំ១០,៣ភាគរយ រយៈពេល ១៦ទៅ២០ ឆ្នាំនិង

៧,១ភាគរយ អស់រយៈពេលជាង ២០ ឆ្នាំ។ ដូចគ្នានេះដែរ អ្នកអនុវត្តភាគច្រើន (១៩,៦ភាគរយ) មានបទពិសោធន៍ក្នុងវិស័យអប់រំអស់រយៈពេលជាង ៥ឆ្នាំ។ ទាំងអ្នកគាំទ្រ និងអ្នកអនុវត្តហាក់មានបទពិសោធន៍ការងារគ្រប់គ្រាន់នៅក្នុងវិស័យនោះ។ បើក្រឡេកទៅមើលប្រវត្តិនៃអប់រំរបស់អ្នកគាំ ទ្រជាពិសេសអាណាព្យាបាលសិស្ស លទ្ធផលបានបង្ហាញថាពួកគាត់ភាគច្រើនបានបញ្ចប់ត្រឹមតែមធ្យមសិក្សាប៉ុណ្ណោះ តួយ៉ាងដូចជា ១,៨ភាគរយ មិនមានសញ្ញាបត្រ ៣១,៦ភាគរយរៀនត្រឹមថ្នាក់ទី១ដល់ទី៦ ៣៤,២ភាគរយ រៀនត្រឹមថ្នាក់ទី៧ដល់ទី៩ និង១៤,៩ភាគរយរៀនត្រឹមថ្នាក់ទី១០ដល់ទី១២។ ក្នុងនោះភាគតិចបំផុតនៃអ្នកចូលរួមបានបន្តថ្នាក់ឧត្តមសិក្សា។ ទាំងនោះអាចនិយាយបានថាការអប់រំរបស់ឪពុកម្តាយនៅតែមានកម្រិតនៅឡើយ ហើយគណៈកម្មការគាំទ្រសាលារៀន និងអាជ្ញាធរមូលដ្ឋានក៏ដូចគ្នាផងដែរ។ ដោយឡែក សម្រាប់គុណវុឌ្ឍិរបស់ថ្នាក់មន្ទីរ ថ្នាក់ការិយាល័យ និងនាយកឬនាយិកាសាលាមានលក្ខណៈសមស្របអាចទទួលយកបាន ដោយមានត្រឹមតែ ៦,៨ភាគរយប៉ុណ្ណោះនៃថ្នាក់ការិយាល័យ.អយកដែលនៅមានគុណវុឌ្ឍិទាប។ សម្រាប់អ្នកអនុវត្តនៅកម្រិតនេះភាគច្រើនបានបញ្ចប់បរិញ្ញាប័ត្ររង ឬវគ្គបណ្តុះបណ្តាលរយៈពេល ២ ឆ្នាំទាក់ទងនឹងឯកទេសរបស់ពួកគេ។ ចំណុចដែលគួរឱ្យកត់សម្គាល់គឺថា អ្នកគាំទ្រដែលមានសញ្ញាប័ត្រភាគច្រើនមានជំនាញខាងផ្នែកមនុស្សសាស្ត្រ ថ្នាក់មន្ទីរ (៨៧,៥ភាគរយ) ថ្នាក់ការិយាល័យ (២៤,១ភាគរយ) នាយកឬនាយិកាសាលា (៤៣,៦ភាគរយ) គណៈកម្មការទ្រទ្រង់សាលា (៧,៧ភាគរយ) អាណាព្យាបាល (២,៦ភាគរយ) និងអ្នកអនុវត្តបានឈានដល់ ៦៣,៥ភាគរយ។

មានគ្រូមុខវិជ្ជាផ្សេងៗគ្នាចូលរួមក្នុងការសិក្សានេះរួមមាន មុខវិជ្ជាកសិកម្ម (២,០ភាគរយ) សិល្បៈ (០,៧ភាគរយ) កុំព្យូទ័រ (១,៤ភាគរយ) រោងជាង (១,៤ភាគរយ) គេហវិទ្យា (១២,៨ភាគរយ) អក្សរសាស្ត្រខ្មែរ (១៩,៦ភាគរយ) គណិតវិទ្យា (៩,៥ភាគរយ) វិទ្យាសាស្ត្រ (២៣,០ភាគរយ) និងវិទ្យាសាស្ត្រសង្គម (២៨,៤ភាគរយ)។ ជាមួយគ្នានេះ គ្រូមុខវិជ្ជាទាំងនោះកំពុងបង្រៀនថ្នាក់ផ្សេងគ្នាដូចជាថ្នាក់ទី៧(១៦,២ភាគរយ)ថ្នាក់ទី៨(១៥,៨ភាគរយ)និងថ្នាក់ទី៩(១៦៩,៦ភាគរយ)។ គួរបញ្ជាក់ផងដែរថា គ្រូខ្លះបង្រៀនតែមួយថ្នាក់ប៉ុណ្ណោះ តែខ្លះបង្រៀនច្រើនថ្នាក់។ ក្រៅពីនេះ អ្នកទទួលផលរួមមានអ្នកដែលមកពីថ្នាក់ផ្សេងៗ - ថ្នាក់ទី ៧ (៣១,៩ភាគរយ) ថ្នាក់ទី ៨ (៣៦,៣ភាគរយ) និងថ្នាក់ទី ៩ (៣៦,៩ភាគរយ)។

## តារាង ៤.១៖ ការបង្ហាញភាគរយនៃសាវតាអ្នកចូលរួម

| អថេរ | ការពណ៌នា | អ្នកចូលរួម | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | អ្នកគាំទ្រ ( **n=267** ) | | | | | | | | | | | | | | អ្នកអនុវត្ត **(n=148)** | | អ្នកទទួលផល **(n=270)** | |
| | | ថ្នាក់មន្ទីរ (N=8) | | ថ្នាក់ការិយាល័យ (N=29) | | នាយកឬនាយិកាសាលា (N=39) | | គណៈកម្មការទ្រទ្រង់សាលា (N=36) | | អាជ្ញាធរមូលដ្ឋាន (N=42) | | អាណាព្យាបាល (N=113) | | **សរុប** | | គ្រូ (N=148) | | សិស្ស (N=270) | |
| | | *f* | ភាគរយ | *f* | ភាគរយ | *f* | ភាគរយ | *f* | ភាគរយ | *f* | ភាគរយ | *f* | ភាគរយ | ***f*** | **ភាគរយ** | *f* | ភាគរយ | *f* | ភាគរយ |
| ភេទ | ប្រុស | *6* | 75 | *29* | 100 | *36* | 92.3 | *34* | 87.2 | *38* | 90.5 | 48 | 42.1 | *191* | 71.5 | *83* | 56.1 | *102* | 37.8 |
| | ស្រី | *2* | 25 | *0* | 0.00 | *3* | 7.7 | *5* | 12.8 | *4* | 9.5 | 65 | 57.0 | *84* | 31.5 | *65* | 43.9 | *168* | 62.2 |
| អាយុ | ១១-២០ ឆ្នាំ | *0* | 0.00 | *0* | 0.00 | *0* | 0.00 | *0* | 0.00 | *0* | 0.00 | 0 | 0.00 | *0* | 0.00 | *0* | 0.00 | *268* | 99.3 |

| | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២១-៣០ ឆ្នាំ | *0* | 0.00 | *0* | 0.00 | *2* | 5.1 | *0* | 0.00 | *1* | 2.4 | 2 | 1.8 | *5* | 1.9 | *49* | 33.1 | *0* | 0.00 |
| | ៣១-៤០ ឆ្នាំ | *0* | 0.00 | *5* | 17.2 | *12* | 30.8 | *3* | 7.7 | *3* | 7.1 | 33 | 28.9 | *56* | 21 | *62* | 41.9 | *0* | 0.00 |
| | ៤១-៥០ ឆ្នាំ | *5* | 62.5 | *16* | 55.2 | *21* | 53.8 | *7* | 17.9 | *9* | 21.4 | 47 | 41.2 | *105* | 39.3 | *26* | 17.6 | *0* | 0.00 |
| | ៥០ ឆ្នាំឡើង | *3* | 37.5 | *8* | 27.6 | *1* | 2.6 | *29* | 74.4 | *29* | 69.0 | 30 | 26.3 | *100* | 37.5 | *4* | 2.7 | *0* | 0.00 |
| បទពិសោធន៍ | ០ ឆ្នាំ | *0* | 0.00 | *0* | 0.00 | *0* | 0.00 | *0* | 0.00 | *0* | 0.00 | | | *0* | 0.00 | *0* | 0.00 | | |
| | ១-៥ ឆ្នាំ | *3* | 37.5 | *14* | 48.3 | *15* | 38.5 | *17* | 43.6 | *11* | 26.2 | | | *60* | 39.0 | *17* | 11.5 | | |
| | ៦-១០ ឆ្នាំ | *3* | 37.5 | *8* | 27.6 | *10* | 25.6 | *10* | 25.6 | *8* | 19.0 | | | *39* | 25.3 | *29* | 19.6 | | |
| | ១១-១៥ ឆ្នាំ | *0* | 0.00 | *3* | 10.3 | *4* | 10.3 | *2* | 5.1 | *5* | 11.9 | | | *14* | 9.1 | *15* | 10.1 | | |
| | ១៦-២០ ឆ្នាំ | *1* | 12.5 | *1* | 3.4 | *0* | 0.00 | *4* | 10.3 | *10* | 23.8 | | | *16* | 10.4 | *8* | 5.4 | | |
| | ២០ ឆ្នាំឡើង | *1* | 12.5 | 3 | 6.9 | 1 | 2.6 | *5* | 12.8 | *1* | 2.4 | | | *11* | 7.1 | *15* | 10.1 | | |
| វិញ្ញាបនប | មិនមាន សញ្ញាបត្រ | *0* | 0.00 | *0* | 0.00 | *0* | 0.00 | *0* | 0.00 | *0* | 0.00 | *2* | 1.8 | *2* | 0.7 | *0* | 0.00 | | |

| | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថ្នាក់ទី ១-៦ | *0* | 0.00 | *0* | 0.00 | *0* | 0.00 | *16* | 41.0 | *12* | 28.6 | *36* | 31.6 | *64* | 24.0 | *0* | 0.00 | | |
| | ថ្នាក់ទី ៧-៩ | *0* | 0.00 | *1* | 3.4 | *0* | 0.00 | *13* | 33.3 | *15* | 35.7 | *39* | 34.2 | *68* | 25.5 | *0* | 0.00 | | |
| | ថ្នាក់ទី ១០-១២ | *0* | 0.00 | *1* | 3.4 | *0* | 0.00 | *6* | 15.4 | *11* | 26.2 | *17* | 14.9 | *35* | 13.1 | *1* | 0.7 | | |
| | បរិញ្ញាបត្ររង | *0* | 0.00 | *10* | 34.5 | *17* | 43.6 | *0* | 0.00 | *0* | 0.00 | *4* | 3.5 | *31* | 11.6 | *97* | 65.5 | | |
| | បរិញ្ញាបត្រ | *0* | 0.00 | *10* | 34.5 | *20* | 51.3 | *3* | 7.7 | *2* | 4.8 | *2* | 1.8 | *37* | 13.9 | *49* | 33.1 | | |
| | អនុបណ្ឌិត | *8* | 100 | *7* | 24.1 | *0* | 0.00 | *0* | 0.00 | *0* | 0.00 | *0* | 0.00 | *15* | 5.6 | *1* | 0.7 | | |
| ជំនាញ | គ្មានជំនាញ | *0* | 0.00 | *2* | 6.9 | *0* | 0.00 | *31* | 79.5 | *35* | 83.3 | *88* | 77.2 | *156* | 58.4 | *0* | 0.00 | | |
| | មនុស្សសាស្ត្រ | *7* | 87.5 | *7* | 24.1 | *17* | 43.6 | *3* | 7.7 | *0* | 0.00 | *3* | 2.6 | *37* | 13.9 | *94* | 63.5 | | |
| | វិទ្យាសាស្ត្រសង្គម | *0* | 0.00 | *10* | 34.5 | *3* | 7.7 | *0* | 0.00 | *2* | 4.8 | *2* | 1.8 | *17* | 6.4 | *8* | 5.4 | | |
| | វិទ្យាសាស្ត្រធម្មជាតិ | *0* | 0.00 | *5* | 17.2 | *13* | 33.3 | *4* | 10.3 | *2* | 4.8 | *7* | 6.1 | *31* | 11.6 | *30* | 20.3 | | |
| | វិទ្យាសាស្ត្រពិត | *1* | 12.5 | *1* | 3.4 | *1* | 2.6 | *0* | 0.00 | *0* | 0.00 | *1* | 0.9 | *4* | 1.5 | *11* | 7.4 | | |

| | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | វិទ្យាសាស្ត្រអនុវត្ត | *0* | 0.00 | *0* | 0.00 | *1* | 2.6 | *0* | 0.00 | *1* | 2.4 | *0* | 0.00 | *2* | 0.7 | *3* | 2.0 | | |
| មុខវិជ្ជាបង្រៀន | កសិកម្ម | | | | | | | | | | | | | | | *3* | 2.0 | | |
| | សិល្បៈ | | | | | | | | | | | | | | | *1* | 0.7 | | |
| | កុំព្យូទ័រ | | | | | | | | | | | | | | | *2* | 1.4 | | |
| | រោងជាង | | | | | | | | | | | | | | | *2* | 1.4 | | |
| | គេហវិទ្យា | | | | | | | | | | | | | | | *19* | 12.8 | | |
| | ខ្មែរ | | | | | | | | | | | | | | | *29* | 19.6 | | |
| | គណិតវិទ្យា | | | | | | | | | | | | | | | *14* | 9.5 | | |
| | វិទ្យាសាស្ត្រ | | | | | | | | | | | | | | | *34* | 23.0 | | |
| | វិទ្យាសាស្ត្រសង្គម | | | | | | | | | | | | | | | *42* | 28.4 | | |
| ថ្នាក់បង្រៀន | ថ្នាក់ទី៧:<br>១ = មិនមែន | | | | | | | | | | | | | | | *37* | 25 | | |
| | ២ = មែន | | | | | | | | | | | | | | | *111* | 75 | | |

| | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថ្នាក់ទី៨:<br>១ = មិនមែន | | | | | | | | | | | | | | | *40* | 27.0 | | |
| | ២ = មែន | | | | | | | | | | | | | | | *108* | 73.0 | | |
| | ថ្នាក់ទី៩:<br>១ = មិនមែន | | | | | | | | | | | | | | | *34* | 23.0 | | |
| | ២ = មែន | | | | | | | | | | | | | | | *114* | 77.0 | | |
| ថ្នាក់រៀន | ៧ | | | | | | | | | | | | | | | | | 86 | 31.9 |
| | ៨ | | | | | | | | | | | | | | | | | 98 | 36.3 |
| | ៩ | | | | | | | | | | | | | | | | | 86 | 31.9 |

## ៤.២ ស្ថានភាពបច្ចុប្បន្ននៃការអនុវត្តការអប់រំបំណិនជីវិត និងបញ្ហាប្រឈម

សំណួរស្រាវជ្រាវទី១ មានចេតនាបង្ហាញពីស្ថានភាពបច្ចុប្បន្ននៃការអនុវត្តការអប់រំបំណិនជីវិត និងដោះស្រាយបញ្ហាប្រឈមដែលកំពុងជួបប្រទះក្នុងអំឡុងពេលអនុវត្តនៅកម្រិតមធ្យមសិក្សាបឋមភូមិ។

### ៤.២.១ ការយល់ដឹងពីការអប់រំបំណិនជីវិត

ផ្អែកតាមទិន្នន័យក្នុងស្ថិតិពណ៌នាបានបង្ហាញថា ការអប់រំបំណិនជីវិតត្រូវបានដាក់ឱ្យអនុវត្តនៅតាមបណ្ដាសាលារៀនប្រមាណជាជាង១០ឆ្នាំមកហើយ។ ទោះយ៉ាងណា រូបភាពទី ៤.១ ខាងក្រោមបង្ហាញថាក្នុងចំណោមអ្នកឆ្លើយសំណួរ ៦៨៣នាក់ ដែលត្រូវបានជ្រើសរើសមកពីខេត្តចំនួន ៩មាន ៣១.៦ភាគរយ នៅតែអះអាងថាពួកគេមិនដែលដឹង "បំណិនជីវិត" ចំណែកឯ ៦៨.៤ភាគរយ បានឆ្លើយថាធ្លាប់បានដឹង។ អ្នកដែលមិនសូវមានការយល់ដឹងច្រើនអំពីកម្មវិធីភាគច្រើន គេសង្កេតឃើញថាជាសិស្ស បន្ទាប់មកគឺអាណាព្យាបាល គ្រូ អាជ្ញាធរមូលដ្ឋាន គណៈកម្មការទ្រទ្រង់សាលារៀន និងនាយក ឬនាយិកាសាលា ដូចបង្ហាញក្នុងរូបភាព ៤.២។ ម៉្យាងវិញទៀត អ្នកចូលរួមដែលគេអះអាងថាធ្លាប់បានដឹងពីការអប់រំបំណិនជីវិតបានពន្យល់ថា ការអប់រំបំណិនជីវិតសំដៅលើបំណិនដែលត្រូវប្រើក្នុងជីវភាពប្រចាំថ្ងៃ និងសម្រាប់ការងារនាពេលអនាគតរួមមានបំណិនមូលដ្ឋាន (ឧ- ការទំនាក់ទំនង សុខភាព យេនឌ័រ បុគ្គល សីលធម៌ ការគិតពិចារណា ការដោះស្រាយបញ្ហា)។ អាចនិយាយបានថាពីការយល់ដឹងពីបំណិនជីវិតនៅតែស្ថិតក្នុងស្ថានភាពព្រួយបារម្ភនៅឡើយ ខណៈដែលអ្នកអនុវត្តផ្ទាល់ពោលគឺគ្រូបង្រៀន (៤,៨ភាគរយ) នៅតែខ្វះការយល់ដឹង។

*រូបភាព ៤.១៖ ក្រាហ្វិចបង្ហាញការយល់ដឹងអំពីបំណិនជីវិត (n=៦៨៣)*



*រូបភាព ៤.២៖ ក្រាហ្វិចបង្ហាញភាគរយអ្នកចូលរួមដែលមិនធ្លាប់បានដឹងពីការអប់រំបំណិនជីវិត (n=២១៦)*




## ៤.២.២. ការតម្រង់ទិស

ការតម្រង់ទិសការដឹកនាំដែលជាចំណុចគន្លឹះសំខាន់ទី ២ ដែលចែកចេញជា ៣អថេរជាក់លាក់ ពោលគឺសេចក្តីណែនាំ ការណែនាំ និងការផ្សព្វផ្សាយ។ ស្ថិតិពណ៌នាបានបង្ហាញថាចាប់តាំងពីគោលនយោបាយអប់រំបំណិនជីវិតបានបង្កើតមក ប្រមាណជា៤២,៧ភាគរយ នៃអ្នកចូលរួមដែលបានជ្រើសរើស (ថ្នាក់មន្ទីរ ថ្នាក់ការិយាល័យ នាយកឬនាយិកាសាលា និងគ្រូ) បានបញ្ជាក់ថាមិនដែលបានទទួលសេចក្តីណែនាំ ឬឯកសារពាក់ព័ន្ធនានា ទាក់ទងនឹងការអនុវត្ត មើលរូបភាព ៤.៣។ រូបភាព ៤.៤ បានបង្ហាញពីភាគរយនៃអ្នកឆ្លើយសំណួរដែលមិនធ្លាប់ទទួលបានការគាំទ្រទាំងនោះដាច់ដោយឡែកពីគ្នា គ្រូបង្រៀន (៦០ភាគរយ) នាយកឬនាយិកាសាលា (៤៣,៦ភាគរយ) ការិយាល័យ.អយក (៤២,៩ភាគរយ) និងមន្ទីរ.អយក (៣៧,៥ភាគរយ)។ អាចនិយាយបានថា សេចក្តីណែនាំអនុវត្តការអប់រំបំណិនជីវិតមិនទាន់បានផ្តល់គ្រប់ជ្រុងជ្រោយដល់អ្នកអនុវត្តឡើយ ជាពិសេសគ្រូបង្រៀនផ្ទាល់តែម្តង។

*រូបភាព ៤.៣៖ ភាគរយអ្នកដែលទទួលបានឯកសារសេចក្ដីណែនាំ (n=222)*




*រូបភាព ៤.៤៖ ភាគរយអ្នកមិនបានទទួលឯកសារសេចក្ដីណែនាំ ឬឯកសារពាក់ព័ន្ធ*



*រូបភាព ៤.៥៖ ភាគរយអ្នកដែលមិនបានទទួលការណែនាំទាក់ទងនឹងការអនុវត្ត*




លើសពីនេះទៀត ក្នុងចំណោមអ្នកចូលរួមក្នុងការស្រាវជ្រាវដែលបានរាយការណ៍ថាមិនដែលទទួលបានការណែនាំរួមមាន ថ្នាក់ការិយាល័យ.អយក (៦៥,៥ភាគរយ) នាយក ឬនាយិកាសាលា (៥៩ភាគរយ) ថ្នាក់មន្ទីរ (៥០ភាគរយ) និងគណៈកម្មការទ្រទ្រង់សាលា (២៣,៣ភាគរយ) បានរាយការណ៍ថាមិនដែលទទួលបានការណែនាំណាមួយ (ដូចបង្ហាញក្នុង រូបភាព ៤.៥)។ ក្នុងពេលដំណាលគ្នា៧៩ភាគរយនៃគ្រូក៏បានរាយការណ៍ថាមិនដែលទទួលបានការណែនាំទាក់ទងនឹងការអនុវត្តកម្មវិធីទេ។ ដូចដែលបានឃើញហើយភាគច្រើននៃអ្នកគាំទ្រ និងអ្នកអនុវត្តនៅមិនទាន់បានតម្រង់ទិសបានច្បាស់លាស់នៅឡើយទាក់ទងនឹងការអនុវត្តកម្មវិធីនោះទេ។

## ៤.២.២ ការប្រតិបត្តិការអប់រំបំណិនជីវិត

### *៤.២.២.១ ការអនុវត្តការអប់រំបំណិនជីវិត*

មុនពេលនិយាយអំពីចំណុចគន្លឹះផ្សេងទៀត ការអប់រំបំណិនជីវិតត្រូវបានគេមើលថាតើធ្លាប់បានអនុវត្តនៅកម្រិតមធ្យមសិក្សាបឋមភូមិដែរឬទេ។ក្នុងនោះអ្នកចូលរួមប្រមាណជា៩៦,៨ភាគរយ បានឆ្លើយថាពិតជាធ្លាប់បានអនុវត្តកម្មវិធីបំណិនជីវិតក្នុងសាលារៀនរបស់ពួកគាត់ពិតប្រាកដមែន (មាន៥០សាលា ដែលបានឆ្លើយដូច្នោះ)។ លទ្ធផលបានបង្ហាញថា ២០,៩ភាគរយនៃនាយកឬនាយិកាសាលាបានរ៉ាយរ៉ាប់ថាធ្លាប់បានអនុវត្ត ខណៈដែល ៧,៩ភាគរយ នៃគ្រូបង្រៀនក៏បានឆ្លើយដូចគ្នាផងដែរ ដូចបានបង្ហាញក្នុងរូបភាព៤.៦។

*រូបភាព ៤.៦៖ ភាគរយអ្នកដែលបានអនុវត្តការអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិនៅកម្ពុជា*




បន្ទាប់ពីទទួលបានលទ្ធផលពីអ្នកគាំទ្រនិងអ្នកអនុវត្តផ្ទាល់ (ឧ. នាយកឬនាយិកាសាលានិងគ្រូ) សិស្ស (៩៦,៣ភាគរយ) បានរាយការណ៍ថាធ្លាប់បានរៀនបំណិនជីវិតនៅក្នុងសាលារបស់ពួកគេ (៥០ សាលា) ប៉ុន្តែ មានសិស្ស ៣,៧ភាគរយ (សាលាចំនួន ៥) បាននិយាយថាមិនដែលបានរៀននោះទេ។

*៤.២.២.២ បំណិនជីវិតដែលបានអនុវត្ត*

ចំណុចគន្លឹះសំខាន់នេះគោលដៅទាញយកពីដែលអ្នកចូលរួមទាំងអស់(n=៦៨៥)ចំណែកអ្នកចូលរួមខ្លះត្រូវបានដកចេញដោយសារទិន្នន័យមិនគ្រប់គ្រាន់និងមិនបានអនុវត្ត។ ជាក់ស្តែងបំណិនទូទៅមិនមែនជាមុខវិជ្ជាកាតព្វកិច្ចទេ ប៉ុន្តែវាជាមុខវិជ្ជាដែលត្រូវបញ្ជ្រាបទៅក្នុងមុខវិជ្ជាដទៃទៀត។ ៩០,៥ភាគរយនៃអ្នកចូលរួមបានលើកឡើងថាបានអនុវត្តមុខវិជ្ជានេះ។ ស្របពេលជាមួយគ្នានេះដែរ អ្នកចូលរួម(៨៤,៩ភាគរយ) បានអះអាងថាបំណិនទូទៅត្រូវបានបញ្ជ្រាបក្នុងមុខវិជ្ជានានានៅថ្នាក់ទី៧ នៅថ្នាក់ទី ៨ មាន ៨៣,២ភាគរយ និងថ្នាក់ទី៩ មាន ៧៨,២ភាគរយ។ អ្នកចូលរួម ៧៦,១ភាគរយបានអះអាងថាធ្លាប់បានអនុវត្ត "បំណិនបុរេវិជ្ជាជីវៈ"។ បំណិនទាំងនោះត្រូវបានគេអះអាងថាបានបញ្ចូលគ្នាក្នុង ៣ ថ្នាក់ផ្សេងគ្នាដូចជា ថ្នាក់ទី ៧ (៧០ភាគរយ), ថ្នាក់ទី ៨ (៦៧,២ភាគរយ) និងថ្នាក់ទី ៩ (៦១,១ភាគរយ)។ ភាគរយនៃសិស្សថ្នាក់ទី ៩ ដែលទទួលបានបំណិនបុរេវិជ្ជាជីវៈហាក់ដូចជាមានការធ្លាក់ចុះ។

បើក្រឡេកទៅមើលបំណិនអាជីពងាយៗ បំណិនទាំងនេះត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សាបឋមភូមិ ដើម្បីបំពាក់បំណិនងាយៗដល់អ្នកសិក្សាដែលជាផ្នែកមួយនៃកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន និងការអប់រំក្រៅប្រព័ន្ធ។ លទ្ធផលបានបង្ហាញថា ៨១,១ភាគរយនៃអ្នកចូលរួមបានអះអាងថា មុខវិជ្ជាកសិកម្មត្រូវបានអនុវត្តនៅតាមសាលារៀនក្នុងតំបន់របស់ពួកគេ ហើយអ្នកផ្សេងទៀតនិយាយថា "មិនបាន"។ ៧៧,៨ភាគរយ នៃអ្នកចូលរួមទាំងអស់បាននិយាយថាបំណិននោះបានអនុវត្តនៅថ្នាក់ទី ៧ នៅថ្នាក់ទី ៨ មាន ៧៧,៨ភាគរយ ហើយមានតែ ៧៥ភាគរយ ប៉ុណ្ណោះនៅថ្នាក់ទី ៩។ បន្ទាប់មក ៣៩,៧ភាគរយនៃអ្នកចូលរួមបានអះអាងថា មុខវិជ្ជារោងជាងបានអនុវត្តក្នុងមូលដ្ឋានរបស់ពួកគាត់។ ក្នុងចំណោមនោះ មាន៣៩,៥ភាគរយបាននិយាយថាធ្លាប់បានធ្វើនៅថ្នាក់ទី ៧ ៣២.៥ភាគរយ នៅថ្នាក់ទី៨ និង ៣០,៣ភាគរយ នៅថ្នាក់ទី៩។ ភាគរយហាក់ដូចជាធ្លាក់ចុះសម្រាប់ជំនាញនេះ។ ជំនាញមួយទៀតគឺ "គេហវិទ្យា" ដែលតម្រូវឱ្យផ្តល់ជូនអ្នកសិក្សានូវជំនាញផ្សេងៗដូចជា ការចំអិន ច្នៃសំលៀកបំពាក់សាមញ្ញ និងជំនាញដេរប៉ាក់ជាដើម។ អ្វីដែលគួរឱ្យកត់សម្គាល់គឺថាអ្នកចូលរួមដែលឆ្លើយថាបានហ្វឹកហាត់ជំនាញមានកំណើនដល់ទៅ ៩៣,៩ភាគរយ។ ៩១,១ភាគរយ នៃអ្នកចូលរួមបានលើកឡើងថាគេហវិទ្យាត្រូវបានអនុវត្តនៅថ្នាក់ទី ៧ ៩១,១ភាគរយ នៅថ្នាក់ទី ៨ ប៉ុន្តែមានតែ ៨៧,៨ភាគរយប៉ុណ្ណោះនៅក្នុងថ្នាក់ទី ៩។ បន្ថែមពីនេះ សិល្បៈក៏ជាបំណិនមួយដែលអ្នកសិក្សាត្រូវរៀនជាចាំបាច់។ ប៉ុន្តែ មានអ្នកចូលរួមត្រឹមតែ ៤៥,៨ភាគរយបានលើកឡើងថាបានអនុវត្តបំណិននេះនៅក្នុងមូលដ្ឋានរបស់ពួកគេ។ ៤៣ភាគរយភាគរយនៃចូលរួមបានអះអាងថាបានអនុវត្តនៅថ្នាក់ទី៧ ៤៣ភាគរយអនុវត្តនៅថ្នាក់ទី៨ និង៤០,៨ភាគរយ អនុវត្តនៅថ្នាក់ទី៩។ ចុងក្រោយ ជំនាញដែលចាំបាច់សម្រាប់សង្គមសតវត្សរ៍ទី ២១ គឺកុំព្យូទ័រ។ ប៉ុន្តែមានភាគតិចណាស់នៃអ្នកចូលរួម (១០,៥ភាគរយ) បានលើកឡើងថាមានថ្នាក់កុំព្យូទ័រនៅតាមសាលាសម្រាប់ថ្នាក់ទី ៧ ដល់ទី ៩។ យោងតាមស្ថិតិដែលបានរៀបរាប់ខាងលើ ភាគរយនៃការអនុវត្តបំណិនជីវិតមូលដ្ឋានមានកំរិតខ្ពស់ និងរីកដុះដាលពេញទាំង ៣កម្រិត បើប្រៀបធៀបនឹងបំណិនអាជីពងាយៗ គេសង្កេតឃើញថាភាគរយនៃអ្នកចូលរួមដែលបានអះអាងថាបានអនុវត្តបំណិននេះបានធ្លាក់ចុះ ជាពិសេសនៅថ្នាក់ទី៩ ហើយមុខវិជ្ជាដែលមិនគួរមើលរំលង គឺកុំព្យូទ័រ រោងជាង និងសិល្បៈ មើលតារាង ៤.២។

តារាង ៤.២៖ ភាគរយសង្ខេបនាយកឬនាយិកាសាលា និងគ្រូដែលបានអនុវត្តការអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិ

| | | ភាគរដែលបានអនុវត្ត | ថ្នាក់ទី ៧ | ថ្នាក់ទី ៨ | ថ្នាក់ទី ៩ |
|---|---|---|---|---|---|
| បំណិនមូលដ្ឋាន | បំណិនទូទៅ | ៩០,៥ | ៨៤,៩ | ៨៣,២ | ៧៨,២ |
| | បំណិនបុរេវិជ្ជាជីវៈ | ៧៦,១ | ៧០,០ | ៦៧,២ | ៦១,១ |
| បំណិនអាជីព (បំណិនអាជីពងាយៗ) | ១. កសិកម្ម | ៨១,១ | ៧៧,៨ | ៧៧,៨ | ៧៥,០ |
| | ២.រោងជាង | ៣៤,២ | ៣២,៥ | ៣២,៥ | ៣០,៣ |
| | ៣. គេហវិទ្យា | ៩៣,៩ | ៩១,១ | ៩១,១ | ៨៧,៨ |
| | ៤. សិល្បៈ | ៤៥,៨ | ៤៣,០ | ៤៣,០ | ៤០,៨ |
| | ៥. កុំព្យូទ័រ | ១០,៥ | ១០,៥ | ១០,៥ | ១០,៥ |

ឆ្លុះបញ្ចាំងពីការរកឃើញនៅក្នុងតារាង ៤.៣ សិស្សបានរាយការណ៍ស្រដៀងគ្នាថាមុខវិជ្ជាសំខាន់ចំនួន ៣ គឺរោងជាង សិល្បៈនិងកុំព្យូទ័រ មិនទាន់បានអនុវត្តពេញលេញនៅឡើយ បើធៀបទៅនឹងមុខវិជ្ជាដទៃទៀត ដូចបានបង្ហាញក្នុងតារាង ៤.៣។

តារាង ៤.៣៖ ភាគរយសិស្សដែលបានរៀនបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិ

| | | ភាគរដែល បានអនុវត្ត | ថ្នាក់ទី ៧ | ថ្នាក់ទី ៨ | ថ្នាក់ទី ៩ |
|---|---|---|---|---|---|
| បំណិនមូលដ្ឋាន | បំណិនទូទៅ | ៩៣,៤ | ៨៨,៤ | ៥៦,៣ | ២៦,២ |
| | បំណិនបុរេវិជ្ជាជីវៈ | ៨៩,២ | ៧៩,២ | ៥៦,៤ | ២៩,៩ |
| បំណិនអាជីព (បំណិនអាជីពងាយៗ) | ១. កសិកម្ម | ៧៩,៦ | ៧៣,៤ | ៤២,៣ | ២២,៧ |
| | ២.រោងជាង | ៣៥,៩ | ៣២,៤ | ២៣,០ | ១១,៣ |
| | ៣. គេហវិទ្យា | ៩៥,៤ | ៩២,៣ | ៦១,០ | ២៨,៦ |
| | ៤. សិល្បៈ | ៤៥,៧ | ៤៤,១ | ២៩,៣ | ១៦,៤ |
| | ៥. កុំព្យូទ័រ | ១០,៩ | ៧,៨ | ៣,៥ | ៣,១ |

*៤.២.២.៤ ភាពញឹកញាប់នៃការអនុវត្តការអប់រំបំណិនជីវិត*

បន្ទាប់ពីបង្ហាញពីមុខវិជ្ជាបំណិនជីវិតដែលបានអនុវត្ត អ្នកចូលរួមបានបន្តបកស្រាយពីភាពញឹកញាប់នៃការអនុវត្តនូវបំណិនទាំងនោះ។ សម្រាប់បំណិនអាជីពងាយៗ តួយ៉ាងដូចជាកសិកម្ម បានបង្ហាញថានាយកឬនាយិកាសាលា និងគ្រូភាគច្រើន (៥៤,៨ភាគរយ) និងសិស្ស (៣៤,៦ភាគរយ) ឆ្លើយថាបានអនុវត្ត និងរៀន១ម៉ោងក្នុង១សប្តាហ៍ ស្របតាមសេចក្តីណែនាំ។ ក្នុងពេលជាមួយគ្នានេះដែរ ក៏មានភាគរយតិចតួចនៃអ្នកឆ្លើយសំណួរដែលបានរាយការណ៍ថាមិនដែលបានធ្វើទាល់តែសោះ សូមមើលរូបភាព ៤.៧។

*រូបភាព ៤.៧៖ ភាគរយបង្ហាញភាពញឹកញាប់ដែលនាយកឬនាយិកា គ្រូ និងសិស្សដែលបានអនុវត្តមុខវិជ្ជាកសិកម្ម*




ស្ថិតិពណ៌នានៃការអនុវត្តមុខវិជ្ជារោងជាងបានបង្ហាញថា ១,៦ភាគរយ នៃអ្នកចូលរួមបានអះអាងថាមុខវិជ្ជានេះមិនដែលបានអនុវត្តនៅតាមតំបន់របស់ពួកគាត់នៅឡើយទេ ប៉ុន្តែ សិស្ស ៦៩,៨ភាគរយ បានអះអាងថាពួកគេមិនបានរៀនមុខវិជ្ជានោះទេ ខណៈដែលភាគរយតិចតួចណាស់នៃអ្នកចូលរួមបានឆ្លើយថាបានអនុវត្ត ប្រធានបទនោះនៅក្នុងសាលារៀនរបស់ពួកគេ ដូចដែលបានឃើញនៅក្នុងរូបភាព ៤.៨។

*រូបភាព ៤.៨៖ ភាគរយបង្ហាញភាពញឹកញាប់ដែលនាយកឬនាយិកា គ្រូ និងសិស្សដែលបានអនុវត្តមុខវិជ្ជារោងជាង*




យោងតាមស្ថិតិពណ៌នាខាងក្រោម (រូបភាព ៤.៩) អ្នកអនុវត្ត ៣០,៤ភាគរយ បាននិយាយថា ពួកគេមិនដែលអនុវត្តមុខវិជ្ជាគេហវិទ្យានៅតំបន់របស់ពួកគាត់ទេ ហើយសិស្សភាគច្រើន (៥៤,១ភាគរយ) បានលើកឡើងថាពួកគេមិនដែលបានរៀនទេ ទោះយ៉ាងណាក៏នៅមានចំនួនតិចណាស់ដែលអះអាងថាបានរៀន។

*រូបភាព ៤.៩៖ ភាគរយបង្ហាញភាពញឹកញាប់ដែលនាយកឬនាយិកា គ្រូ និងសិស្សដែលបានអនុវត្តមុខវិជ្ជាគេហវិទ្យា*




រូបភាព ៤.១០ បានបង្ហាញផ្ទុយស្រឡះទៅនឹងមុខវិជ្ជាពីរផ្សេងទៀតគឺ រោងជាងនិងគេហវិទ្យា ខណៈ ២៩,៨ភាគរយ នៃអ្នកអនុវត្តអះអាងថាបានអនុវត្តមុខវិជ្ជាសិល្បៈ ១ ម៉ោងក្នុងមួយសប្តាហ៍ ហើយសិស្ស ៥៣,១ភាគរយ លើកឡើង ថាពួកគេបានរៀនមុខវិជ្ជានោះ។ យោងតាមលទ្ធផលបានបង្ហាញថា មុខវិជ្ជានេះទំនងជាបានអនុវត្តជាប្រចាំនៅក្នុងសាលារបស់ពួកគេឆ្លើយតបនឹងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

*រូបភាព ៤.១០៖ ភាគរយបង្ហាញភាពញឹកញាប់ដែលនាយកឬនាយិកា គ្រូ និងសិស្សដែលបានអនុវត្តមុខវិជ្ជាសិល្បៈ*




អ្វីដែលគួរឱ្យកត់សម្គាល់ជាងនេះទៅទៀត កុំព្យូទ័រគឺជា ជំនាញមួយដែលចាំបាច់បំផុតសម្រាប់សិស្សនៅសតវត្សរ៍ទី ២១ ប៉ុន្តែ សិស្ស៨៩,៨ភាគរយ បានលើកឡើងថាពួកគេមិនដែលរៀនមុខវិជ្ជានេះទាល់តែសោះ ខណៈពេលដែលមិនមានអ្នកអនុវត្តណាម្នាក់លើកឡើងថាធ្លាប់បានអនុវត្ត។ ម៉្យាងវិញទៀត មានអ្នកអនុវត្តតិចតួចណាស់ដែលបាននិយាយថាមានថ្នាក់កុំព្យូទ័របានអនុវត្តនៅក្នុងសាលារៀនរបស់ពួកគេ ដូចបង្ហាញក្នុងរូបភាព៤.១១។ ការធ្លាក់ចុះនៃការអនុវត្តមុខវិជ្ជាកុំព្យូទ័រនៅតាមសាលារៀនបណ្តាលមកពីកង្វះសម្ភារៈបរិក្ខារ និងគ្រូឯកទេស។

*រូបភាព ៤.១១៖ ភាគរយបង្ហាញភាពញឹកញាប់ដែលនាយកឬនាយិកា គ្រូ និងសិស្សដែលបានអនុវត្តមុខវិជ្ជាកុំព្យូទ័រ*




## ៤.២.២.៥ វិធីសាស្ត្របង្រៀន

រហូតមកដល់ពេលនេះ ការអប់រំបំណិនជីវិតត្រូវបានអនុវត្តនៅតាមតំបន់មួយចំនួន ដែលបានតែមុខវិជ្ជាខ្លះៗតែប៉ុណ្ណោះ។ ពាក់ព័ន្ធនឹងតំបន់ដែលបានអនុវត្តនោះផងដែរ គ្រូ ១៤,៩ ភាគរយ បានរាយការណ៍ថាការបង្រៀនផ្តោតសំខាន់តែលើទ្រឹស្តី (ផ្អែកលើខ្លឹមសារជាគោល)។ គ្រូ ៣៨,៨ភាគរយ បានអះអាងថា ពួកគេអនុវត្តដោយប្រើទាំងទ្រឹស្តី និងការអនុវត្ត ដោយឡែកទ្រឹស្តីហាក់គ្របដណ្តប់បន្តិច ខណៈដែលគ្រូ ៤៧ភាគរយបានលើកឡើងថាការបង្រៀនតម្រូវឱ្យសិស្សអនុវត្តឱ្យបានច្រើនជាងទ្រឹស្តី ពោលគឺចំណេះដឹងត្រូវធ្វើឱ្យផ្សារភ្ជាប់នឹងការរស់នៅជាក់ស្តែង ដូចបង្ហាញក្នុងរូបភាព ៤.១២។ ស្ថិតិក៏បានបង្ហាញយ៉ាងច្បាស់លាស់ផងដែរទាក់ទងនឹងមុខវិជ្ជាដែលបានអនុវត្តច្រើនជាងទ្រឹស្តី។

*រូបភាព ៤.១២៖ ភាគរយបង្ហាញពីវិធីសាស្រ្តបង្រៀន (n=134)*




*រូបភាព ៤.១៣៖ ភាគរយបង្ហាញការបង្រៀនការអប់រំបំណិនជីវិត (បំណិនអាជីពងាយៗ)*




រូបភាព ៤.១៣ បានបង្ហាញថា គ្រូ ៤៣,៣ភាគរយ បានអះអាងថាពួកគេបានអោយសិស្សអនុវត្តច្រើនជាងអោយពួកគេរៀនតែទ្រឹស្តី។ គ្រូ ២០,៩ភាគរយ បានអះអាងថាពួកគេបានប្រើប្រាស់វិធីសាស្រ្តនោះសម្រាប់មុខវិជ្ជារោងជាង និងគេហវិទ្យា ហើយ ១៤,២ភាគរយ បាននិយាយថាពួកគេបានឱ្យសិស្សអនុវត្តច្រើនជាងការរៀនទ្រឹស្តីសម្រាប់មុខវិជ្ជាសិល្បៈ។

*៤.២.២.៦ ការរៀបចំគ្រូបង្រៀន*

ថ្មីៗនេះ សាលារៀនជាច្រើនកំពុងប្រឈមនឹងបញ្ហាកង្វះគ្រូ ជាពិសេសគ្រូបំណិនអាជីព ងាយៗ ខណៈដែលអ្នកចូលរួម ៨៤,៦ភាគរយអះអាងថាមិនមានគ្រូជំនាញទាំងនោះ ហើយ ១៥,៤ភាគរយ និយាយថាមានគ្រូជំនាញខ្លះ តែមិនគ្រប់គ្រាន់។ ជាក់ស្តែងមានតែមុខវិជ្ជាគេហវិទ្យាប៉ុណ្ណោះដែលត្រូវបានគេរាយការណ៍ថាមានគ្រូជំនាញ ខណៈដែលមុខវិជ្ជាដទៃមិនមាន។

*រូបភាព ៤.១៤៖ ភាគរយបង្ហាញគ្រូអប់រំបំណិនជីវិតដែលមាន*




ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ នាយកឬនាយិកាសាលា (៧៤ ភាគរយ) ដែលអះអាងថា មិនមានគ្រូជំនាញបានរាយការណ៍ថាពួកគាត់បានស្នើឱ្យគ្រូមុខវិជ្ជាផ្សេងទៀតឱ្យបង្រៀនជំនួស ហើយ ១៣,២ភាគរយ អះអាងថាបានជ្រើសរើសពីសហាគមន៍ដើម្បីជួយ (ដូចបង្ហាញក្នុងរូបភាព ៤.១៥)។ អ្នកចូលរួម ក៏បានបន្ថែមទៀតថាគ្រូដែលបង្រៀនជំនួសសម្រាប់មុខវិជ្ជាបំណិនជីវិត ភាគច្រើនជាគ្រូមុខវិជ្ជាវិទ្យាសាស្ត្រ ដូចជាជីវវិទ្យា គណិតវិទ្យា និងគីមីវិទ្យា (៧០ ភាគរយ) និង ៦៥ភាគរយបញ្ជាក់ថា ជាគ្រូបង្រៀនមុខវិជ្ជាសិក្សាសង្គមដូចជាអក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា ភូមិវិទ្យា និងភាសាអង់គ្លេស។ ទន្ទឹមនឹងនេះ ការគាំទ្រភាគច្រើនដែលបានពីសហាគមន៍មានត្រឹមតែជួយផ្តល់ការណែនាំក៏ដូចជាបទពិសោធន៍តិចតួចទាក់ទងនឹងកសិកម្មប៉ុណ្ណោះ។

*រូបភាព ៤.១៥៖ ភាគរយបង្ហាញការរៀបចំគ្រូបង្រៀនបំណិនជីវិត (ករណីកង្វះគ្រូ)*




លើសពីនេះទៅទៀត នាយកឬនាយិកាសាលាដែលអះអាងថាពួកគេមានគ្រូបំណិនជីវិតដែលមានគ្រូបំណិនតិចតួច បានបញ្ជាក់ថាពួកគាត់បានព្យាយាមដោះស្រាយបញ្ហានោះតាមដែលអាចធ្វើទៅបាន។ នាយកឬនាយិកាសាលា ២,៦ភាគរយ បានចាត់គ្រូដែលមានស្រាប់នៅក្នុងសាលាឱ្យបង្រៀន ហើយ ១៥,៦ភាគរយ បានដាក់គ្រូមុខវិជ្ជាផ្សេងឱ្យបង្រៀនជំនួស (ដូចបង្ហាញក្នុងរូបភាព ៤.១៦)។ តាមពិត គ្រូឯកទេសដែលមានស្រាប់មានតែគ្រូគេហវិទ្យាតែប៉ុណ្ណោះ ដូច្នេះគ្រូមុខវិជ្ជាផ្សេងទៀតដែលភាគច្រើនជាគ្រូបង្រៀនសិក្សាផ្នែកសង្គមត្រូវបានស្នើឱ្យជួយបង្រៀនជំនួស។

*រូបភាព ៤.១៦៖ ភាគរយបង្ហាញការរៀបចំគ្រូ (ករណីមានគ្រូមិនគ្រប់គ្រាន់)*




### *៤.២.២.៧ ការពិនិត្យតាមដាន និងវាយតម្លៃ*

ចាប់តាំងពីចាប់ផ្ដើមអនុវត្តការអប់រំបំណិនជីវិត អ្នកអនុវត្តបានលើកឡើងថាពួកគាត់ធ្លាប់ត្រូវបានពិនិត្យតាមដាន និងវាយតម្លៃតាមរយៈវិធីសាស្ត្រផ្សេងៗដោយអ្នកគាំទ្របច្ចេកទេស។ ក្នុងនោះ ថ្នាក់មន្ទីរ.អយក ៨៧.៥ភាគរយ បានអះអាងថាធ្លាប់បានទៅពិនិត្យតាមដាន និងវាយតម្លៃនៅសាលាដែលបានអនុវត្តកម្មវិធីបំណិនជីវិត រីឯថ្នាក់ការិយាល័យ.អយក (៤២,៩ភាគរយ) និងនាយកឬនាយិកា (៧៩,៥ភាគរយ) ដូចដែលបានឃើញក្នុងរូបភាព ៤.១៧។

*រូបភាព ៤.១៧៖ ភាគរយបង្ហាញពីការពិនិត្យតាមដាន និងវាយតម្លៃធ្វើឡើងដោយថ្នាក់មន្ទីរ.អយក ថ្នាក់ការិយាល័យ.អយក និងនាយកឬនាយិកាសាលា*




លើសពីនេះទៀតវិធីសាស្រ្តក្នុងការពិនិត្យតាមដាន និងវាយតម្លៃ ធ្វើឡើងខុសៗគ្នា។ ថ្នាក់មន្ទីរ.អយក ២៥ភាគរយ ថ្នាក់ការិយាល័យ.អយក ១០,៧ភាគរយ និងនាយកឬនាយិកា ៤៣,៦ ភាគរយមានប្រើឧបករណ៍ពិនិត្យតាមដាននិងវាយតម្លៃ។រូបភាព៤.១៨បានបង្ហាញថាភាគច្រើននៃថ្នាក់មន្ទីរ.អយក (៣៧,៥ភាគរយ) បានប្រើវិធីសាស្រ្តផ្សេងទៀត ពោលគឺសង្កេតការអនុវត្ត

ជាក់ស្តែងនៅតាមសាលារៀន ដូចគ្នានឹង ថ្នាក់ការិយាល័យ.អយក (១៧,៩ភាគរយ)។ នៅកម្រិតសាលា នាយកឬនាយិកា ៤៣,៦ភាគរយ បានរាយការណ៍ថាប្រើប្រាស់ឧបករណ៍សង្កេតជាក់លាក់។

*រូបភាព ៤.១៨៖ ភាគរយបង្ហាញវិធីសាស្រ្តក្នុងការពិនិត្យតាមដាន និងវាយតម្លៃ*




ម្យ៉ាងវិញទៀត គ្រូក៏ត្រូវបានរាប់បញ្ចូលក្នុងការវិភាគនេះដើម្បីធ្វើរបាយការណ៍ស្តីពីការពិនិត្យតាមដាន និងវាយតម្លៃដែលបានធ្វើដោយអ្នកគាំទ្រខាងក្រៅ (ឧ- ថ្នាក់មន្ទីរ.អយក និង ថ្នាក់ការិយាល័យ.អយក) និងអ្នកគាំទ្រផ្ទៃក្នុង (ឧ. នាយកឬនាយិកា) និងជាពិសេសការពិនិត្យ

តាមដាន និងវាយតម្លៃទៅលើសិស្ស។ គ្រូបានរាយការណ៍ថា ភាគច្រើនត្រូវបានគេរាយការណ៍




ក្រៅពីនេះ គ្រូ ៧៦ភាគរយ នៅក្នុងការសិក្សានេះបានអះអាងថាពួកគាត់បានតាមដាន និង វាយតម្លៃសិស្សដែលកំពុងរៀនមុខវិជ្ជាបំណិនជីវិត ពោលគឺបំណិនអាជីពងាយៗ។ បន្ទាប់ពីនោះ គ្រូ ៦៩,២ភាគរយ បានលើកឡើងថាពួកគេបានរៀបចំតេស្តផ្ទាល់ខ្លួនដើម្បីវាយតម្លៃសិស្សជា

រៀងរាល់ខែ ៥,៣ភាគរយបាននិយាយថាពួកគាត់បានសង្កេតនិងវាយតម្លៃដោយមើលតាមការប្រព្រឹត្តជាក់ស្តែងក្នុងថ្នាក់ ហើយ ១,៥ភាគរយបាននិយាយថាពួកគាត់ប្រើប្រាស់ឧបករណ៍ដើម្បីវាយតម្លៃសិស្ស សូមមើលរូបភាព ៤.២០។

*រូបភាព ៤.២០៖ ភាគរយបង្ហាញវិធីសាស្ត្រពិនិត្យតាមដាន និងវាយតម្លៃដែលបានប្រើសម្រាប់សិស្ស*




*៤.២.២.៨ ការយល់ឃើញចំពោះការរៀនការអប់រំបំណិនជីវិតតាមមូលដ្ឋាន*

ស្ថិតិពណ៌នាបានបង្ហាញថា ការអប់រំបំណិនជីវិតដែលបានអនុវត្តហាក់ផ្តល់ផលវិជ្ជមានច្រើនផ្នែកតាមរបាយការណ៍ពីអ្នកអនុវត្ត។ រូបភាព ៤.២១ បង្ហាញពីវឌ្ឍនភាពនៃសិក្សាបំណិន

ជីវិតតាមមូលដ្ឋានដែលរាយការណ៍ដោយមន្ទីរ.អយក ការិយាល័យ.អយក សាលារៀន (នាយក នាយិកាសាលា និងគ្រូ)។ អ្នកចូលរួមបានរាយការណ៍ថាបំណិនជីវិតតាមមូលដ្ឋានដែលបាន អនុវត្តនៅតាមសាលារៀន បានជួយសិស្សទាំងអស់ឱ្យមានភាពប្រសើរឡើង ដោយសង្កេត ឃើញថា ពួកគេយល់ពីខ្លឹមសារមេរៀន និងបានយកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃបានយ៉ាងល្អ ជាពិសេសកសិកម្ម (= ៣,៨១, SD = ១,៦) និងគេហវិទ្យា ( = ៣,៨២, SD = ១,៥)។

*រូបភាព ៤.២១៖ ភាគរយនៃការយល់ឃើញចំពោះការរៀនការអប់រំបំណិនជីវិតតាមមូលដ្ឋាន*




*៤.២.២.៩ ភាពឆ្លើយតបក្នុងការអនុវត្ត*

ស្ថិតិពិពណ៌នាខាងក្រោម បង្ហាញពីលទ្ធផលរបស់អ្នកចូលរួមដែលបានរាយការណ៍អំពី ការឆ្លើយតបនៃការអនុវត្តការអប់រំបំណិនជីវិតនៅមធ្យមសិក្សាបឋមភូមិកន្លងមក ទៅនឹងសេចក្តី ណែនាំរបស់ក្រសួង. អយក (n = ២១៤) និងតម្រូវការមូលដ្ឋាន (n = ៥៥៩)។ បើនិយាយអំពីការ ឆ្លើយតបនៃការអនុវត្តការអប់រំបំណិនជីវិតនៅមធ្យមសិក្សាបឋមភូមិកន្លងមក ទៅនឹងសេចក្តី

ណែនាំរបស់ក្រសួង.អយក លទ្ធផលដែលបានមកបានកំណត់ចម្លើយចេញជា៥ប្រភេទ គឺ (១) មិនឆ្លើយតបទាល់តែសោះ (១២,១ភាគរយ) (២)ឆ្លើយតបតិចតួច (៣៩,៧ភាគរយ) (៣)ឆ្លើយតបមធ្យម (៣៣,២ភាគរយ) (៤)ឆ្លើយតបភាគច្រើន (១៤ភាគរយ)និង(៥)ឆ្លើយតបទាំងស្រុង (០,៩ភាគរយ)។ រូបភាព ៤.២២ បានបង្ហាញថាអ្នកចូលរួមភាគច្រើន (៣៩,៧ភាគរយ) បានអះអាងថាការអនុវត្តនៃការអប់រំបំណិនជីវិតមានភាពឆ្លើយតបតិចតួចបំផុតទៅនឹងគោលការណ៍ណែនាំ ឬការរំពឹងទុករបស់ក្រសួង។

*រូបភាព ៤.២២៖ ភាគរយនៃការអនុវត្តការអប់រំបំណិនជីវិតឆ្លើយតបនឹងសេចក្តីណែនាំ របស់*




បន្ទាប់ពីនោះមក នេះគឺជាលទ្ធផលនៃការឆ្លើយតបចំពោះតម្រូវការមូលដ្ឋាន។ ភាគរយអ្នកចូលរួមយ៉ាងច្រើន (៣៥,១ភាគរយ) បានអះអាងថាការអនុវត្តការអប់រំបំណិនជីវិតកន្លងមកឆ្លើយតបនឹងតម្រូវការមូលដ្ឋានខ្លះៗតែប៉ុណ្ណោះ ដូចបានបង្ហាញក្នុងរូបភាព ៤.២៣។

*រូបភាព ៤.២៣៖ ភាគរយនៃការអនុវត្តការអប់រំបំណិនជីវិតឆ្លើយតបនឹងតម្រូវការមូលដ្ឋាន*




### *៤.២.២.១០ ការសហការគាំទ្រ*

ជាក់ស្តែង ការអនុវត្តការអប់រំបំណិនជីវិត ត្រូវការការគាំទ្រជាច្រើនពីអ្នកពាក់ព័ន្ធដើម្បីចូលរួមចំណែកធ្វើឱ្យរចនាសម្ព័ន្ធអនុវត្តប្រកបដោយចីរភាព។ ដូច្នេះអ្នកគាំទ្រខាងក្រៅ (ថ្នាក់មន្ទីរ.អយក និងថ្នាក់ការិយាល័យ.អយក ) អ្នកគាំទ្រខាងក្នុង (នាយកសាលា) អ្នកអនុវត្ត (គ្រូ) និងអ្នកគាំទ្របន្ថែមតាមមូលដ្ឋាន (អាជ្ញាធរមូលដ្ឋាន និង អាណាព្យាបាល) ត្រូវបានរាប់បញ្ចូលក្នុងការវិភាគនៃការសិក្សានេះ ហើយលទ្ធផលត្រូវបានបង្ហាញដូចខាងក្រោម។

រូបភាព៤.២៤បង្ហាញពីការគាំទ្រសហការរវាងថ្នាក់មន្ទីរ.អយកជាមួយអ្នកស្ម័គ្រចិត្តផ្សេងៗសម្រាប់ការគាំទ្រផ្សេងៗគ្នាក្នុងកំឡុងពេលអនុវត្តការអប់រំបំណិនជីវិត។ ការវិភាគក្នុងការសិក្សានេះ ផ្តោតជាចម្បងលើអ្នកចូលរួមដែលបានរាយការណ៍ថា ធ្លាប់អនុវត្តការអប់រំបំណិនជីវិតនៅក្នុងតំបន់របស់ពួកគេ។ លទ្ធផលបានបង្ហាញថាចំនួនអ្នកចូលរួមពីថ្នាក់មន្ទីរ.អយក ភាគតិចបំផុតបានរាយការណ៍ថាបានធ្វើការជាមួយអ្នកពាក់ព័ន្ធ (ឧ-អាណាព្យាបាល គណៈកម្មការទ្រទ្រង់ និងដៃគូអភិវឌ្ឍន៍) ក្នុងការតាមដានដំណើរការនៃការអនុវត្តការអប់រំបំណិនជីវិត។ សម្រាប់ជំនួយ

បច្ចេកទេសបន្ថែម ភាគច្រើននៃថ្នាក់មន្ទីរ.អយក បានអះអាងថាពួកគេបានសហការជាមួយ ថ្នាក់ក្រសួង នាយកឬនាយិកាសាលា និង ដៃគូអភិវឌ្ឍន៍ ប៉ុន្តែមានតែ ២៥ ភាគរយប៉ុណ្ណោះដែលអះអាងថា នឹងសហការជាមួយ ថ្នាក់ការិយាល័យ.អយក គណៈកម្មការទ្រទ្រង់ អាជ្ញាធរមូលដ្ឋាន និងអាណាព្យាបាល។ ទាក់ទងនឹងការគាំទ្រផ្នែកសម្ភារៈ ថ្នាក់ការិយាល័យ.អយក (៥០ភាគរយ) បានរាយការណ៍ថាដើម្បីសហការជាមួយគណៈកម្មការទ្រទ្រង់ ដើម្បីចូលរួមវិភាគទានឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ខណៈដែលការចូលរួមរបស់អ្នកដទៃនៅតែជាបញ្ហា។ សម្រាប់ការលើកទឹកចិត្តផ្សេងៗ (ការគាំទ្រផ្នែកថវិកា) ការចូលរួមរវាង ថ្នាក់មន្ទីរ.អយក ជាមួយនឹងអ្នកពាក់ព័ន្ធសំខាន់ៗនៅតែជាបញ្ហាប្រឈម។

*រូបភាព ៤.២៤៖ ភាគរយនៃការសហការគាំទ្ររវាង ថ្នាក់មន្ទីរ.អយក និងអ្នកពាក់ព័ន្ធ*



បន្ទាប់មក ស្ថិតិបានបង្ហាញថាកិច្ចសហការរវាងថ្នាក់ការិយាល័យ.អយក និងអ្នកពាក់ព័ន្ធផ្សេងៗនៅតែជាបញ្ហាប្រឈមទាក់ទងនឹងដំណើរការពិនិត្យតាមដាន ការគាំទ្របច្ចេកទេសការគាំទ្រផ្នែកសម្ភារៈ និងការលើកទឹកចិត្ត ដូចបានឃើញក្នុងរូបភាព ៤.២៥។

*រូបភាព ៤.២៥៖ ភាគរយការសហការគាំទ្ររវាង ថ្នាក់ការិយាល័យ.អយក និងអ្នកពាក់ព័ន្ធ*



បើក្រឡេកទៅមើលអ្នកគាំទ្រផ្ទៃក្នុងដូចជានាយកឬនាយិកាសាលា ក៏ត្រូវបានរាប់បញ្ចូលផងដែរ ដើម្បីសង្កេតមើលអ្នកពាក់ព័ន្ធដែលបានសហការជាមួយនាយកឬនាយិកាសាលាដើម្បីទ្រទ្រង់ការអនុវត្តការអប់រំបំណិនជីវិត។ រូបភាព ៤.២៦ បង្ហាញថាមាននាយកឬនាយិកាសាលាតិចណាស់ដែលបានរាយការណ៍ថា បានសហការ ឬទទួលជំនួយនានាពីអ្នកពាក់ព័ន្ធដូចខាងក្រោម។ បញ្ហានេះអាចធ្វើឱ្យប៉ះពាល់ដល់វឌ្ឍនភាពនៃការអនុវត្តការអប់រំបំណិនជីវិតនៅតាមសាលារៀន។

*រូបភាព ៤.២៦៖ ភាគរយការសហការគាំទ្ររវាង នាយកឬនាយិកាសាលា និងអ្នកពាក់ព័ន្ធ*



គណៈកម្មការទ្រទ្រង់សាលា ក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់សាលារៀន ដើម្បីលើកកម្ពស់ការអនុវត្តការអប់រំបំណិនជីវិត។ រូបភាព ៤.២៧ បានបង្ហាញថាគណៈកម្មការទ្រទ្រង់សាលាភាគច្រើន (៨២,១ភាគរយ) បានរាយការណ៍ថាបានធ្វើការយ៉ាងជិតស្និទ្ធជាមួយនាយកឬនាយិកាសាលា ទាក់ទងនឹងការពិនិត្យតាមដាន ការគាំទ្រផ្នែកបច្ចេកទេស ផ្នែកសម្ភារៈ និងលើកទឹកចិត្ត។ទន្ទឹមនឹងនោះដៃគូអភិវឌ្ឍន៍អាជ្ញាធរមូលដ្ឋាន និងអាណាព្យាបាលក៏បានជួយសហការនៅក្នុងការគាំទ្រទាំងនោះដែរ ខណៈដែលការសហការជាមួយថ្នាក់ខេត្ត និងក្រសួងនៅតែស្ថិតក្នុងការពិចារណា។

*រូបភាព ៤.២៧៖ ភាគរយការសហការគាំទ្ររវាង គណៈកម្មការទ្រទ្រង់សាលា និងអ្នកពាក់ព័ន្ធ*



នៅកម្រិតសាលា គ្រូបង្រៀន គឺជាអ្នកអនុវត្តផ្ទាល់តែម្តង។ ដូច្នេះ ការវិភាគនេះធ្វើឡើងដើម្បីសង្កេត និងពិនិត្យឡើងវិញនូវចម្លើយរបស់អ្នកពាក់ព័ន្ធដែលបានសហការជាមួយគ្រូអំឡុងពេលអនុវត្តដើម្បីគាំទ្រ និងជំរុញការអនុវត្តការអប់រំបំណិនជីវិត។ រូបភាព ៤.២៨ បានបង្ហាញថា គ្រូភាគច្រើន (៣៥,៩ភាគរយ) បានអះអាងថាបានធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងនាយកឬនាយិកាសាលាទាក់ទងនឹងការពិនិត្យតាមដាន ស្វែងរកការគាំទ្រផ្នែកបច្ចេកទេស (៣២,៤ភាគរយ) ប្រមូល និងចែកចាយសម្ភារៈសម្រាប់បង្រៀន និងរៀន (៤៣,៧ភាគរយ) និងពិភាក្សានិងស្នើសុំសម្រាប់ការគាំទ្រលើកទឹកចិត្តបន្ថែម (២៦,៨ភាគរយ)។ ភាគរយដែលបានរកឃើញភាគច្រើនផ្តោតខ្លាំងទៅលើការគាំទ្រផ្នែកសម្ភារៈ។ ទោះជាយ៉ាងណា ពាក់ព័ន្ធនឹងការ គាំទ្រពីសំណាក់អ្នកពាក់ព័ន្ធបានបង្ហាញថានៅមានភាពខ្វះខាតនៅឡើយ។

*រូបភាព ៤.២៨៖ ភាគរយការសហការគាំទ្ររវាង គ្រូ និងអ្នកពាក់ព័ន្ធ*



អាជ្ញាធរមូលដ្ឋានគឺជាជំនួយការបន្ថែមក្នុងការជំរុញការអនុវត្តការអប់រំបំណិនជីវិត។ ដូច្នេះ ពួកគាត់ត្រូវបានគេអះអាងថាត្រូវចូលរួមជាមួយនឹងអ្នកពាក់ព័ន្ធ។ រូបភាព ៤.២៩ បង្ហាញពីភាគរយនៃការគាំទ្រសហការនានារវាងអ្នកពាក់ព័ន្ធ។ អាជ្ញាធរមូលដ្ឋានភាគច្រើន បានអះអាងថា បានសហការជាមួយនាយកឬនាយិកាសាលាក្នុងការពិនិត្យតាមដាននិងការគាំទ្រផ្នែកសម្ភារៈ។ ពួកគាត់ក៏បានរាយការណ៍ផងដែរថាពួកគាត់ធ្លាប់បានសហការជាមួយ ថ្នាក់ការិយាល័យ.អយក ដើម្បីជួយផ្ដល់ការគាំទ្រផ្នែកបច្ចេកទេស ហើយការគាំទ្រលើកទឹកចិត្តភាគច្រើនត្រូវបានគេរាយការណ៍ថាបានធ្វើការរួមគ្នាជាមួយ នាយកឬនាយកសាលា ដៃគូអភិវឌ្ឍន៍ និងអាណាព្យាបាល។

*រូបភាព ៤.២៩៖ ភាគរយការសហការគាំទ្ររវាង អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ*



បើក្រឡេកទៅមើលខាងអាណាព្យាបាលវិញឃើញថាពួកគាត់ គឺជាតួអង្គមួយដែលត្រូវចូលរួមយ៉ាងជិតស្និទ្ធជាមួយអ្នកទទួលផលពោលគឺសិស្ស ហើយក៏ត្រូវចូលរួមចំណែកខ្លះដែរដើម្បីភាពជោគជ័យក្នុងការរៀនសូត្ររបស់សិស្សតាមរយៈការជួយគាំទ្រផ្សេងៗ។ ជាការពិតណាស់ ការវិភាគនេះផ្តោតលើអ្នកផ្តល់សេវា (នៅកម្រិតសាលា) និងអ្នកគាំទ្របន្ថែម (អាណាព្យាបាល)។ រូបភាព ៤.៣០ បានបង្ហាញថា អាណាព្យាបាលប្រហែលជា ៥៩ភាគរយ បាននិយាយថា ពួកគេបានសហការជាមួយនាយកឬនាយិកាសាលាដើម្បីតាមដានការអនុវត្តកម្មវិធីតាមរយៈលទ្ធផលសិក្សារបស់សិស្ស ដែលបានរាយការណ៍នៅក្នុងសៀវភៅតាមដានការសិក្សា ហើយ ២៩ភាគរយ បានរាយការណ៍ថាបានជួយពិភាក្សា និងជួយស្វែងរកជំនួយលើកទឹកចិត្តគ្រូឲ្យបង្រៀនដោយក្តីរីករាយ។ ឯ ២១ភាគរយទៀត បានរាយការណ៍ថាបានជួយស្វែងរកការគាំទ្រផ្នែកសម្ភារៈសម្រាប់ការបង្រៀននិងការអនុវត្ត ហើយ ១៥ភាគរយ បានរាយការណ៍ថាបានជួយរកជំនួយផ្នែកបច្ចេកទេស ពោលគឺការជ្រើសរើសអ្នកជំនាញពីក្នុងមូលដ្ឋានសម្រាប់បំណិនជីវិតអាជីពងាយៗ ឬផ្តល់ជំនួយដោយខ្លួនឯងផ្ទាល់ឱ្យអស់ពីលទ្ធភាព។

*រូបភាព ៤.៣០៖ ភាគរយការសហការគាំទ្ររវាង អាណាព្យាបាល និងនាយក ឬនាយិកា សាលា*



### ៤.២.៣ សេចក្ដីសង្ខេបបញ្ហាប្រឈមទាក់ទងនឹងការអប់រំបំណិនជីវិតនាពេលបច្ចុប្បន្ន

ដោយអនុលោមទៅតាមទិន្នន័យស្ថិតិខាងលើ បញ្ហាប្រឈមមួយចំនួននៅតែបន្តកើតឡើងអំឡុងពេលអនុវត្ត។ ក្នុងពេលដំណាលគ្នានេះដែរ ការអនុវត្តត្រូវបានលើកឡើងថាមិនទាន់សម្រេចបានតាមសេចក្ដីណែនាំរបស់ ក្រសួង.អយក និងតម្រូវការតាមមូលដ្ឋានឱ្យបានត្រឹមត្រូវនៅឡើយ សូមមើលលម្អិតនៅក្នុង ៤.២.២។ ជាក់ស្ដែង ភាគរយនៃអ្នកចូលរួមដែលបានរាយការណ៍ថាធ្លាប់បានដឹងអំពីការអប់រំបំណិនជីវិតហាក់នៅមានកម្រិតនៅឡើយ (ដូចបានឃើញក្នុងរូបភាព ៤.១)។ ក្នុងចំណោមអ្នកឆ្លើយសំណួរដែលរាយការណ៍ថាមិនទាន់ធ្លាប់បានដឹងគឺភាគច្រើននៅកម្រិតសាលាដូចជា នាយកឬនាយិកាសាលាផ្ទាល់ គណៈកម្មការទ្រទ្រង់សាលា គ្រូ សិស្ស អាណាព្យាបាល និងអាជ្ញាធរមូលដ្ឋាន ហើយចំណុចដែលបានរាយការថាធ្លាប់ដឹងគឺជំនាញយល់ដឹងផ្នែកសង្គម។ លទ្ធផលនេះទំនងជាបញ្ជាក់ថាព័ត៌មាន គោលការណ៍ ឬការណែនាំនានាមិនបានទៅដល់ពួកគេគ្រប់ជ្រុងជ្រោយឡើយ ជាពិសេសអ្នកអនុវត្តផ្ទាល់តែម្តង។ ភាគច្រើននៃអ្នកចូលរួម បានរាយការណ៍ថាបានអនុវត្តបំណិនជីវិតផ្សេងៗគ្នានៅក្នុងសាលារៀន និងមូលដ្ឋានរបស់ពួកគេ។ តែទោះយ៉ាងណាក៏មុខវិជ្ជានៃបំណិនអាជីពងាយៗចំនួនបី ដូចជា កុំព្យូទ័រ រោងជាង និងសិល្បៈនៅតែមិនទាន់បានអនុវត្តពេញលេញ និងទូលំទូលាយ ដូចដែលបានរៀបរាប់លម្អិតនៅក្នុងតារាង ៤.២ និង ៤.៣។ ស្របគ្នានេះ បញ្ហាដែលប៉ះពាល់ដល់ភាពខ្វះចន្លោះក្នុងការអនុវត្តមុខវិជ្ជាទាំងនោះ ត្រូវបានគេរាយការណ៍ថាដោយសារតែខ្វះការគាំទ្រ និងការយកចិត្តទុកដាក់។ បញ្ហាទាំងនោះក៏ផ្ដោតបន្ថែមទៀតលើគ្រូដែលមិនទាន់មានជំនាញគ្រប់គ្រាន់ ដូច្នេះគ្រូមុខវិជ្ជាផ្សេងទៀតដូចជា គ្រូបង្រៀនវិទ្យាសាស្ត្រសង្គមត្រូវបានដាក់ឱ្យជួយបង្រៀនជំនួស។ មានអ្នកចូលរួមជាច្រើនប្រភេទ បានបង្ហាញពីកង្វះផ្នែកសម្ភារៈ និងបរិក្ខារបង្រៀន។ ដូច្នេះ វាធ្វើឱ្យគុណភាពនៃការរៀនសូត្រហាក់មិនអាចធានាបានទេ ខណៈដែលការបង្រៀនត្រូវផ្សាភ្ជាប់ជាមួយនឹងការអនុវត្តជាក់ស្ដែង។ ទន្ទឹមនឹងនេះ ការសហការគាំទ្រពីអ្នកពាក់ព័ន្ធនៅតែត្រូវបានមើលរំលង។ ការរកឃើញបានពីការសិក្សាបានបង្ហាញថាកិច្ចសហការរវាងអ្នកគាំទ្រពីខាងក្រៅ (ថ្នាក់មន្ទីរ.អយក និង ថ្នាក់ការិយាល័យ.អយក) ជាមួយអ្នកពាក់ព័ន្ធនៅតែជាបញ្ហាព្រួយបារម្ភជាពិសេសជាមួយអ្នកពាក់ព័ន្ធនៅកម្រិតសាលា (នាយកឬនាយិកាសាលា និងគ្រូ) ទាក់ទងនឹងការពិនិត្យតាមដាន ការគាំទ្រផ្នែកសម្ភារៈ និងការលើកទឹកចិត្តនានា។ លទ្ធផលនៃការសិក្សា ក៏បានបញ្ជាក់បន្ថែមទៀតថា ការចូលរួមរវាងកម្រិតសាលារៀនជាមួយនឹងសហគមន៍ ក្នុងការរួមចំណែកធ្វើឱ្យការអនុវត្តការអប់រំបំណិនជីវិតមានការប្រសើរឡើងមានលម្អិតក្នុង

ផ្នែក ៤.២.២.៩។ លើសពីនេះទៅទៀត ការស្រាវជ្រាវបានបញ្ជាក់ថាការពិនិត្យនិងវាយតម្លៃហាក់នៅមិនទាន់មានលក្ខណៈជាប្រព័ន្ធនៅឡើយនោះទេ។ ថ្នាក់មន្ទីរ.អយក និងថ្នាក់ការិយាល័យ.អយក ភាគច្រើនបានសង្កេតដោយផ្អែកលើការអនុវត្តជាក់ស្តែងនៅក្នុងសាលា រីឯនាយក ឬនាយិកាសាលា បានប្រើប្រាស់ឧបករណ៍ជាក់លាក់ក្នុងការពិនិត្យតាមដាន ដូចបានបញ្ជាក់នៅក្នុងផ្នែក ៤.២.២.៧។ ទោះយ៉ាងណា គ្រូបានរាយការណ៍ថាមិនដែលឃើញមានការចូលរួមតាមដាន និងវាយតម្លៃលើការអនុវត្តការអប់រំបំណិនជីវិតពីសំណាក់ថ្នាក់មន្ទីរ.អយក និងថ្នាក់ការិយាល័យ.អយកឡើយ ហើយនាយកឬនាយិកាសាលាត្រូវបានរាយការណ៍ថាបានអនុវត្តសកម្មភាពនោះតាមរយៈការវាយតម្លៃរបស់គ្រូខ្លួនឯង។ មិនដែលបានបង្កើតការប្រជុំពិភាក្សាណាមួយស្តីពីការអប់រំបំណិនជីវិតជាក់លាក់។ ជាក់ស្តែង ផែនការសកម្មភាពសម្រាប់ការអនុវត្តការអប់រំបំណិនជីវិតត្រូវបានលើកឡើងថា មិនដែលបានធ្វើឡើងដោយសារតែហេតុផលមួយចំនួនជាអាទិ៍ កង្វះជំនាញ និងសមត្ថភាពក្នុងការធ្វើវា (ពោលគឺ កង្វះការណែនាំផ្នែកបច្ចេកទេសទាក់ទងនឹងបញ្ហានេះ) កង្វះការចូលរួម និងការយកចិត្តទុកដាក់ កង្វះថវិកានិងការគាំទ្រផ្នែកសម្ភារៈ និងបញ្ហាពេលវេលា។ ទាំងនោះជាហេតុធ្វើឱ្យបញ្ហាប្រឈមនៅតែបន្តកើតមាន។

## ៤.៣ មុខវិជ្ជាបំណិនជីវិតដែលជាតម្រូវការ

បន្ទាប់ពីបញ្ហាប្រឈមដែលបានលើកឡើងនៅ ៤.២.៣ សំណួរស្រាវជ្រាវទីពីបានរកឃើញថា បំណិនជីវិតចាំបាច់ឆ្លើយតបទៅនឹងមូលដ្ឋានផ្សេងៗជាច្រើន។ ចម្លើយសម្រាប់សំណួរនេះភាគច្រើនវិភាគពឹងផ្អែកលើស្ថិតិពណ៌នា ខណៈដែលលទ្ធផលត្រូវបានបង្ហាញជាលក្ខណៈរួម និងដោយឡែកពីគ្នា។ ស្ថិតិបានបង្ហាញថាប្រហែលជា ៩៩ភាគរយនៃអ្នកចូលរួមបានបញ្ជាក់ថាការអប់រំបំណិនជីវិតពិតមានអត្ថប្រយោជន៍ខ្លាំងណាស់សម្រាប់អ្នកសិក្សាទាំងអស់ ហើយក៏អាចរួមចំណែកក្នុងការគាំទ្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់ម្នាក់ៗក៏ដូចជាមានឥទ្ធិពលវិជ្ជមានទៅលើគ្រួសារ សាលារៀន និងសហគមន៍។

*រូបភាព ៤.៣១៖ ភាគរយបង្ហាញការយល់ឃើញរបស់អ្នកចូលរួមចំពោះផលសម្រេចនៃការអប់រំបំណិនជីវិត*




គួររំលឹកផងដែរថា មាត្រដ្ឋានសម្រាប់ការវិភាគនេះត្រូវបានបែងចែកជា ៥ ចំណុច៖ ១) មិនចាំបាច់ទាល់តែសោះ ២) មិនចាំបាច់តិចតួច ៣) ចាំបាច់ ៤) ចាំបាច់បំផុត និង ៥) ចាំបាច់បំផុត។ ទិន្នន័យស្ថិតិបានបង្ហាញថា កុំព្យូទ័រជាជំនាញដែលចាំបាច់បំផុត (= ៤,១ និង SD[8] = ១,១) ក្នុងចំណោមបំណិនជីវិតដទៃទៀត។ បំណិនបន្ទាប់គឺ កសិកម្ម និងគេហវិទ្យា ( = ៣,៧, SD= ១,១) រោងជាង (= ៣,១, SD = ១,២) សិល្បៈ ( = ៣,០, SD = ១,១) ក៏ត្រូវបានលើកឡើងថាចាំបាច់ខ្លាំងណាស់ដែរសម្រាប់សិស្សនៅក្នុងមូលដ្ឋានរបស់ពួកគេ  ប៉ុន្តែក្រៅពីបំណិនដែលបានលើកឡើងខាងលើត្រូវបានគេបង្ហាញថាមិនសូវមានតម្រូវការ។  ទាំងនេះគឺជាបំណិនដែលត្រូវការចាំបាច់ដែលសិស្សបានឆ្លើយ (សូមមើលរូបភាព ៤.៣២)។

8 SD = Standard Deviation គន្លាតស្តង់ដា

*រូបភាព ៤.៣២៖ មុខវិជ្ជាបំណិនជីវិតដែលជាតម្រូវការ (បំណិនអាជីពងាយៗ) នៅកម្រិតមធ្យមសិក្សាបឋមភូមិ*




សម្រាប់ព័ត៌មានលម្អិតបន្ថែម រូបភាព ៤.៣៣ បង្ហាញពីបំណិនអាជីពងាយៗដែលមានអ្នកចូលរួមផ្សេងៗជាច្រើនបញ្ជាក់ថាពិតជាចាំបាច់។ ក្នុងនោះ លោកគ្រូ-អ្នកគ្រូជាច្រើន (១៤,៧ភាគរយ) បង្ហាញថាមុខវិជ្ជាកុំព្យូទ័រពិតជាចាំបាច់ណាស់ ចំណែកឯ កសិកម្ម (១២,៧ភាគរយ) គេហវិទ្យា (១៣,៤ភាគរយ) និងសិល្បៈ (១០,៣ភាគរយ) ត្រូវបានសិស្សយល់ថាពិតជាចាំបាច់ណាស់។ លោកគ្រូ-អ្នកគ្រូ (៩,៦ភាគរយ) បង្ហាញថាពិតជាចាំបាច់ណាស់។ ដោយឡែក សិស្ស (៥២.៥ភាគរយ)លើកឡើងថាបំណិនផ្សេងទៀតមិនសូវជាចាំបាច់ទេ។

*រូបភាព ៤.៣៣៖ ភាគរយបង្ហាញមុខវិជ្ជាបំណិនជីវិតដែលជាតម្រូវការ (បំណិនអាជីពងាយៗ) ដោយអ្នកចូលរួមផ្សេងៗ*




ទិន្នន័យបែបគុណវិស័យ បានបញ្ជាក់យ៉ាងលម្អិតបន្ថែមពីលើទិន្នន័យស្ថិតិទាក់ទងនឹងតម្រូវការមុខវិជ្ជាបំណិនជីវិតផ្សេងៗ។ ជាការពិតណាស់ បំណិនអាជីពងាយៗ ដូចជាកុំព្យូទ័រ កសិកម្ម រោងជាង គេហវិទ្យា សិល្បៈ និងបំណិនផ្សេងៗទៀត ដែលបាននឹងកំពុងអនុវត្តនៅ

តាមសាលារៀនហាក់ពុំទាន់មានលទ្ធផលឆ្លើយតបបានល្អនៅឡើយទេ។ ដូច្នេះលទ្ធផលនៃការសិក្សានេះ បានបង្ហាញពីបំណិនដែលចាំបាច់ ដើម្បីឆ្លើយតបនឹងតម្រូវការតាមមូលដ្ឋាន។ ជាបឋម បំណិនកុំព្យូទ័រដើរតួយ៉ាងសំខាន់ក្នុងការជំរុញអ្នកសិក្សាឱ្យចូលរួមក្នុងសង្គមសិក្សានៅសតវត្សរ៍ទី ២១ និងរួមចំណែកដល់ការសម្រេចបាននូវគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ខណៈការយល់ដឹងអំពីបច្ចេកវិទ្យាជាស្នូលនៃឧស្សាហកម្ម ៤.០។ ហេតុដូច្នេះហើយ អ្នកសិក្សាទាំងអស់គួរតែត្រូវបានបំពាក់ដោយជំនាញបែបនេះ យ៉ាងហោចណាស់កម្រិតមូលដ្ឋាន (ឧ. កម្មវិធី Ms Word Excel អ៊ីនធឺណិត អ៊ីម៉ែល។ល។ )។ ដោយសារប្រជាជនកម្ពុជា ជាពិសេសអ្នកនៅតាមទីជនបទ ពឹងផ្អែកជាចម្បងលើវិស័យកសិកម្ម ដូច្នេះហើយបានជាអ្នកចូលរួមជាច្រើនបានស្នើឱ្យមានប្រធានបទមួយចំនួនដើម្បីដាក់បញ្ចូលដូចជា ការដាំដំណាំ ផ្លែឈើ និងបន្លែ (ឧ.ស្រូវ ពោត ដំឡូង ស្ពៃ ត្រកួន ស្ពៃក្ដោបជាដើម) ការផលិតជីធម្មជាតិ និងបច្ចេកទេសចិញ្ចឹមសត្វក្នុងកសិដ្ឋាន។ លើសពីនេះទៅទៀត មុខវិជ្ជារោងជាងក៏តម្រូវឱ្យមានប្រធានបទចាំបាច់មួយចំនួនដូច ជាងឈើ ជាងចម្លាក់ និងជួសជុលគ្រឿងសង្ហារឹម (តុ កៅអី គ្រែ អំបោស ធ្មើដាក់សៀវភៅ និងវត្ថុសាមញ្ញៗ ផ្សេងទៀត) មេកានិច និងជួសជុលខ្នាតតូច។ គេហវិទ្យា គឺជាជំនាញវិជ្ជាជីវៈដ៏សាមញ្ញមួយដែលមិនអាចខ្វះបាន ជាពិសេសសម្រាប់សិស្សស្រីដែលជាជំនួយនិងទ្រទ្រង់ជីវិតប្រចាំថ្ងៃ។ ប្រធានបទដែលពួកគេទទួចចង់មានដូចជា ដេរប៉ាក់ ការចម្អិន ការថែទាំសុខភាព តម្បាញ បត់ក្រដាស និងកាត់ដេរ។ សិល្បៈក៏ជាជំនាញចាំបាច់ដែលសិស្សត្រូវចាប់យក និងបំពាក់ជាមូលដ្ឋាន។ ប្រធានបទគួរតែបំពេញតាមបំណងប្រាថ្នារបស់អ្នកចូលរួម ដូច្នេះលទ្ធផលនៃការសិក្សាបានបង្ហាញថាអ្នកចូលរួមភាគច្រើនចង់ឱ្យបញ្ចូលប្រធានបទ ដូចជាការស្គាល់ឧបករណ៍ភ្លេងបុរាណខ្មែរ និងការអនុវត្តជាក់ស្តែង ការសម្តែង ការគូរគំនូរ និងផាត់ពណ៌។ល។ ជាចុងក្រោយ មានជំនាញបន្ថែមផ្សេងទៀតត្រូវបានគេស្នើឱ្យដាក់បញ្ចូល ដូចជាការគ្រប់គ្រងហិរញ្ញវត្ថុ និងជំនាញកែសម្ផស្ស។

## ៤.៤ បទអន្តរាគមន៍ដោយអ្នកពាក់ព័ន្ធ

សំណួរស្រាវជ្រាវទី៣ បានកំណត់នូវអន្តរាគមន៍ដែលបានធ្វើកន្លងមកដោយអ្នកសហការគ្នាជាច្រើនរួមមាន ថ្នាក់មន្ទីរ.អយក ថ្នាក់ការិយាល័យ.អយក នាយកឬនាយកាសាលា គ្រូគណៈកម្មការទ្រទង់សាលា អាជ្ញាធរមូលដ្ឋាន និងអាណាព្យាបាល។ ភាគីនីមួយៗដើរតួយ៉ាងសំខាន់និងមានតួនាទីចម្រុះក្នុងការលើកកម្ពស់ការអនុវត្តការអប់រំបំណិនជីវិតក្នុងមូលដ្ឋានរបស់ពួកគេ។

*រូបភាព ៤.៣៤៖ ភាគរយបង្ហាញអ្នកចូលរួមអន្តរាគមន៍របស់ ថ្នាក់មន្ទីរ.អយក*




ជាការឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលបានលើកឡើងខាងលើក្នុង ៤.២.២ អ្នកពាក់ព័ន្ធសំខាន់ៗមកពី ថ្នាក់មន្ទីរ.អយក បានរាយការណ៍ថាធ្លាប់បានធ្វើអន្តរាគមន៍តាមរយៈសកម្មភាពមួយចំនួន។ ថ្នាក់មន្ទីរ.អយក បាន៖ (១) ណែនាំនាយកឬនាយិកាសាលាឱ្យរៀបចំគ្រូឯកទេសផ្សេងៗបង្រៀនជំនួសបណ្តោះអាសន្ន (២) លើកទឹកចិត្តនាយកសាលាឱ្យបញ្ជ្រាបការយល់ដឹងអំពីការអប់រំបំណិនជីវិតតាមរយៈការប្រជុំបច្ចេកទេស និងផ្តល់ជាយោបល់កែលម្អ (៣)ជំរុញនាយកសាលាឱ្យព្យាយាមជ្រើសរើសគ្រូបំណិនជីវិតស្ម័គ្រចិត្តបន្ថែម និងកែច្នៃធនធានដែលមានស្រាប់ដើម្បីបង្រៀន (៤)ណែនាំគ្រូឱ្យបន្តអភិវឌ្ឍសមត្ថភាព (៥) ណែនាំនាយកសាលាឱ្យរៀន និងចែករំលែកបទពិសោធន៍ តាមរយៈការទៅទស្សនកិច្ចសាលាដែលបានអនុវត្តកម្មវិធីបំណិនជីវិតបានល្អ និង(៦) មិនមានការចូលរួមអីទាល់តែសោះ មើលរូបភាព ៤.៣៤។

*រូបភាព ៤.៣៥៖ ភាគរយបង្ហាញអ្នកចូលរួមអន្តរាគមន៍របស់ ថ្នាក់ការិយាល័យ.អយក*




ថ្នាក់ការិយាល័យ.អយក ជាបុគ្គលសំខាន់ផ្សេងទៀតដែលបានអន្តរាគមដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តការអប់រំបំណិនជីវិត។ រហូតមកដល់ពេលនេះថ្នាក់ការិយាល័យ.អយក ៥១,៩ភាគរយ បានរាយការណ៍ថា៖ (១) សហការជាដៃគូអភិវឌ្ឍ (ដូចជា យូនីសេហ្វ)ដើម្បីផ្តល់ជំនួយបច្ចេកទេស (ការតម្រង់ទិស សម្ភារៈឧបទេស បណ្តុះបណ្តាល ធនធានមនុស្ស ការលើកទឹកចិត្ត និងយោបល់កែលម្អ) ដល់សាលាគោលដៅតាមរយៈការប្រជុំ និងសំណើសុំនូវជំនួយប្រកបដោយចីរភាព និងជំរុញឱ្យនាយកសាលាទៅសង្កេតមើលគម្រូសាលាដែលអនុវត្តបានប្រសើរ (២)ធ្វើរបាយការណ៍ និងសំណើទៅក្រសួង និងមន្ទីរដើម្បីសុំគ្រូឯកទេសបំណិនជីវិតបន្ថែម (១៤.៨ភាគរយ) (៣)មិនបានចូលរួមអ្វីទាល់តែសោះ (៧.៤ភាគរយ) (៤)រៀបចំក្រុមការងារទទួលបន្ទុកលើការអនុវត្តការអប់រំបំណិនជីវិត (៣.៧ភាគរយ) (៥) ណែនាំសាលាឱ្យចេះកែច្នៃសម្ភារៈនានាដើម្បីឱ្យសិស្សបានអនុវត្ត មើលរូបភាព ៤.៣៥។

*រូបភាព ៤.៣៦៖ ភាគរយបង្ហាញអ្នកចូលរួមអន្តរាគមន៍របស់ នាយកឬនាយិកាសាលា*




ភាគីសំខាន់បន្ទាប់ គឺនាយកឬនាយិកាសាលាដែលជាអ្នកគាំទ្រផ្ទាល់ដល់គ្រូដើម្បីអនុវត្តការអប់រំបំណិនជីវិតតាមសាលារៀន។ អ្នកចូលរួមបានរាយការណ៍ថាពួកគាត់បាន៖(១)ស្វែងរកការសហការបន្ថែមពីភាគីពាក់ព័ន្ធដូចជា អង្គការក្រៅរដ្ឋាភិបាល មន្ទីរ.អយក ការិយាល័យ.អយក និងសហគមន៍ដើម្បីជួយផ្នែកបច្ចេកទេស (ការបណ្តុះបណ្តាលធនធានមនុស្ស) និងជួយផ្នែកថវិកាសម្រាប់សម្ភារៈអនុវត្ត និងគ្រឿងជំនួយផ្សេងៗ (៣៥,១ភាគរយ) (២)រៀបចំគ្រូឯកទេសផ្សេងបង្រៀនជំនួស (២៩,៧ភាគរយ) (៣)លើកទឹកចិត្តឱ្យមានការចូលរួម សហការដើម្បីសម្របសម្រួលក្នុងការរៀបចំសម្ភារៈដែលមានស្រាប់មកអនុវត្ត លើកទឹកចិត្តសិស្សឱ្យមានចូលរួមបរិច្ចាគសម្ភារៈផ្ទាល់ខ្លួនមកអនុវត្តតាមរយៈការផ្តល់ពិន្ទុ និងរក្សាទំនាក់ទំនងល្អជាមួយសហគមន៍ (២១,៦ភាគរយ) (៤)ផ្តល់ការណែនាំ និងយោបល់កែលម្អដល់គ្រូ (២,៧ភាគរយ) និងមិនបានចូលរួមជួយអ្វីទាំងអស់ (១០,៨ភាគរយ) មើលរូបភាព ៤.៣៦។

*រូបភាព ៤.៣៧៖ ភាគរយបង្ហាញអ្នកចូលរួមអន្តរាគមន៍របស់គ្រូ*




ដើម្បីពង្រឹងការអប់រំបំណិនជីវិត គ្រូត្រូវបានគេចាត់ទុកថាជាអ្នកអនុវត្តដែលត្រូវប្រឈមនឹងបញ្ហាផ្ទាល់បានរាយការណ៍ថា បានដោះស្រាយបញ្ហាទាំងនោះដោយធ្វើនូវសកម្មភាពអន្តរាគមន៍មួយចំនួនរួមមាន (១)រាយការណ៍ផ្ទាល់មាត់ និងស្នើទៅនាយកសាលានៅពេលប្រជុំឱ្យជួយគាំទ្រលើផ្នែកមួយចំនួនដូចជាយោបល់កែលម្អ ថវិកា។ល។ (៤៩ភាគរយ) (២)បញ្ជ្រាបផ្នែកខ្លះៗអំពីបំណិនជីវិត និងសារៈសំខាន់របស់វានៅពេលបង្រៀន (ឧ.របៀបដោះស្រាយបញ្ហាការរៀបផែនការជីវិត សេចក្ដីក្លាហាន)(១៧ភាគរយ) (៣)បង្រៀនជំនួស ករណីខ្វះគ្រូបំណិនជីវិត (តាមតែទ្រឹស្ដី) (១៥ភាគរយ) (៤)ប្រើសម្ភារៈងាយៗដូចជាសៀវភៅពុម្ព ឯកសារពាក់ព័ន្ធ និងរូបភាពជាដើម (១០ភាគរយ) (៥)ស្រាវជ្រាវឯកសារបន្ថែមសម្រាប់ការបង្រៀន (៨ភាគរយ) (៦)មិនបានចូលរួម (៥ភាគរយ) (៧)ចូលរួមវគ្គបណ្ដុះបណ្ដាលអង្គការក្រៅរដ្ឋាភិបាល និង(៨)លើកទឹកចិត្តសិស្សឱ្យជួយបរិច្ចាគសម្ភារៈខ្លះៗសម្រាប់អនុវត្ត ដោយជាផ្ដល់ពិន្ទុ (៣ភាគរយ) មើលរូបភាព ៤.៣៧។

*រូបភាព ៤.៣៨៖ ភាគរយបង្ហាញអ្នកចូលរួមអន្តរាគមន៍របស់ គណៈកម្មការទ្រទ្រង់សាលា*




លើសពីនេះទៅទៀត គណៈកម្មការទ្រទ្រង់សាលារៀន ត្រូវបានគេរាយការណ៍ថាចូលរួមនៅក្នុងដំណើរការនៃការអនុវត្តការអប់រំបំណិនជីវិត។ ដូច្នេះក្នុងអំឡុងពេលសម្ភាស ពួកគាត់បានរាយការណ៍ថាបានធ្វើសកម្មភាពមួយចំនួនដើម្បីគាំទ្រកម្មវិធីរួមមាន (១)ផ្តល់ធាតុចូលខ្លះៗទាក់ទងនឹងការគ្រប់គ្រងការអនុវត្តកម្មវិធីបំណិនជីវិតនៅសាលារៀននៅពេលប្រជុំ ដូចជា យោបល់លើបរិស្ថានសាលា និងការអនុវត្ត(ឧ.ស្នើដាក់បញ្ចូលប្រធានបទពាក់ព័ន្ធនឹងធម៌ និងកសិកម្មដាំដើម ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីបំណិនជីវិត និងបង្កើនកិច្ចសហការ (៦៦,៧ភាគរយ) (២)ចូលរួមស្ម័គ្រចិត្ត(ឧ.ផ្តល់សម្ភារៈ ថវិកា ជំនួយបច្ចេកទេស និងសកម្មភាពនានា (៤៤,៤ភាគរយ) (៣) រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តការអប់រំបំណិនជីវិតដែលរួមមាន (ក) ស្វែងរកធនធានពីសហគមន៍ (២៧,៨ភាគរយ) (ខ) បង្កើតមូលនិធិ (២២,២ភាគរយ) (គ) សហការជាមួយដៃគូនានា (២២,២ភាគរយ) (ឃ) ធ្វើផែនការកែលម្អបរិស្ថានសាលារៀន (២២,២ភាគរយ) (ង) ធ្វើផែនការថវិកាសម្រាប់ទ្រទង់កម្មវិធី ១៩,៤ភាគរយ) និង(ច) ស្វែងរកអ្នកជំនាញ (១៦,៧ភាគរយ) មើលរូបភាព ៤.៣៨។

*រូបភាព ៤.៣៩៖ ភាគរយបង្ហាញអ្នកចូលរួមអន្តរាគមន៍របស់ អាជ្ញាធរមូលដ្ឋាន*




ក្រៅពីនេះ អាជ្ញាធរមូលដ្ឋានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការអនុវត្តកម្មវិធី។ ដូច្នេះពួកគាត់ក៏បានរាយការណ៍នូវអ្វីដែលពួកគាត់បានជួយកន្លងមករួមមាន (១)ស្វែងរក និងជំរុញការគាំទ្រពីដៃគូ អាណាព្យាបាល និងគណៈកម្មការគាំទ្រសាលាឱ្យមានការចូលរួមសកម្មភាព និងបរិច្ចាគផ្សេងៗ (ឧ.សម្ភារៈ ការស្ម័គ្រចិត្ត ជំនួយបច្ចេកទេស។ល។ ) (៣៧,៩ភាគរយ) (២)ចូលរួមប្រជុំជាមួយសាលា និងសហគមន៍ដើម្បីផ្សព្វផ្សាយពីបញ្ហាទូទៅផ្សេងៗ និងការអប់រំបំណិនជីវិត និងលើកទឹកចិត្តឱ្យយកចិត្តទុកដាក់ក្នុងការសិក្សា (៣៧,៩ភាគរយ) (៣)បរិច្ចាគសម្ភារៈ និងថវិកាខ្លះដើម្បីជួយសកម្មភាពមួយចំនួនដល់សាលាពេលចាំបាច់ (១៧,២ភាគរយ) និង(៤)មិនបានចូលរួម (៦,៩ភាគរយ) មើលរូបភាព ៤.៣៩។

*រូបភាព ៤.៤០៖ ភាគរយបង្ហាញអ្នកចូលរួមអន្តរាគមន៍របស់ អាណាព្យាបាលសិស្ស*



អ្នកគាំទ្រចុងក្រោយ ដែលជួយដល់ការអនុវត្តបានផ្សាភ្ជាប់ជាចម្បងជាមួយនឹងការចូលរួមរបស់អាណាព្យាបាល។ ដូច្នេះ អ្នកស្រាវជ្រាវក៏បានសម្ភាសអាណាព្យាបាលបន្ថែមទៀតដើម្បីបញ្ជាក់ថា ពួកគាត់បានចូលរួមវិភាគទានដល់ណាមួយដល់សាលារៀន។ ពួកគាត់បានរាយការណ៍ថាពួកគាត់បាន (១)ចូលរួមសកម្មភាពស្ម័គ្រចិត្តនានា ដូចជាពេលវេលាក្នុងការតាមដានការសិក្សារបស់កូន លើកទឹកចិត្តពួកគេឱ្យខំសិក្សា ផ្ដល់ឱកាសឱ្យពួកគេមានពេលអនុវត្តបន្ថែមនៅផ្ទះដូចជាជួយការងារផ្ទះ និងដាំដំណាំជាដើម (៥៣,២ភាគរយ) (២)ផ្ដល់ធាតុចូលខ្លះៗទាក់ទងនឹងការគ្រប់គ្រងការអនុវត្តកម្មវិធីបំណិនជីវិតនៅសាលារៀននៅពេលប្រជុំដូចជា ជំរុញការពង្រឹងប្រសិទ្ធភាពនៃការបង្រៀន ពិនិត្យ និងចែករំលែកបទពិសោធន៍ទាក់ទងនឹងកសិកម្ម(៤៤,៩ភាគរយ) និង(៣)បរិច្ចាគថវិកាខ្លះៗដើម្បីរៀបចំបរិស្ថានសាលា និងការអនុវត្ត (១៦,៨ភាគរយ)។

## ៤.៩ យោបល់របស់អ្នកចូលរួម

ទាក់ទងទៅនឹងបញ្ហាប្រឈមដែលបានលើកឡើងខាងលើ ក៏ដូចជាបទអន្តរាគមន៍ដែលបានធ្វើកន្លងមក អ្នកចូលរួមបានស្នើយោបល់មួយចំនួនដល់ភាគីសំខាន់ៗទាំងអស់ក្នុងការពិចារណានិងចាត់វិធានការបន្ទាន់ដើម្បីទទួលបានលទ្ធផលល្អប្រសើរ។

### ៤.៩.១ ក្រសួង.អយក

ស្របពេលដំណាលគ្នា សកម្មភាពមួយចំនួនត្រូវបានគេតម្រង់ឆ្ពោះទៅក្រសួងអប់រំយុវជន និងកីឡា ដើម្បីពិចារណា។ អ្នកចូលរួមបានលើកឡើងថា ក្រសួង.អយក គួរពិចារណានូវចំណុចដូចខាងក្រោម៖

បន្ថែមការយកចិត្តទុកដាក់លើការអប់រំបំណិជីវិតដោយដាក់បញ្ចូលមុខវិជ្ជានេះទៅក្នុងការប្រឡងថ្នាក់ជាតិ បន្ថែមម៉ោងបង្រៀន និងម៉ោងអនុវត្ត ពង្រឹងកិច្ចសហការជាមួយថ្នាក់ក្រោមជាតិ ផ្ដល់ជំនួយបច្ចេកទេសនានាតាមការចាំបាច់៖

- ផ្ដល់គ្រូដែលមានជំនាញគ្រប់គ្រាន់គ្រូ ពិសេសគ្រូបំណិនអាជីពងាយៗដល់សាលារៀនដែលត្រូវការ។
- ផ្ដល់សម្ភារៈដែលពាក់ព័ន្ធគ្រប់គ្រាន់ (ឧ.សេចក្ដីណែនាំ, កម្មវិធីសិក្សាលម្អិត សៀវភៅសិក្សាគោល) និងគ្រឿងបរិក្ខារសម្រាប់បម្រើដល់ការអនុវត្ត (បន្ទប់ / កន្លែងសម្រាប់អនុវត្តកុំព្យូទ័រម៉ាស៊ីនដេរ ឧបករណ៍និងធនធានសម្រាប់អនុវត្តមុខវិជ្ជាកសិកម្ម សិល្បៈ និងរោងជាង។ល។ )

- ទម្លាក់ថវិកាសំរាប់ការអនុវត្តការអនុវត្តការអប់រំបំណិនជីវិត
- ពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំ (តាមរយៈការសង្កេត និងការស្ទង់មតិ) និងផ្តល់នូវមតិស្ថាបនា។
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាលដើម្បីណែនាំ និងពង្រឹងសមត្ថភាពដល់អ្នកអនុវត្ត (មន្ត្រីទទួលបន្ទុកការងារអប់រំបំណិនជីវិតដែលមកពី ថ្នាក់ការិយាល័យ.អយក នាយក ឬនាយិកាសាលា គ្រូ) ដូចជាធ្វើការចុះទស្សនកិច្ចសិក្សាដើម្បីទទួលបានបទពិសោធន៍ពីសាលាដែលអនុវត្តការអប់រំបំណិនជីវិតបានជោគជ័យ (យ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ)
- កំណត់ផែនការឱ្យបានច្បាស់លាស់សម្រាប់ការអនុវត្តជាមួយក្រុមការងារជាក់លាក់ និងមានការតម្រង់ទិសច្បាស់លាស់សម្រាប់អ្នកដែលចូលរួមទាំងអស់។
- ផ្តល់ការលើកទឹកចិត្តបន្ថែមសម្រាប់គ្រូ និងអ្នកដែលស្ម័គ្រចិត្តជួយ និងលើកទឹកចិត្តបន្ថែមដល់សិស្ស។

### ៤.៩.២ ថ្នាក់មន្ទីរ.អយក

ថ្នាក់មន្ទីរ.អយក ជាអ្នកពាក់ព័ន្ធសំខាន់ទី២ ទទួលបន្ទុកអនុវត្តការងារអប់រំទូទាំងខេត្ត និងណែនាំគោលការណ៍ច្បាប់ និងបទបញ្ជាក្នុងមូលដ្ឋានរបស់ក្រសួង.អយក។ អ្នកចូលរួមបានស្នើថ្នាក់មន្ទីរ.អយក ឱ្យជួយគាំទ្រដល់សកម្មភាពចាំបាច់មួយចំនួនៈ

- ផ្សព្វផ្សាយរាល់ឯកសារគតិយុត្តពាក់ព័ន្ធនានា និងឧបករណ៍ពិនិត្យ និងវាយតម្លៃ និងធានាថាភាគីពាក់ព័ន្ធ និងអ្នកអនុវត្តទទួលបានឯកសារទាំងនោះនិងមានការណែនាំច្បាស់លាស់
- រៀបចំក្រុមការងារដើម្បីពង្រឹងការពិនិត្យតាមដាននិងវាយតម្លៃជាប្រចាំ ផ្តល់មតិយោបល់លើការ អនុវត្តកម្មវិធីដល់អ្នកអនុវត្ត និងធ្វើឱ្យការអនុវត្តប្រសើរឡើង
- រៀបចំសិក្ខាសាលាក្នុងការជ្រើសរើសប្រធានបទសំខាន់ៗ ដើម្បីឆ្លើយតបនឹងតម្រូវការក្នុងតំបន់
- រក្សាទំនាក់ទំនងជាមួយថ្នាក់ការិយាល័យ.អយក
- ផ្តល់គ្រូឯកទេសឱ្យបានគ្រប់គ្រាន់តាមតម្រូវការ

- ផ្តោតការយកចិត្តទុកដាក់បន្ថែម លើការអនុវត្តការអប់រំបំណិនជីវិតទាក់ទងនឹងការបង្កើនម៉ោងសម្រាប់ការបង្រៀននិងការអនុវត្តរួមទាំងដាក់មុខវិជ្ជាទាំងនោះក្នុងការប្រឡង
- ផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស សម្ភារៈបរិក្ខា និងថវិកាគាំទ្របន្ថែមសម្រាប់ការអនុវត្តការអប់រំបំណិនជីវិត (កសិកម្ម សិល្បៈ គេហវិទ្យា កុំព្យូទ័រ និងរោងជាង) និងកែលម្អបរិស្ថានសាលា
- រាយការណ៍ទៅថ្នាក់កណ្តាលអំពីស្ថានភាពនៃការអនុវត្ត និងស្នើសុំការអន្តរាគមន៍នានា
- ស្វែងរកដៃគូអភិវឌ្ឍន៍បន្ថែមដើម្បីគាំទ្រ។

### ៤.៩.៣ ថ្នាក់ការិយាល័យ.អយក

នៅថ្នាក់ក្រោមជាតិ ថ្នាក់ការិយាល័យ.អយក ត្រូវបានសង្កេតឃើញថាត្រូវសហការគាំទ្រយ៉ាងជិតស្និទ្ធជាមួយសាលារៀន។ នោះហើយជាមូលហេតុដែលអ្នកចូលរួមបានស្នើការផ្តល់យោបល់ទៅថ្នាក់ការិយា ល័យ.អយក ដើម្បីរៀបចំការងារអនុវត្តការអប់រំបំណិនជីវិតឱ្យបានត្រឹមត្រូវ។ ដែលក្នុងនោះរួមមានការ តម្រូវការបច្ចេកទេសក៏ដូចជាការលើកទឹកចិត្តបន្ថែមផ្សេងទៀត៖

- បង្កើនកិច្ចសហការឱ្យកាន់តែច្រើននៅក្នុងសាលារៀន
- ពង្រឹងការពិនិត្យតាមដាន និងវាយតម្លៃ សម្រាប់ការអនុវត្តការអប់រំបំណិនជីវិតតាមសាលារៀនឱ្យបានទៀងទាត់តាមរយៈការសង្កេតនិងការស្ទង់មតិ
- ផ្តល់យោបល់ និងព័ត៌មានត្រឡប់ដោយផ្ទាល់ទៅសាលារៀនទាក់ទងនឹងការអនុវត្ត
- ផ្សព្វផ្សាយព័ត៌មានណាមួយនិងផ្តល់ការណែនាំពីក្រសួងអប់រំ យុវជន និងកីឡាដើម្បីឱ្យសាលារៀនបានយល់ច្បាស់ និងផ្តល់ការសម្របសម្រួលកាន់តែសកម្មប្រសិនបើចាំបាច់
- កំណត់ផែនការច្បាស់លាស់សម្រាប់ការអនុវត្ត
- ផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើការអនុវត្តការអប់រំបំណិនជីវិត៖ បង្កើនម៉ោងសម្រាប់ការបង្រៀននិងការអនុវត្ត និងដាក់បញ្ចូលទាំងមុខវិជ្ជាដែលជាប់ក្នុងការប្រឡង
- ពង្រឹងប្រសិទ្ធភាពការងាររបស់មន្ត្រីទទួលបន្ទុកការងារបំណិនជីវិត
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់គ្រូទាក់ទងនឹងការអប់រំបំណិនជីវិត (ឧ. ការបណ្តុះបណ្តាល និងបទពិសោធន៍នានា)

- ធ្វើរបាយការណ៍ និងស្នើសុំសម្ភារៈនិងគ្រឿងបរិក្ខារជាច្រើនទៀតសម្រាប់ការអនុវត្តឱ្យកាន់តែប្រសើរឡើង
- បង្កើនឱកាសដើម្បីផ្សព្វផ្សាយ និងបញ្ជ្រាបសារៈសំខាន់នៃការអប់រំបំជីវិតតាមសាលារៀន និងសហគមន៍ (ឧ.ការប្រជុំប្រចាំខែ ព្រឹត្តិការណ៍សាលារៀន។ល។ )
- ស្វែងរកការគាំទ្របន្ថែមពីដៃគូអភិវឌ្ឍន៍ ក៏ដូចជាសហគមន៍ដើម្បីជួយសាលារៀនតាមតម្រូវការ (ឧ.មូលនិធិសម្រាប់ជំនួយបច្ចេកទេសឬការលើកទឹកចិត្ត)
- លើកទឹកចិត្តឱ្យសាលារៀនរក្សាទំនាក់ទំនងជាមួយសហគមន៍។

### ៤.៥.៤ នាយកឬនាយិកាសាលា

លើសពីនេះ នាយកសាលាដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តលើកកម្ពស់និងវាយតម្លៃភាពជោគ ជ័យនៃកម្មវិធី។ ដូច្នេះដើម្បីបណ្តុះការអនុវត្តការអប់រំបំណិនជីវិត នាយកឬនាយិកាសាលាត្រូវបានណែនាំឱ្យអនុវត្តតួនាទីដូចខាងក្រោម៖

- រៀបចំផែនការប្រតិបត្តិការសាលារៀនដោយដាក់បញ្ចូលសកម្មភាពជាក់លាក់ ដើម្បីអនុវត្តឆ្លើយតបទៅនឹងតម្រូវការក្នុងតំបន់
- លើកទឹកចិត្តគ្រូឱ្យពិនិត្យតាមដាននិងវាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ
- កសាងទំនាក់ទំនងជាមួយអ្នកចូលរួមទាំងអស់ និងចូលរួមក្នុងសកម្មភាពផ្សេងៗរបស់សាលាសម្រាប់ការចូលរួមចំណែក និងចែករំលែកព័ត៌មានណាមួយជាពិសេសដល់អាណាព្យាបាល
- ផ្តល់ឱកាសនិងសមធម៌នៃការរៀនសូត្រដល់សិស្សទាំងអស់

លើកកម្ពស់គុណភាពរៀនដោយ៖

- បំពាក់បំប៉នគ្រូមានសមត្ថភាព
- គាំទ្រផ្នែកសម្ភារៈ និងគ្រឿងបរិក្ខា (សំភារៈបង្រៀនជំនាញជីវិតងាយៗ កន្លែង សមរម្យសំរាប់ការអនុវត្ត) និងជំនួយបច្ចេកទេស (ការណែនាំនិងការបណ្តុះ បណ្តាលដ៏ទូលំទូលាយ ការលើកទឹកចិត្តសំរាប់អ្នកផ្តើម/សង្វាតនឹងការងារ)
- កំណត់ឱ្យបទប្បញ្ញត្តិតឹងរ៉ឹង

- អនុវត្តការពិនិត្យតាមដាននិងវាយតម្លៃការអប់រំបំណិនជីវិតជាប្រចាំនិងផ្តល់មតិ ត្រឡប់ (ឧ. ណែនាំគ្រូឱ្យរៀបចំកម្មវិធីសិក្សាលម្អិតឱ្យបានច្បាស់លាស់អំពីអ្វីដែលត្រូវបង្រៀន និងធ្វើ)
- រៀបចំរបាយការណ៍ពិនិត្យតាមដាន រួចផ្ញើទៅថ្នាក់ការិយាល័យ.អយក
- បង្កើនពេលវេលាសម្រាប់ការអនុវត្តការអប់រំបំណិនជីវិត
- រៀបចំកម្មវិធីលម្អិត និងប្រធានបទជាក់លាក់ឱ្យស្របតាមតម្រូវការក្នុងតំបន់
- រៀបចំក្រុមការងារអប់រំបំណិនជីវិត និងរៀបចំផែនការសកម្មភាពនានាដើម្បីសហការគ្នា។

### ៤.៥.៥ គណៈកម្មការទ្រទ្រង់សាលា

លើសពីនេះទៅទៀត គណៈកម្មការទ្រទ្រង់សាលារៀន គឺជាអ្នកគាំទ្រដែលនៅជាប់នឹងសាលារៀន និងសហគមន៍ក្នុងការជួយធានាថាការអប់រំនិង គោលដៅអភិវឌ្ឍន៍សាលារៀនប្រព្រឹត្តទៅមានការឆ្លើយតប។ ដើម្បីពង្រឹងការអនុវត្តការអប់រំបំណិនជីវិត គណៈកម្មការទ្រទ្រង់សាលារៀនត្រូវបានស្នើឱ្យ៖

មានការចូលរួមរាល់សកម្មភាព និងរួមចំណែកតាមដែលអាចធ្វើទៅបានសម្រាប់ការអនុវត្តការអប់រំបំណិនជីវិត រួមមាន៖

- ការគាំទ្រថវិកា (ឧ.ដើម្បីកែលម្អបរិស្ថានសាលារៀនឱ្យស្អាត និងបង្កើនការអនុវត្តការអប់រំបំណិនជីវិត)
- ការបរិច្ចាគសម្ភារៈបង្រៀន និងរៀន
- ការផ្តល់ព័ត៌មានទាក់ទងនឹងការអប់រំបំណិនជីវិតពីសាលារៀនដល់អាណាព្យាបាល និងសហគមន៍ ដើម្បីចូលរួមសកម្មភាពសាលារៀន ដោយរៀបចំការប្រជុំនិងអញ្ជើញអ្នកដែលពាក់ព័ន្ធអោយចូលរួម។
- ពង្រឹង និងការពារសកម្មភាពមិនប្រក្រតីនានា និងអត្រាបោះបង់ការសិក្សាតាមរយៈដំណោះស្រាយផ្សេងៗ។
- ជួយគាំទ្រផ្នែកបច្ចេកទេសនានា
- ស្វែងរកធនធានមនុស្សនិងការគាំទ្រផ្សេងទៀតសម្រាប់កម្មវិធី។

- រៀបចំការប្រជុំជាមួយភាគីសំខាន់ៗដែលពាក់ព័ន្ធ ដើម្បីជ្រើសរើសប្រធានបទបង្រៀនឱ្យឆ្លើយតបនឹងតម្រូវការមូលដ្ឋាន។
- ពិនិត្យតាមដានការអនុវត្តការអប់រំបំណិនជីវិតនៅតាមសាលារៀននិងស្នើសុំអន្តរាគមន៍ជាយុទ្ធសាស្ត្រមួយចំនួនដើម្បីដោះស្រាយបញ្ហាប្រឈមនៃការអនុវត្តកម្មវិធី។

### ៨.៩.៦ អាជ្ញាធរមូលដ្ឋាន

បន្ទាប់មកទៀត អាជ្ញាធរមូលដ្ឋានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាគាំទ្រ បែងចែកថវិកាដល់សាលារៀន និងជួយរដ្ឋាភិបាលក្នុងការអនុវត្តគំនិតផ្តួចផ្តើមនិងច្បាប់នានាដែលទាក់ទងទៅនឹងសាលារៀន កុមារនិងគ្រួសារដើម្បីជួយគាំទ្រដល់សាលាឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យការអប់រំក៏ដូចជាការអប់រំបំណិនជីវិតមានប្រសិទ្ធភាពនិងឆ្លើយតម។ នោះហើយជាមូលហេតុដែលសកម្មភាពជាក់លាក់មួយចំនួន ត្រូវបានស្នើទៅអាជ្ញាធរមូលដ្ឋានដើម្បីដោះស្រាយបញ្ហាប្រឈមនៃការអនុវត្តការអប់រំបំណិនជីវិត។

ព្យាយាមស្វែងយល់អំពីអត្ថប្រយោជន៍ការអប់រំបំណិនជីវិត លើកទឹកចិត្តនិងពិនិត្យតាមដានការអនុវត្តកម្មវិធីរៃអង្គាសថវិកាណាមួយ (ឧ. សម្ភារៈ ថវិកា) ពីមាតាបិតានិងសហគមន៍ដើម្បីគាំទ្រដល់ការអនុវត្តការអប់រំបំណិនជីវិត និងកែលម្អបរិស្ថានសាលារៀន ជួយសម្រួលទីធ្លាសម្រាប់ការអនុវត្តការអប់រំបំណិនជីវិត បទពិសោធន៍សម្រាប់ការអនុវត្ត និងគ្រូជំនាញ (ជំនួយបច្ចេកទេស) ប្រសិនបើចាំបាច់ចូលរួមក្នុងសកម្មភាពនានារបស់សាលារៀន ដូចជាការប្រជុំពិភាក្សាអំពីបញ្ហាប្រឈមនិងដំណោះស្រាយដើម្បីកែលម្អការអនុវត្តការអប់រំបំណិនជីវិត និងរៀបចំផែនការសកម្មភាពបង្កើតទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ (ឧ. ជួយផ្សព្វផ្សាយនិងបញ្ជូនព័ត៌មានទៅឪពុកម្តាយទៅវិញទៅមក) លើកទឹកចិត្តសិស្សឱ្យចូលរួមតាមរយៈការបញ្ជ្រាបខ្លឹមសារខ្លះៗនៅពេលប្រជុំ ចូលរួមថែរក្សានិងពង្រឹងស្ថេរភាពសណ្តាប់ធ្នាប់នៅក្នុងសហគមន៍។

### ៨.៩.៧ អាណាព្យាបាល

ក្រៅពីការរៀនសូត្រនៅសាលារៀន អាណាព្យាបាលដើរតួយ៉ាងសកម្មដើម្បីជួយសិស្សឱ្យមានជំនាញសង្គមល្អប្រសើរ និងឥរិយាបថល្អប្រសើរ។ការលើកទឹកចិត្តនិងការគាំទ្រពីអាណាព្យាបាលក្នុងសកម្មភាពរៀនសូត្រនៅផ្ទះ រួមជាមួយការចូលរួមរបស់អាណាព្យាបាលក្នុងការសិក្សាមានសារៈសំខាន់ណាស់សម្រាប់ការអប់រំកុមារ។ ការកើនឡើងនៃការស្រាវជ្រាវបង្ហាញថាការបង្កើតភាពជាដៃគូប្រកបដោយប្រសិទ្ធភាពរវាងអាណាព្យាបាល ក្រុមគ្រួសារ និងសាលារៀនដើម្បីគាំទ្រដល់ការរៀនសូត្ររបស់កុមារឱ្យមានលទ្ធផលសិក្សាប្រសើរឡើង។ បន្ទាប់មក

ដើម្បីសំរេចបានដូច្នេះ  អាណាព្យាបាលត្រូវបានគេណែនាំឱ្យចូលរួមក្នុងសកម្មភាពមួយចំនួនរួមមាន៖

- ចូលរួមវិភាគទានថវិកា សម្ភារៈ បទពិសោធន៍ជាក់ស្ដែង និងសំណូមពរនានាដើម្បីធ្វើឱ្យការបង្រៀននិងការរៀនបំណិនជីវិត មានគុណភាពកាន់តែប្រសើរតាមដែលអាចធ្វើទៅបាន
- លើកទឹកចិត្តសិស្សឱ្យខិតខំរៀនសូត្រ និងគោរពបទបញ្ជាសាលាដោយលើកទឹកចិត្តពួកគេទាំងផ្លូវចិត្តនិងសម្ភារៈ និងចំណាយពេលជាមួយពួកគេ
- ចូលរួមក្នុងសកម្មភាពនិងព្រឹត្តិការណ៍នានារបស់សាលារៀន  ហើយព្យាយាមឈ្វេងយល់ និងអោយតម្លៃការអប់រំបំណិនជីវិត
- បញ្ជ្រាបតម្លៃនៃការអប់រំបំណិនជីវិត ដល់កូនៗតាមដែលអាចធ្វើទៅបាន
- តាមដានការរៀនបំណិនជីវិត ដោយសហការជាមួយសាលារៀន ដើម្បីឈ្វេងយល់ឱ្យបានពេញលេញអំពីការអនុវត្តកម្មវិធី។

### ៤.៩.៨ ដៃគូអភិវឌ្ឍន៍

ជាក់ស្ដែង ដើម្បីលើកកម្ពស់គុណភាពអប់រំ ក្រសួង.អយក តែម្នាក់ឯងមិនអាចគ្រប់គ្រងអ្វីៗគ្រប់យ៉ាងឱ្យបានគ្រប់ជ្រុងជ្រោយនោះទេ  ដូច្នេះការចូលរួមគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ទាក់ទងនឹងការគាំទ្រផ្នែកបច្ចេកទេសនិងថវិកាពិតជាមិនអាចខ្វះបាន។ ក្នុងន័យនេះ ភាគីទាំងនោះ ក៏ត្រូវបានស្នើឱ្យជួយដូចតទៅ៖

- ផ្ដល់ជំនួយបច្ចេកទេស បទពិសោធន៍ ថវិកា និងការសម្រួលការអនុវត្ត ប្រសិនបើចាំបាច់
- ផ្ដល់ការបំប៉នសមត្ថភាពដល់គ្រូក៏ដូចជានាយកឬនាយិកាសាលា និងជ្រើសរើសធនធានមនុស្សដែលមានជំនាញឯកទេសបន្ថែមដើម្បីគាំទ្រ
- លើកទឹកចិត្តដល់អ្នកអនុវត្តការអប់រំបំណិនជីវិត  ក៏ដូចជាសិស្សដោយផ្ដល់ជាសម្ភារៈបង្រៀននិងរៀនទាំងគ្រូនិងសិស្ស
- ស្នើមតិ ឬយោបល់គ្រឡប់ដែលអាចអនុវត្តបានដើម្បីលើកកម្ពស់ការអនុវត្តការអប់រំបំណិនជីវិត (ឧ.កែលម្អបរិស្ថានសាលារៀន ជាពិសេសដើម្បីបម្រើដល់ការអនុវត្ត ឬសកម្មភាព និងព្រឹត្តិការណ៍នានាក្នុងសាលា)

• ពិនិត្យតាមដានជាប្រចាំទាក់ទងនឹងការអនុវត្ត បន្ទាប់ពីផ្តល់ការគាំទ្រនិងរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយសាលារៀន

• ធានានូវការគាំទ្រប្រកបដោយនិរន្តរភាព។

## ៤.៦ ការពិភាក្សា

### ៤.៦.១ ការពិភាក្សាអំពីបញ្ហាប្រឈមសំខាន់ៗនៃការអនុវត្តការអប់រំបំណិនជីវិត

ការសិក្សាស្រាវជ្រាវនេះ ព្យាយាមបង្ហាញពីស្ថានភាពនៃការអនុវត្តការអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិនៅកម្ពុជានាពេលបច្ចុប្បន្ន ដោយសិក្សាលើចំណុចសំខាន់ៗ។ ចំណុចស៊ីជម្រៅបន្ថែមដែលគួរពិចារណា ក៏បានបញ្ជាក់នៅក្នុងផ្នែកនេះផងដែរ។

ជាបឋម ផ្អែកតាមលទ្ធផលនៃការសិក្សានេះ បានបញ្ជាក់ថាមានបញ្ហាប្រឈមមួយចំនួនបានកើតឡើង ខណៈដែលបញ្ហាទាំងនោះតម្រូវឲ្យអ្នកចូលរួមទាំងអស់ត្រូវយកមកពិចារណា។ លទ្ធផលបានបង្ហាញថា ភាពឆ្លើយតបនៃការអនុវត្តចំពោះសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងតម្រូវការក្នុងមូលដ្ឋានត្រូវបានរាយការណ៍ថាមិនទាន់សម្រេចបានតាមការចង់បាននៅឡើយទេ។ សិស្ស អាណាព្យាបាល និងសូម្បីតែគ្រូពេលគឺអ្នកអនុវត្តផ្ទាល់ក៏នៅមិនទាន់យល់ច្បាស់អំពីការអនុវត្តការអប់រំបំណិនជីវិតនៅឡើយផងដែរ។ ក្នុងន័យនេះ ការយល់ដឹងតិចតួចក្នុងចំណោមអ្នកចូលរួម គឺដោយសារតែការតម្រង់ទិស និងការណែនាំពីអ្នកគាំទ្រដែលពាក់ព័ន្ធទាំងអស់នៅមានកម្រិត។ អ្វីដែលគួរឱ្យកត់សម្គាល់ជាងនេះទៅទៀតនោះគឺតម្រូវការធនធានសម្រាប់ការបង្រៀននិងរៀននៅមានភាពខ្វះខាត។ អាចនិយាយបានថាកង្វះជំនាញ សេចក្តីណែនាំ និងកម្មវិធីសិក្សាហាក់នៅមិនទាន់បានគ្រប់ជ្រុងជ្រោយ និងតម្រង់ទិសច្បាស់លាស់។ ទាក់ទងនឹងបញ្ហានេះ ចំណាប់អារម្មណ៍និងការយកចិត្តទុកដាក់ចំពោះកម្មវិធីហាក់ត្រូវបានមើលរំលង។ ទោះយ៉ាងណា លទ្ធផលនៃការសិក្សាបានបង្ហាញថាអ្នកចូលរួមមួយចំនួន (៩៩ភាគរយ) បានផ្តោតលើសារៈសំខាន់នៃការអនុវត្តការអប់រំបំណិនជីវិតក្នុងការបង្កើនការគោរពខ្លួនឯងនិងសមត្ថភាព និងជាថ្នាលចម្លងទៅកាន់អាជីពដ៏ត្រឹមត្រូវនាពេលអនាគត សូមមើលរូបភាព ៤.៣២។ គេសង្កេតឃើញថាអ្វីដែលអ្នកចូលរួមបានអះអាងផ្អែកលើទស្សនផ្ទាល់ខ្លួនដោយមិនមានការតម្រង់ទិសជំនាញនោះទេ។ អនុលោមតាមការអះអាងស្តីពីផលប្រយោជន៍នៃការអប់រំបំណិនជីវិតសម្រាប់សិស្សត្រូវបានគាំទ្រដោយការសិក្សាជាច្រើន (ឧ. Okech&Role ២០១៥; Prajapati et al, ២០១៧)។

ចំណុចទីពីរ និងបញ្ហាដែលកំពុងប្រឈមខ្លាំងទាក់ទងនឹងការអនុវត្តការអប់រំបំណិនជីវិត ត្រូវបានគេសម្គាល់ថាការអនុវត្តហាក់មានការធ្លាក់ចុះខ្លាំង ពិសេសនៅថ្នាក់ទី៩។ វាក៏គួរតែមានហេតុផលមួយចំនួននៅពីក្រោយការរកឃើញនេះផងដែរ។ តាមពិត សិស្សនៅដំណាក់កាលនេះ ហាក់ដូចជាត្រូវបានតម្រង់ទិសសិក្សា ដោយគ្រាន់តែឱ្យប្រឡងជាជាងពង្រឹងជំនាញជាពិសេស ជំនាញជីវិត។ ទាក់ទងនឹងកង្វះអ្នកជំនាញបំណិនអាជីព ក្រសួង.អយក មិនដែលបានបណ្តុះបណ្តាលគ្រូមុខបំណិនជីវិតមូលដ្ឋានទាល់តែសោះ។ ទន្ទឹមនឹងនេះ មុខវិជ្ជាទាំងនោះត្រូវបានបង្រៀនដោយគ្រូមុខវិជ្ជាផ្សេងទៀត។ គួរបញ្ជាក់ថា បំណិនអាជីពងាយៗបានអនុវត្តដោយមិនសូវមានការយកចិត្តទុកដាក់ក្នុងចំណោមអ្នកចូលរួម។ ទាក់ទងនឹងបញ្ហាការ បណ្តុះបណ្តាលមិនគ្រប់គ្រាន់ដែលបានរកឃើញនៅក្នុងការសិក្សានេះ មានលក្ខណៈស្របនឹងការសិក្សាកន្លងមក (ឧ.Chirwa & Naidoo, ២០១៤; Marieta M. , ២០១៤; Paola et al , ២០១២; Wairimu, ២០១៥)។ ជាទូទៅ ដើម្បីធានានូវគុណភាពនិងប្រសិទ្ធភាពនៃកម្មវិធី គ្រូជំនាញត្រូវបានផ្តល់អាទិភាពមិនត្រឹមតែផ្តល់វិជ្ជាសម្បទាប៉ុណ្ណោះទេ តែមានទាំងបំណិនសម្បទា សម្រាប់តម្រូវការប្រចាំថ្ងៃ និងអនាគតទៀត ផង។ ទោះយ៉ាងណា មុខវិជ្ជាដែលចាំបាច់សម្រាប់សិស្សអនុវិទ្យាល័យនៅកម្ពុជា ត្រូវបានបង្ហាញថាមិនសូវមានការយកចិត្តទុកដាក់ ពាក់ព័ន្ធនឹងការគាំទ្រផ្នែកពិនិត្យតាមដាន និងវាយតម្លៃ ការគាំទ្រហេដ្ឋារចនាសម្ព័ន្ធនិងការគាំទ្រជំនាញវិជ្ជាជីវៈ។ ដោយសារការគាំទ្រនិងការតម្រង់ទិសវិជ្ជាជីវៈដល់អ្នកចូលរួមទាំងអស់មិនគ្រប់គ្រាន់ ជាឫសគល់យ៉ាងសំខាន់ធ្វើឱ្យការអនុវត្តការអប់រំបំណិនជីវិតមិនអាចអនុវត្តបានល្អនៅគ្រប់កម្រិត។

លើសពីនេះទៀត គ្រូបានអះអាងថាការអនុវត្តកំពុងជួបប្រទះនូវឧបសគ្គជាច្រើនក្នុងការផ្ទេរចំណេះដឹងដែលបានរៀនទៅក្នុងការអនុវត្តជាក់ស្តែង។ ជាទូទៅ ការបង្រៀនទាមទារឱ្យមានការបែងចែកពេលវេលាសមស្រប សម្ភារៈ និងកន្លែងសមស្របសម្រាប់អនុវត្ត។ ទោះយ៉ាងណារបាយការណ៍ទាំងនោះបានបញ្ជាក់ថាតម្រូវការនៅតាមសាលារៀននីមួយៗ មិនទាន់ត្រូវបានបំពេញនៅឡើយទេ។ អាស្រ័យហេតុនេះ មុខវិជ្ជាដូចជាកសិកម្មដែលហាក់ដូចជាបានអនុវត្តច្រើនជាងគេដោយសារតែមុខវិជ្ជានេះមានភាពងាយស្រួលក្នុងការកៀរគរធនធាននៅតាមតំបន់របស់ ប៉ុន្តែសម្រាប់មុខវិជ្ជាដទៃទៀតត្រូវបានគេរាយការណ៍ថាមានឱកាសតិចក្នុងការអនុវត្តខណៈដែលមុខវិជ្ជាទាំងនោះទាមទារឱ្យគ្រូមានសមត្ថភាព កន្លែង និងសម្ភារៈ ប៉ុន្តែវាមិនងាយក្នុងការរៀបចំ ដូច្នេះសកម្មភាពនេះមិនអាចប្រព្រឹត្តទៅបានរលូនទេ។ ទាក់ទងនឹងគ្រូជំនាញ ការសិក្សានេះក៏បញ្ជាក់ថាមិនមានគ្រប់គ្រាន់ដែរ។ ការអះអាងនេះហាក់ជាមានភាពស្របគ្នានឹងការ

សិក្សាមុនៗ ដែលបានបង្ហាញពីបញ្ហាប្រឈមសំខាន់ៗដែលកើតឡើងក្នុងពេលអនុវត្តការអប់រំបំណិនជីវិត។ បើទោះបីជាយ៉ាងនេះក្រសួងអប់រំ យុវជន និងកីឡាបានផ្តោតសំខាន់លើកំណែទម្រង់ការបណ្តុះបណ្តាលគ្រូជាអាទិភាពក៏ដោយ គេសង្កេតឃើញថាការបណ្តុះបណ្តាលគ្រូមុខវិជ្ជាកសិកម្ម កុំព្យូទ័រ និងរោងជាងមិនត្រូវបានរាប់បញ្ចូលនៅឡើយទេ។

ចុងក្រោយ ចំណុចដែលជាឧបសគ្គមួយទៀតគឺការពិនិត្យតាមដាននិងវាយតម្លៃ។ គេបានរកឃើញថាទាំងអ្នកគាំទ្រខាងក្រៅនិងខាងក្នុងរាយការណ៍ថាបានពិនិត្យតាមដាន និងវាយតម្លៃការអនុវត្ត។ ដោយឡែក វិធីសាស្ត្រដែលបានអនុវត្តកន្លងមកមិនមានលក្ខណៈជាប្រព័ន្ធ ពោលគឺមិនមានឧបករណ៍មាត្រដ្ឋាន និងដំណើរការទៀងទាត់ទេ។ ឧបករណ៍ទាំងនេះមិនទាន់បានបង្ហាញ និងផ្តល់ឱ្យបានសមស្របនៅឡើយ។ លើសពីនេះទៅទៀត គ្រូបានពិនិត្យតាមដាន និងវាយតម្លៃការរីកចម្រើនរបស់សិស្សតាមរយៈការធ្វើតេស្តប្រចាំខែ ដោយវាស់វិជ្ជាសម្បទាជាមូលដ្ឋាន មិនមែនបំណិនសម្បទារបស់ពួកគេដែលបានរៀននៅក្នុងថ្នាក់នោះទេ។ ចំណុចទាំងនោះហាក់ស្របនឹងការអះអាងខាងលើស្តីពីការអនុវត្តមិនមានលក្ខណៈជាប្រព័ន្ធ។

### ៤.៦.២ ការពិភាក្សាពីតម្រូវការជំនាញ

ជាការឆ្លើយតបនឹងតម្រូវការនៃការរីកចម្រើនយ៉ាងខ្លាំងនៅកម្ពុជា ការបំពាក់វិជ្ជាសម្បទា និងបំណិនសម្បទា (ឧ.ជំនាញទន់)ដល់សិស្សហាក់នៅមិនទាន់បានបំពេញនូវតម្រូវការនៅឡើយទេ។ ហេតុដូច្នេះជំនាញបច្ចេកទេសដើរតួនាទីយ៉ាងសំខាន់ដើម្បីលើកកម្ពស់សេដ្ឋកិច្ចកម្ពុជា។ ជំនាញកុំព្យូទ័រត្រូវបានផ្តោតខ្លាំង។ វាពិតជាសារៈសំខាន់ខ្លាំងណាស់ ខណៈដែលប្រទេសកម្ពុជាក៏ដូចជាពិភពលោកកំពុងត្រៀមសំរាប់បដិវត្តឧស្សាហកម្ម៤.០ ដែលពិភពការងារ និងការសិក្សារៀនសូត្រនាពេលអនាគតនឹងត្រូវអនុវត្តតាមបែបបច្ចេកវិទ្យា។ យ៉ាងណាមិញ ជំនាញនេះមិនត្រូវបានអនុវត្ត និងគ្របដណ្តប់បានល្អនៅគ្រប់សាលារៀនទាំងអស់នោះទេ ជាពិសេសនៅតាមតំបន់ជនបទដោយសារតែលទ្ធភាពក្នុងការទទួល អនុវត្ត គុណភាព និងអភិបាលកិច្ច និងឧបសគ្គផ្នែកហិរញ្ញប្បទាន ដូចដែលបានបញ្ជាក់ក្នុង ៤.២.២។ ម្យ៉ាងវិញទៀត រាល់តម្រូវការទាំងនោះ មិនគួរគេមិនយកចិត្តទុកដាក់ ដូចដែលអង្គការពលកម្មអន្តរជាតិ បានព្យាករថាកម្លាំងពលកម្មនៅកម្ពុជា ៥៧ ភាគរយ ប្រឈមនឹងហានិភ័យខ្ពស់នៃផ្នែកប្រព័ន្ធស្វ័យប្រវត្តិកម្ម ការអភិវឌ្ឍបច្ចេកវិទ្យានៅគ្រប់វិស័យសេដ្ឋកិច្ច (អង្គការពលកម្មអន្តរជាតិ, ឆ្នាំ២០១៧)។ ដោយមើលឃើញដូច្នេះ កម្ពុជាគួរតែរៀបចំ និងជំរុញការចូលរួមរបស់យុវជនដើម្បីពង្រឹងជំនាញទាំងនោះដើម្បីត្រៀមខ្លួនសម្រាប់បដិវត្តន៍ទីផ្សារការងារនាពេលអនាគត។ ជំនាញមួយទៀត

ដែលត្រូវពិចារណាគឺកសិកម្ម។ ចំនួនការងារក្នុងវិស័យឧស្សាហកម្ម[9] ឆ្នាំ២០០៩-២០១៣ បាន បង្ហាញថាវិស័យកសិកម្ម (៤៨,៧ភាគរយ) មានឥទ្ធិពលលើឧស្សាហកម្ម (១៩,៩ភាគរយ) និងសេវាកម្ម (៣១.៥ភាគរយ) ខណៈសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកជាចម្បងលើវិស័យនោះ។ ជាមួយគ្នានេះផងដែរគេហវិទ្យាក៏ចាំបាច់ណាស់សម្រាប់ជីវភាពប្រចាំថ្ងៃជាពិសេសសម្រាប់សិស្សស្រី។ នៅក្នុងបរិបទប្រទេសកម្ពុជា មុខវិជ្ជានេះ ត្រូវបានគេចាត់ទុកជាបំណិនអាជីពងាយៗដែលបង្រៀននៅកម្រិតអនុវិទ្យាល័យ។ ការសិក្សាមុខវិជ្ជានេះពិតជាមានលក្ខណៈជាបុគ្គលសម្រាប់អ្នកសិក្សាដើម្បីអនុវត្តក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។ ម៉្យាងទៀត ការរៀនមុខវិជ្ជានេះក្នុងដំណាក់កាលនេះ អាចជាបំណិនមូលដ្ឋានមួយ និងជំរុញពួកគេឱ្យខិតខំរៀនសូត្រនៅសាលាបច្ចេកទេស។ ជាការពិតណាស់ បំណិនទាំងនេះត្រូវបានណែនាំឱ្យដាក់បញ្ចូលក្នុងកម្មវិធីសិក្សាកន្លងមក ប៉ុន្តែវានៅតែមានជួបប្រទះឧបសគ្គនៅឡើយដោយសារសិស្សភាគច្រើនរាយការណ៍ថាមិនសូវមានឱកាសសម្រាប់ការអនុវត្ត។ យោងទៅតាម ជំនាញដែលជាតម្រូវការទាំងអស់ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សារួចហើយ ដោយឡែកការអនុវត្តជាក់ស្តែងហាក់មិនមានការយកចិត្តទុកដាក់ ខណៈពេលដែលបំណិនមូលដ្ឋានត្រូវបានផ្តោតខ្លាំង។

ជាលទ្ធផល ការសិក្សានេះមានគោលបំណងដាស់តឿនដល់អ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់ឱ្យពិចារណាឡើងវិញ ដើម្បីជំរុញការអនុវត្តទាំងជំនាញបច្ចេកទេសឬបំណិនជីវិតតាមមូលដ្ឋានឱ្យមានភាពសកម្មនិងមានប្រសិទ្ធភាព។

9 Cambodia Socio-Economic Survey 2013

# ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋានរួម

ការសិក្សាស្រាវជ្រាវនេះ បានជួយបង្កើនការយល់ដឹងឱ្យកាន់តែស៊ីជម្រៅអំពីការអនុវត្តការអប់រំបំណិនជីវិតនៅមធ្យមសិក្សាបឋមភូមិដោយបង្ហាញពី (១)បញ្ហាប្រឈមក្នុងការអនុវត្តការអប់រំបំណិនជីវិត (២)បំ ណិនជីវិតដែលចាំបាច់ និង(៣)បទអន្តរាគមន៍ជាយុទ្ធសាស្ត្រលើកកម្ពស់ការអនុវត្ត។ ដូច្នេះ ការសន្និដ្ឋានសម្រាប់ការសិក្សាស្រាវជ្រាវនេះ បានសង្ខេបនូវខ្លឹមសារទាំងស្រុង និងបង្ហាញនូវលទ្ធផលសំខាន់ៗ។ របាយការណ៍នេះក៏បានបង្ហាញពីដែនកំណត់នៃការសិក្សាដែលជាឧបសគ្គមិនអាចដោះស្រាយបានក្នុងការសិក្សាតែមួយ។ នៅចុងបញ្ចប់នៃជំពូកនេះ ក៏បានបញ្ចូលនូវអនុសាសន៍មួយចំនួនសម្រាប់ការស្រាវជ្រាវបន្ថែម។

ទាក់ទងនឹងរបកគំហើញនេះ ការអនុវត្តការអប់រំបំណិនជីវិតមិនទាន់អនុវត្តបានតាមការរំពឹងទុកដើម្បីផ្តល់ជូនអ្នកសិក្សានូវបំណិនចាំបាច់ដើម្បីបំពេញតាមតម្រូវការតាមមូលដ្ឋាន និងតម្រូវការនាពេលអនាគត។ ផ្អែកលើលទ្ធផលដែលបានរកឃើញ បញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពនៃអនុវត្តកម្មវិធីបានកើតឡើងស្ទើរតែគ្រប់សាលាគោលដៅ។ របកគំហើញនៃការសិក្សានេះត្រូវបានបញ្ជាក់ដូចគ្នានឹងការសិក្សានិងរបាយការណ៍មុនៗ ហើយបញ្ហាដែលត្រូវបានលើកឡើងដោយភាពពាក់ព័ន្ធទាំងអស់ មិនគួរត្រូវបានគេទុកចោលនោះទេ។ ស្របពេលជាមួយគ្នានេះគេសង្កេតឃើញថាការយកចិត្តទុកដាក់ភាគច្រើនត្រូវបានគេផ្តោតទៅលើបំណិនមូលដ្ឋានដូចជាជំនាញទន់ ចំណែកបំណិនអាជីពងាយៗដែលអនុវត្តនៅអនុវិទ្យាល័យហាក់មិនសូវមានការយកចិត្តទុកដាក់។ ការសិក្សានេះបានរកឃើញនូវបញ្ហាប្រឈមជាច្រើន ដែលបានបង្ហាញថាភាពជាអ្នកដឹកនាំនិងការប្រតិបត្តិនៅតែបញ្ហា និងមិនទាន់មានភាពឆ្លើយតប ព្រោះវាទាមទារឱ្យមានការចូលរួមខ្ពស់នៅគ្រប់កម្រិតដើម្បីធានាថា រាល់ព័ត៌មានទាំងអស់ត្រូវបានផ្សព្វផ្សាយទូលំទូលាយ និងយល់បានល្អ ហើយការប្រតិបត្តិត្រូវធ្វើយ៉ាងណាឱ្យមានធនធានដែលមានសមត្ថភាព សម្ភារៈ និងគ្រឿងបរិក្ខារគ្រប់គ្រាន់។ លើសពីនេះទៀត ការអនុវត្តកម្មវិធីកន្លងមកមិនទាន់បំពេញតម្រូវការមូលដ្ឋាន ខណៈដែលបំណិនភាគច្រើនបានស្នើឱ្យមានការជួយសម្របសម្រួល និងពង្រឹងមុខវិជ្ជាសំខាន់ៗមួយចំនួនសម្រាប់សិស្ស។ មុខវិជ្ជាដែលចាំបាច់ខ្លាំងត្រូវបានបញ្ជាក់ថាមុខវិជ្ជាកុំព្យូទ័រ ហើយមុខវិជ្ជាកសិកម្ម គេហវិទ្យា រោងជាង សិល្បៈ និងមុខវិជ្ជាផ្សេងទៀត ក៏ទាមទារឱ្យមានការយកចិត្តទុកដាក់ផងដែរ។ ជំនាញទាំងនោះតម្រូវឱ្យអ្នកចូលរួមទាំងអស់ព្រមព្រៀងគ្នាក្នុងការកែប្រែប្រធានបទឬខ្លឹមសារណាមួយ

ដែលសមស្របសម្រាប់តម្រូវការជាក់លាក់តាមតំបន់នីមួយៗ។ ការរកឃើញនេះហាក់ឆ្លើយតបនឹងអំណះអំណាងដែលថា ការអនុវត្តការអប់រំបំណិនជីវិតមិនមានភាពឆ្លើយតបនឹងតម្រូវការសិស្ស ក៏ដូចជាតម្រូវការតាមមូលដ្ឋាន។ ដោយឡែក អ្នកចូលរួមទាំងអស់ក៏បានរាយការណ៍ថាបានធ្វើអន្តរាគមន៍មួយចំនួនដើម្បីធ្វើឱ្យកម្មវិធីនោះបន្តអនុវត្តរហូតមកដល់បច្ចុប្បន្ន។ ការលើកឡើងបែបនោះ ហាក់បង្ហាញថាអន្តរាគមន៍ដែលបានធ្វើកន្លងមកមិនទាន់លក្ខណៈគ្រប់គ្រាន់ និងជាយុទ្ធសាស្ត្រនៅឡើយទេ ដូច្នេះវាតម្រូវឱ្យមានការយកចិត្តទុកដាក់ និងអន្តរាគមន៍បន្ថែមទៀតដើម្បីដោះស្រាយឧបសគ្គទាំងនោះ។

## ៥.២ ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

មានចំណុចខ្វះខាតមួយចំនួននៅតែកើតឡើងសម្រាប់ការសិក្សានេះដោយមិនអាចចៀសបាននោះទេ។ ជាបឋម ចំណុចទាំងនោះទាក់ទងទៅនឹងបញ្ហាវិធីសាស្ត្រដែលប្រើក្នុងការសិក្សានេះ បញ្ហាមួយក្នុងចំណោមបញ្ហាគួរឱ្យកត់សម្គាល់នៅក្នុងការសិក្សានេះ ទាក់ទងនឹងចំនួនសំណាកគម្រូ។ ដូចដែលបានរៀបរាប់ខាងលើ ការអប់រំបំណិនជីវិតបានអនុវត្តកន្លងមកទាំងនៅកម្រិតបឋមសិក្សានិងមធ្យមសិក្សាបឋម

ភូមិ។ ក្នុងពេលជំណាលគ្នាដែរ មានសាលារៀនចំនួន ១០០ ដែលបានរាយការណ៍ថាបានទទួលការគាំទ្រដោយដៃគូអភិវឌ្ឍន៍ផ្សេងៗដើម្បីទ្រទ្រង់កម្មវិធីនេះ។ ដោយឡែក មានតែអនុវិទ្យាល័យមួយចំនួនមកពីខេត្តផ្សេងៗគ្នាប៉ុណ្ណោះ ដែលត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងការសិក្សានេះ ហើយដៃគូអភិវឌ្ឍន៍ក៏មិនបានរាប់បញ្ចូលសម្រាប់ការវិភាគនេះដែរ ដោយសារតែបញ្ហាពេលវេលាដែលមិនអាចឱ្យការសិក្សានេះគ្របដណ្តប់បានច្រើន។ បញ្ហាសំខាន់មួយទៀតទាក់ទងនឹងការវិភាគទិន្នន័យ។ ជាក់ស្តែង ទិន្នន័យត្រូវបានវិភាគដោយផ្តោតខ្លាំងលើវិធីសាស្ត្របែបបរិមាណវិស័យ ខណៈដែលកម្រងសំណួរបានរៀបចំឡើងនិងមានសំណួរគន្លឹះមួយចំនួនដើម្បីឆ្លើយសំណួរនៃការស្រាវជ្រាវ។ ទោះយ៉ាងណា ការសិក្សាហាក់នៅមានការខកខានសម្រាប់បទសម្ភាសន៍ស៊ីជម្រៅដែលហៅថា វិធីសាស្ត្របែបគុណវិស័យដើម្បីបញ្ជាក់ថារបកគំហើញមានលក្ខណៈកាន់តែលម្អិត។ ក្នុងន័យនេះ តម្រូវឱ្យមានការស្រាវជ្រាវបន្តទៀតដើម្បីបញ្ជាក់បន្ថែម។ ដើម្បីការពារភាពខ្វះចន្លោះ អ្នកស្រាវជ្រាវក៏បានបញ្ជាក់ពីចំណុចមួយចំនួនដែលចាំបាច់។

លើសពីនេះទៀត ការសិក្សានេះបានកំណត់ព្រំដែននៃគោលបំណងដោយផ្តោតលើការបង្ហាញពីស្ថានភាពបច្ចុប្បន្ននៃការអនុវត្តការអប់រំបំណិន ដែលបញ្ហាប្រឈមសំខាន់ៗមួយចំនួន

ហាក់ដូចជាត្រូវបានកំណត់មិនទាន់មានភាពច្បាស់លាស់។ សំខាន់ជាងនេះទៅទៀត ការសិក្សាបានផ្តោតសំខាន់លើបំណិនអាជីពងាយៗ និងដាក់បញ្ចូលទៅក្នុងការវិភាគខណៈពេលដែលបំណិនទាំងនោះមិនសូវការចាប់អារម្មណ៍។ យ៉ាងណាមិញ ការសិក្សាមិនមានបំណងពង្រីកការវិភាគតាមបែបស្ថិតិសន្និដ្ឋានដែលពិនិត្យលើភាពខុសគ្នា ក៏ដូចជាការទំនាក់ទំនងរវាងចំណុចដែលត្រូវវិភាគឡើយ ខណៈដែលការសិក្សាបែបនោះហាក់ដូចជាមិនបានចូលរួមចំណែកដល់សារៈសំខាន់នៃការសិក្សាបច្ចុប្បន្ននេះទេ។ ចំណុចទាំងនេះគួរតែត្រូវបានស្នើសម្រាប់ការសិក្សាបន្តទៀត។

## ៥.៣ អនុសាសន៍សម្រាប់បទអន្តរាគមន៍ជាយុទ្ធសាស្ត្រ

យោងទៅតាមដែនកំណត់ និងលទ្ធផលនៃការសិក្សានេះ ក្រុមអ្នកស្រាវជ្រាវបានសំយោគរាល់មតិយោបល់ដែលផ្តល់ដោយអ្នកចូលរួមសំខាន់ៗ រួមជាមួយទស្សនៈផ្ទាល់ខ្លួនរបស់ក្រុមស្រាវជ្រាវសម្រាប់អ្នកពាក់ព័ន្ធក្នុងការអនុវត្ត ដើម្បីចាត់វិធានការលើកកម្ពស់ការអនុវត្តការអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិ។ ដើម្បីសំរេចបាននូវចេតនានេះ ទាមទារអោយមានការសម្របសម្រួល និងការប្តេជ្ញាចិត្តមុតមាំពីសំណាក់អ្នកគាំទ្រនិងអ្នកអនុវត្ត។

### ក) ក្រសួង.អយក (នាយកដ្ឋានពាក់ព័ន្ធ)

*ក១) ភាពជាអ្នកដឹកនាំ*

- ធានាថាយុទ្ធសាស្ត្រគោលនយោបាយអាចអនុវត្តបាន
- ធានាថាបំណិនអាជីពងាយៗត្រូវបានផ្តល់អាទិភាព
- ធានាថារាល់ឯកសារគតិយុត្តពាក់ព័ន្ធត្រូវបានផ្សព្វផ្សាយ និងតម្រង់ទិសឱ្យបានច្បាស់មុនពេល អនុវត្ត
- ធានានូវការបន្តគាំទ្រដល់សាលារៀនដែលមិនធ្លាប់បានទទួល។

*ក២) ការគ្រប់គ្រងធនធានមនុស្ស*

- រៀបចំក្រុមឬគណៈកម្មការបច្ចេកទេសដើម្បីគាំទ្រ (ឧ. ការប្រតិបត្តិ និងការណែនាំ) និងការអនុវត្តការពិនិត្យតាមដាននិងវាយតម្លៃជាប្រចាំ

ជ្រើសរើសគ្រូបំណិនអាជីពងាយៗ និងរៀបចំការបណ្តុះបណ្តាលគ្រូឱ្យបានត្រឹមត្រូវ

ធានាថាការបណ្តុះបណ្តាលការងារត្រូវបានធ្វើឡើងជាលក្ខណៈប្រព័ន្ធដើម្បីកសាងនិង

ពង្រឹងសមត្ថភាពអ្នកពាក់ព័ន្ធទាក់ទងនឹងការអប់រំបំណិនជីវិត។

*ក៣) ធនធាន*

- ធានាឱ្យបាននូវគោលការណ៍ណែនាំ ឬក្របខ័ណ្ឌនៃការ ពិនិត្យតាមដាននិងវាយតម្លៃត្រូវបានបង្កើតឡើងដោយផ្តោតលើបំណិនជីវិតតាមមូលដ្ឋាន
- បែងចែករាលឯកសារគតិយុត្តពាក់ព័ន្ធនឹងបំណិនជីវិតតាមមូលដ្ឋាន ដូចជាឯកសារគោលនយោបាយ គោលការណ៍ណែនាំ ក្របខណ្ឌ សេចក្តីណែនាំ កម្មវិធីសិក្សា ទៅដល់អ្នកពាក់ព័ន្ធសំខាន់
- ជួយនិងសម្រួលសម្ភារៈ និងបរិក្ខារដែលចាំបាច់សម្រាប់អ្នកអនុវត្តជាពិសេសដើម្បីធានាឱ្យបានការសិក្សាសម្រាប់សតវត្សរ៍ទី ២១
- បែងចែកការគាំទ្រថវិកាសម្រាប់ការអនុវត្តការអប់រំបំណិនជីវិត និងធានាថាអ្នកអនុវត្តមានស្វ័យភាព។

**ខ) ថ្នាក់មន្ទីរ.អយក និង ថ្នាក់ការិយាល័យ.អយក**

*ខ១) ភាពជាអ្នកដឹកនាំ*

- ធានាថារាល់ឯកសារគតិយុត្តពាក់ព័ន្ធនានាត្រូវបានផ្សព្វផ្សាយ និងតម្រង់ទិសឱ្យបានល្អមុនពេលអនុវត្តនៅកម្រិតសាលា
- ស្នើគំនិតផ្តួចផ្តើមផ្សេងៗដើម្បីជួយកែលំអសាលារៀនអោយកាន់តែមានការប្រកួតប្រជែង
- ធានានូវការគាំទ្រនិរន្តរភាពសម្រាប់សាលារៀនដែលមិនធ្លាប់ទទួលបានការគាំទ្រ។

*ខ២) ការគ្រប់គ្រងធនធានមនុស្ស*

- រៀបចំក្រុមបច្ចេកទេសដើម្បីគាំទ្រ (ឧ.ការប្រតិបត្តិ និងការណែនាំ) និងតាមដាននិងវាយតម្លៃការអនុវត្តជាប្រចាំ
- សម្របសម្រួលក្នុងការជ្រើសរើសគ្រូបំណិនអាជីពងាយៗទាំងផ្លូវការ (ការបណ្តុះបណ្តាលមុនពេលផ្តល់សេវាកម្ម) និងក្រៅផ្លូវការ (ឧ.អ្នកជំនាញដៃគូអភិវឌ្ឍន៍ និងសហគមន៍)
- ធានាថាការបណ្តុះបណ្តាលការងារត្រូវបានធ្វើឡើងជាលក្ខណៈប្រព័ន្ធដើម្បីកសាងនិង

ពង្រឹងសមត្ថភាពរបស់អ្នកពាក់ព័ន្ធទាក់ទងនឹងការបង្រៀនបំណិនអាជីពងាយៗ។

*ខ៣) ធនធាន*

- បែងចែកឯកសារគតិយុត្តពាក់ព័ន្ធនានា (ឧ. គោលនយោបាយ គោលការណ៍ ក្របខ័ណ្ឌណែនាំ កម្មវិធីសិក្សា) ដល់អ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់
- ជួយរៀបចំសម្ភារៈ និងបរិក្ខារដែលចាំបាច់សំរាប់អ្នកអនុវត្ត
- ធានាលំហូរនៃការអនុវត្តដោយថវិកាគាំទ្រសម្រាប់ដំណើរការទាំងមូលនៃការអនុវត្ត។

**គ) នាយកឬនាយិកាសាលា**

*គ១) ភាពជាអ្នកដឹកនាំ*

- ធានាភាពជាអ្នកដឹកនាំសាលាប្រកបដោយប្រសិទ្ធភាព
    - ◇ ផ្សព្វផ្សាយរាល់ឯកសារគតិយុត្តពាក់ព័ន្ធនានា (ឧ. គោលនយោបាយ គោលការណ៍ ក្របខ័ណ្ឌ ណែនាំ កម្មវិធីសិក្សា) ដល់គ្រូ
    - ◇ មានសមត្ថភាពក្នុងការគ្រប់គ្រងរដ្ឋបាលនិងហិរញ្ញវត្ថុដើម្បីតម្រឹមធនធានជាមួយវិធីសាស្រ្តដែលជាអាទិភាព។
    - ◇ ពង្រឹងកិច្ចសហការរវាងគ្រូនិងសហគមន៍ដើម្បីបង្កើនការរៀនបំណិនអាជីពងាយៗតាមរយៈវិធីសាស្រ្តបង្រៀនប្រកបដោយភាពច្នៃប្រឌិតនិងថ្នាក់រៀនដែលសំបូរទៅដោយធធាន
    - ◇ ទាក់ទាញសហគមន៍ឱ្យចូលរួមក្នុងការអនុវត្តគោលការណ៍ពិនិត្យតាមដាននិងវាយតម្លៃគ្រូប្រកបដោយប្រសិទ្ធភាព និងនិរន្តភាព
    - ◇ ធ្វើស្វ័យភាពនិងផ្តួចផ្តើមដើម្បីកំណត់សកម្មភាពនិងកម្មវិធីសិក្សាសម្រាប់អនុវត្តការអប់រំបំណិនជីវិតនៅតាមសាលារៀន និងធានាថាប្រធានបទឆ្លើយតបទៅនឹងតម្រូវការក្នុងមូលដ្ឋាន និងទីផ្សារនាពេលអនាគត
    - ◇ បញ្ចូលសកម្មភាពអនុវត្តការអប់រំបំណិនជីវិតនៅក្នុងផែនការប្រតិបត្តិការ
    - ◇ ធ្វើជាអ្នកណែនាំសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូ។

## គ២) ការគ្រប់គ្រងធនធានមនុស្ស

- ពិនិត្យតាមដាននិងវាយតម្លៃគ្រូបំណិនអាជីពងាយៗជាប្រចាំ និងផ្តល់នូវមតិស្ថាបនា
- ធានាថាការបណ្តុះបណ្តាលការងារត្រូវបានធ្វើឡើងជាលក្ខណៈប្រព័ន្ធដើម្បីកសាងនិងលើកកម្ពស់សមត្ថភាពរបស់គ្រូទាក់ទងនឹងការបង្រៀនជំនាញវិជ្ជាជីវៈសាមញ្ញ
- រៀបចំគ្រូមុខជំនាញផ្សេងទៀតដើម្បីជំនួសប្រសិនបើមិនមានគ្រូបំណិនជីវិតគ្រប់គ្រាន់ (ត្រូវប្រាកដថាពួកគេធ្លាប់បានទទួលការណែនាំ)។

*គ៣) ធនធាន*

- ដាក់ឯកសារគតិយុត្តពាក់ព័ន្ធនានា (ឧ. គោលនយោបាយ គោលការណ៍ ក្របខ័ណ្ឌណែនាំ កម្មវិធីសិក្សា) នៅតាមសាលារៀនសម្រាប់អ្នកអនុវត្តជាឯកសារយោង
- ជួយរៀបចំសម្ភារៈ និងបរិក្ខារដែលចាំបាច់សំរាប់អ្នកអនុវត្ត
- ស្វយ័តថវិកាគាំទ្រសម្រាប់ដំណើរការទាំងមូលនៃការអនុវត្តយ៉ាងហ្មត់ចត់។

## ឃ) គ្រូ

*ឃ១) ភាពជាអ្នកដឹកនាំ*

- ចូលរួមក្នុងការដឹកនាំសាលាប្រកបដោយប្រសិទ្ធភាព
    - ◇ ចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងការរៀបចំនិងការគ្រប់គ្រងផែនការប្រតិបត្តិសាលារៀនដើម្បីកំណត់ទិសដៅជាយុទ្ធសាស្ត្រសម្រាប់ការកែលម្អសាលារៀន
    - ◇ ពង្រឹងកិច្ចសហការរវាងគ្រូនិងសហគមន៍ដើម្បីបង្កើនការរៀនបំណិនអាជីពងាយៗតាមរយៈវិធីសាស្ត្របង្រៀនប្រកបដោយភាពច្នៃប្រឌិតនិងថ្នាក់រៀនដែលសំបូរទៅដោយធនធាន
    - ◇ ចូលរួមក្នុងដំណើរការនៃការជ្រើសរើសប្រធានបទអប់រំបំណិនជីវិតដើម្បីឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាន និងទីផ្សារនាពេលអនាគត
    - ◇ ចូលរួមក្នុងដំណើរការពិនិត្យតាមដាននិងវាយតម្លៃដោយអ្នកពាក់ព័ន្ធសំខាន់ៗ

◇ ចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយរាល់ព័ត៌មានពាក់ព័ន្ធពីសាលារៀនដល់សហគមន៍និងព័ត៌មានត្រឡប់មកវិញ។

*ឃ២) ការពង្រឹងសមត្ថភាពវិជ្ជាជីវៈ*

- ធានាថាការអប់រំបំណិនជីវិតវិធីសាស្ត្របង្រៀនដែលមានលក្ខណៈពិតជាក់ស្តែងត្រូវបានប្រើប្រាស់នៅក្នុង (ឧ.វិធីសាស្ត្របង្រៀនបែបរិះរក)
- បន្តការសិក្សាពេញមួយជីវិតដោយខ្លួនឯង និងដោយវិជ្ជាជីវៈ
- ពិនិត្យតាមដាន និងវាយតម្លៃការរៀនរបស់សិស្សជាមួយនឹងឧបករណ៍ជាក់លាក់ និងផ្តល់ព័ត៌មានត្រឡប់ប្រកបដោយប្រសិទ្ធភាព
- ផ្តួចផ្តើមសកម្មភាពនានា ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់សិស្សក្នុងការរៀនបំណិនជីវិត និងធានាបរិយាកាសសិក្សាតាមបែបសតវត្សរ៍ទី ២១។
- សហការជាមួយសហសេវិកដទៃទៀតទាំងក្នុងនិងក្រៅដើម្បីធានាមានការអភិវឌ្ឍវិជ្ជាជីវៈ។

*ឃ៣) ការប្រើប្រាស់ធនធាន*

- បង្កើត និងធ្វើមូលដ្ឋានីយកម្មធនធានប្រើប្រាស់សម្រាប់គ្រូដើម្បីជំរុញការបង្រៀននិងរៀនបំណិនជីវិត
- ស្នើសុំ និងប្រមូលធនធានពីប្រភពផ្សេងៗ
- ស្នើសុំសាលារៀនសម្រាប់ការបែងចែកថវិកាដើម្បីទិញសម្ភារៈបរិក្ខារ និងដោះស្រាយបញ្ហាចម្បងៗដែលជាប់ទាក់ទងនឹងការអនុវត្តការអប់រំបំណិនជីវិតប្រកបដោយប្រសិទ្ធភាព។

**ង) គណៈកម្មការទ្រទ្រង់សាលា**

*ង១) ភាពជាអ្នកដឹកនាំ*

- ធានាភាពជាអ្នកដឹកនាំសាលាប្រកបដោយប្រសិទ្ធភាព

  ◇ ចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងការរៀបចំនិងការគ្រប់គ្រងផែនការប្រតិបត្តិការសាលារៀនដើម្បីកំណត់ទិសដៅជាយុទ្ធសាស្ត្រសម្រាប់ការកែលម្អសាលារៀន

◇ បង្កើនកិច្ចសហការរវាងសាលារៀន និងសហគមន៍ដើម្បីបង្កើនការរៀនបំណិនអាជីពងាយតាមរយៈវិធីសាស្ត្របង្រៀនប្រកបដោយភាពច្នៃប្រឌិត និងថ្នាក់រៀនដែលសំបូរទៅដោយធនធាន

◇ ចូលរួមក្នុងការពិនិត្យនិងវាយតម្លៃគ្រូនិងការអនុវត្តសាលារៀនជាពិសេសការអនុវត្តការអប់រំបំណិនជីវិត

◇ ផ្សព្វផ្សាយរាល់ព័ត៌មានពាក់ព័ន្ធទាំងអស់ពីសាលារៀនដល់សហគមន៍និងព័ត៌មានត្រឡប់មកវិញ។

*ង២) ការគ្រប់គ្រងធនធានមនុស្ស*

• ពិនិត្យតាមដាននិងវាយតម្លៃគ្រូបំណិនអាជីពងាយៗជាប្រចាំ និងផ្តល់នូវមតិយោបល់ស្ថាបនាដើម្បីបង្កើនគុណភាពនៃការបង្រៀននិងរៀនបំណិនជីវិត

• ជួយជ្រើសរើសអ្នកជំនាញពីក្នុងសហគមន៍ និងដៃគូអភិវឌ្ឍន៍ដើម្បីចែករំលែកបទពិសោធន៍បំណិនជីវិតដើម្បីចូលរួមចំណែកក្នុងការអនុវត្តការបង្រៀន។

*ង៣) ធនធាន*

• ផ្តល់សម្ភារៈ និងបរិក្ខារដែលចាំបាច់សំរាប់អ្នកអនុវត្ត

• លើកទឹកចិត្តដល់គ្រូបំណិនជីវិតក្នុងរូបភាពណាមួយដោយស្នើសុំឱ្យសហគមន៍ចូលរួមវិភាគទាន

• ធានាលំហូរនៃការអនុវត្តដោយផ្តល់ថវិកាគាំទ្រសម្រាប់ដំណើរការអនុវត្តទាំងមូល។

**ច) សហគមន៍ (អាជ្ញាធរមូលដ្ឋាន និងអាណាព្យាបាល)**

*ច១) ភាពជាអ្នកដឹកនាំ*

• ធានាភាពជាអ្នកដឹកនាំសាលាប្រកបដោយប្រសិទ្ធភាព

◇ ចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងការរៀបចំនិងការគ្រប់គ្រង(ឧ.ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ) ដើម្បីកំណត់ទិសដៅជាយុទ្ធសាស្ត្រសម្រាប់ការកែលម្អសាលារៀន

• ពង្រឹងកិច្ចសហការរវាងគ្រូនិងសហគមន៍ដើម្បីបង្កើនការរៀនបំណិនអាជីពងាយៗ

តាមរយៈវិធីសាស្ត្របង្រៀនប្រកបដោយភាពច្នៃប្រឌិតនិងថ្នាក់រៀនដែលសំបូរទៅដោយធនធាន

◇ ចូលរួមក្នុងការពិនិត្យតាមដាននិងវាយតម្លៃគ្រូបំណិនអាជីពងាយៗ ការអនុវត្តរបស់សាលា និងសិស្សតាមរយៈការសិក្សាបំណិនជីវិតឱ្យបានទៀងទាត់

◇ លើកទឹកចិត្តគ្រូឱ្យចូលរួមក្នុងការអនុវត្តការអប់រំបំណិនជីវិត

◇ ធានាថារាល់ព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តការអប់រំបំណិនជីវិតត្រូវបានគេណែនាំ ពន្យល់និងយល់ស្រប។

*ច២) ការគ្រប់គ្រងធនធានមនុស្ស*

- ជួយជ្រើសរើសអ្នកជំនាញពីក្នុងសហគមន៍ និងដៃគូអភិវឌ្ឍន៍ដើម្បីចែករំលែកបទពិសោធន៍ក្នុងការអនុវត្តការអប់រំបំណិនជីវិតដើម្បីរួមចំណែកដល់ការអនុវត្តការបង្រៀន
- ផ្តល់ការប្រឹក្សាដល់គ្រូ និងសាលារៀន

*ច៣) ធនធាន*

- ផ្តល់ជូននូវសម្ភារៈ និងបរិក្ខារដែលចាំបាច់ដល់អ្នកអនុវត្ត
- សម្របសម្រួលនិងបង្កបរិយាកាសដែលគាំទ្រដល់ការអនុវត្តការអប់រំបំណិនជីវិតតាមតម្រូវការ
- លើកទឹកចិត្តដល់គ្រូបំណិនជីវិតតាមគ្រប់រូបភាពដោយស្នើសុំឱ្យសហគមន៍ចូលរួមវិភាគទាន
- ធានាលំហូរនៃការអនុវត្តដោយផ្តល់ថវិកាគាំទ្រសម្រាប់ដំណើរការទាំងមូលនៃការអនុវត្ត។

## ឯកសារយោង


Abobo, F. (2012). *Challenges Facing Implementatino of Life Skills Education in Secondary Schools in Trans-Nzoia West District, Kenya*. Kenyatta University.

Adhiambo, L. P. (2013). *Implementation of Life Skills Education in Secondary School in Uriri and Awendo Districts , Migori County Kenya*. Kenyatta University.

Adolescent Girls Initiative. (2013). *Life Skills: What are they, Why do they matter, andHow are they taught?* The World Bank.

Chirwa, G., & Naidoo, D. (2014). Structural and social constraints in the teaching of Life Skills for HIV / AIDS prevention in Malawi primary schools. *South African Journal of Child Hoor Education*, *4*(1), 61–79.

Department of Vocational Orientation. (2018). *Brief Report*.

ILO. (2017). *ASEAN IN TRANSFORMATION: HOW TECHNOLOGY IS CHANGING JOBS AND ENTERPRISES*.

Marieta M., K. (2014). *Factors Influencing the Implementation of Life Skills Education in Secondary Schools in Kinango District, Kwale County*.

MoEYS. (2004). Policy for Curriculum Development 2005-2009. In *MOEYS*.

MoEYS. (2006). Policy for Life Skills Education. In *Pedagogical Research Department, MOEYS*.

MoEYS. (2013). *Policy for Technical Education*.

MOEYS. (2017). *Guideline for Life Skills Education Practice (For Lower Secondary School)*.

Nasheeda, A., Abdullah, H. B., Krauss, S. E., & Ahmed, N. B. (2018). A narrative systematic review of life skills education: effectiveness, research gaps and priorities. *International Journal of Adolescence and Youth*, *3843*(May), 1–18. https://doi.org/10.1080/02673843.2018.1479278

Okech, D. O., & Role, E. M. (2016). Implications of Life Skills Education on Character

Development amongst children . A case of Hill School. *Baraton Interdisciplinary Research Journal*, (April 2015), 0–18.

Paola, M., Lane, M. A., & Bredenberg, K. (2012). *Life Skills Practices in Cambodia A Review of Implementation by NEP Members*.

Prajapati, R., Sharma, B., & Sharma, D. (2017). *Significance Of Life Skills Education*. *10*(1), 1–6.

UNESCO. (2015). *Education for All 2000-2015: Achievement and Challenges*.

UNICEF. (2012). Global Evaluation of Life Skills Education Programmes. In *Evaluation office*.

Wairimu, K. H. (2015). *FACTORS INFLUENCING IMPLEMENTATION OF LIFE SKILLS EDUCATION IN PRIMARY SCHOOLS IN STAREHE SUB-COUNTY , NAIROBI COUNTY KENYA BY KAMAU HELEN WAIRIMU A Research Project Submitted to the Department of Educational Foundations , in Partial Fulfillment of the Re*. Nairobi University.

WHO. (2005). Skills for health. In *Skills for Health Skills-based health education including life skills: An important component of a Child-Friendly/Health-Promoting School* (Vol. 12). https://doi.org/10.7748/nm.12.7.39.s23

ឧបសម្ព័ន្ធទី ១: សមាមាត្រចំនួនអ្នកចូលរួមរំពឹងទុក

| ខេត្ត | ស្រុក (D) | អនុវិទ្យាល័យ (L) | ថ្នាក់មន្ទីរ.អយក | ថ្នាក់ការិ.អយក | នាយកឬនាយិកាសាលា | គ្រូ | គណៈកម្មការទ្រទ្រង់សាលា | សិស្ស | អាជ្ញាធរមូលដ្ឋាន | អាណាព្យាបាល | ចំនួនអ្នកចូលរួមសរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | D_1 | L_1 | 1 | 1 | 1 | 3 | 1 | 6 | 1 | 3 | 17 |
| | | L_2 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | D_2 | L_3 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | D_3 | L_4 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | | L_5 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| 2 | D_4 | L_6 | 1 | 1 | 1 | 3 | 1 | 6 | 1 | 3 | 17 |
| | D_5 | L_7 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | | L_8 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | D_6 | L_9 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | | L_10 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| 3 | D_7 | L_11 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | | L_12 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | D_8 | L_13 | 1 | 1 | 1 | 3 | 1 | 6 | 1 | 3 | 17 |
| | D_9 | L_14 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | | L_15 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | D_10 | L_16 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | | L_17 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | D_11 | L_18 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | | L_19 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| 4 | D_12 | L_20 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | | L_21 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | | L_22 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | | L_23 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | D_13 | L_24 | 1 | 1 | 1 | 3 | 1 | 6 | 1 | 3 | 17 |
| 5 | D_14 | L_25 | 1 | 1 | 1 | 3 | 1 | 6 | 1 | 3 | 17 |
| | | L_26 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | D_15 | L_27 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | | L_28 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | D_16 | L_29 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | | L_30 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| 6 | D_17 | L_31 | 1 | 1 | 1 | 3 | 1 | 6 | 1 | 3 | 17 |
| | | L_32 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | | L_33 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | D_17 | L_34 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | | L_35 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| 7 | D_19 | L_36 | 1 | 1 | 1 | 3 | 1 | 6 | 1 | 3 | 17 |
| | | L_37 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | D_20 | L_38 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | D_21 | L_39 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | | L_40 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| 8 | D_22 | L_41 | 1 | 1 | 1 | 3 | 1 | 6 | 1 | 3 | 17 |
| | | L_42 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | D_23 | L_43 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | | L_44 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | D_24 | L_45 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | | L_46 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | D_25 | L_47 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | D_26 | L_48 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | | L_49 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| 9 | D_27 | L_50 | 1 | 1 | 1 | 3 | 1 | 6 | 1 | 3 | 17 |
| | | L_51 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| | D_28 | L_52 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 |
| | | L_53 | | | 1 | 3 | 1 | 6 | 1 | 3 | 15 |
| **ចំនួនអ្នកចូលរួមរំពឹងទុកសរុប** | | | 9 | 28 | 53 | 159 | 53 | 318 | 53 | 159 | **832** |

## ឧបសម្ព័ន្ធទី ២: ស្ថិតិបង្ហាញភាគរយកម្រងសំណួរដែលប្រើប្រាស់បាន

| ខេត្ត | ស្រុក (D) | អនុវិទ្យាល័យ (L) | ចំនួនកម្រងសំណួរដែលផ្ញើត្រឡប់មកវិញ | | | | | | | | សរុប (បំនែងចែក) | ភាគរយ % |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ថ្នាក់មន្ទីរ.អយក | ថ្នាក់ការិ. អយក | នាយកឬនាយិកាសាលា | គ្រូ | គណៈកម្មការទ្រទ្រង់ | សិស្ស | អាជ្ញាធរមូល | អាណាព្យា | | |
| 1 | D_1 | L_1 | 1 | 1 | 1 | 2 | 1 | 4 | 1 | 2 | 17 | 13 |
| | | L_2 | | | 1 | 2 | 1 | 6 | 1 | 1 | 15 | 12 |
| | D_2 | L_3 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 | 16 |
| | D_3 | L_4 | | 1 | 1 | 3 | 1 | 5 | 1 | 1 | 16 | 13 |
| | | L_5 | | | 1 | 3 | 0 | 5 | 0 | 1 | 15 | 10 |
| 2 | D_4 | L_6 | 1 | 1 | 1 | 4 | 1 | 3 | 1 | 3 | 17 | 15 |
| | D_5 | L_7 | | 1 | 1 | 3 | 0 | 4 | 1 | 2 | 16 | 12 |
| | | L_8 | | | 1 | 3 | 1 | 4 | 1 | 2 | 15 | 12 |
| | D_6 | L_9 | | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| | | L_10 | | 1 | 1 | 3 | 1 | 4 | 0 | 2 | 16 | 12 |
| 3 | D_7 | L_11 | | 1 | 1 | 3 | 1 | 8 | 1 | 3 | 16 | 18 |
| | | L_12 | | | 1 | 3 | 1 | 6 | 1 | 2 | 15 | 14 |
| | D_8 | L_13 | 1 | 1 | 1 | 3 | 0 | 6 | 2 | 3 | 17 | 17 |
| | D_9 | L_14 | | 1 | 1 | 2 | 1 | 6 | 1 | 2 | 16 | 14 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | L_15 | | | 1 | 3 | 1 | 6 | 1 | 3 | 15 | 15 |
| | D_10 | L_16 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 | 16 |
| | | L_17 | | | 1 | 3 | 1 | 6 | 1 | 2 | 15 | 14 |
| | D_11 | L_18 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 | 16 |
| | | L_19 | | | 1 | 3 | 1 | 6 | 1 | 3 | 15 | 15 |
| 4 | D_12 | L_20 | | 1 | 1 | 0 | 0 | 0 | 0 | 0 | 16 | 2 |
| | | L_21 | | | 1 | 3 | 1 | 6 | 1 | 4 | 15 | 16 |
| | | L_22 | | | 1 | 3 | 2 | 7 | 1 | 2 | 15 | 16 |
| | | L_23 | | | 1 | 1 | 1 | 6 | 0 | 3 | 15 | 12 |
| | D_13 | L_24 | 1 | 1 | 1 | 3 | 1 | 6 | 1 | 3 | 17 | 17 |
| 5 | D_14 | L_25 | 1 | 1 | 1 | 3 | 1 | 4 | 1 | 3 | 17 | 15 |
| | | L_26 | | | 1 | 3 | 1 | 6 | 1 | 2 | 15 | 14 |
| | D_15 | L_27 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 | 16 |
| | | L_28 | | | 1 | 5 | 1 | 5 | 1 | 3 | 15 | 16 |
| | D_16 | L_29 | | 1 | 1 | 3 | 2 | 3 | 1 | 3 | 16 | 14 |
| | | L_30 | | | 1 | 2 | 1 | 6 | 1 | 0 | 15 | 11 |
| 6 | D_17 | L_31 | 1 | 1 | 1 | 1 | 1 | 4 | 0 | 1 | 17 | 10 |
| | | L_32 | | | 1 | 5 | 1 | 7 | 1 | 1 | 15 | 16 |
| | | L_33 | | | 1 | 2 | 1 | 5 | 1 | 2 | 15 | 12 |
| | D_17 | L_34 | | 1 | 1 | 2 | 1 | 6 | 1 | 3 | 16 | 15 |
| | | L_35 | | | 1 | 3 | 0 | 7 | 1 | 1 | 15 | 13 |
| 7 | D_19 | L_36 | 1 | 1 | 1 | 3 | 1 | 6 | 1 | 3 | 17 | 17 |
| | | L_37 | | | 1 | 3 | 1 | 5 | 1 | 3 | 15 | 14 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | D_20 | L_38 | | 1 | 1 | 3 | 0 | 6 | 1 | 2 | 16 | 14 |
| | D_21 | L_39 | | 1 | 1 | 3 | 1 | 6 | 1 | 1 | 16 | 14 |
| | | L_40 | | | 1 | 3 | 1 | 4 | 0 | 2 | 15 | 11 |
| 8 | D_22 | L_41 | 1 | 1 | 1 | 3 | 1 | 6 | 1 | 3 | 17 | 17 |
| | | L_42 | | | 1 | 3 | 1 | 6 | 1 | 3 | 15 | 15 |
| | D_23 | L_43 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 | 16 |
| | | L_44 | | | 1 | 3 | 1 | 6 | 1 | 3 | 15 | 15 |
| | D_24 | L_45 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 | 16 |
| | | L_46 | | | 1 | 3 | 0 | 6 | 1 | 3 | 15 | 14 |
| | D_25 | L_47 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 | 16 |
| | D_26 | L_48 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 | 16 |
| | | L_49 | | | 1 | 3 | 1 | 6 | 1 | 3 | 15 | 15 |
| 9 | D_27 | L_50 | 1 | 1 | 1 | 3 | 0 | 8 | 1 | 3 | 17 | 18 |
| | | L_51 | | | 1 | 3 | 0 | 2 | 0 | 4 | 15 | 10 |
| | D_28 | L_52 | | 1 | 1 | 3 | 1 | 6 | 1 | 3 | 16 | 16 |
| | | L_53 | | | 1 | 3 | 1 | 7 | 1 | 3 | 15 | 16 |
| **ចំនួនកម្រងសំណួរដែលបានបែងចែក** | | | 9 | 28 | 52 | 148 | 45 | 285 | 46 | 126 | **832** | **100** |
| **ចំនួនដែលបានផ្ញើត្រឡប់មកវិញ** | | | 9 | 31 | 51 | 154 | 46 | 289 | 47 | 134 | **761** | **91.46** |
| **ចំនួនកម្រងសំណួរដែលអាចប្រើបាន** | | | 8 | 29 | 39 | 148 | 36 | 270 | 42 | 113 | **685** | **82.21** |

## ឧបសម្ព័ន្ធទី ៣: ចំណុចគន្លឹះនៃការពិនិត្យការអនុវត្តការអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សាបឋមភូមិនៅកម្ពុជា

| ប្រធានបទដែលត្រូវពិនិត្យ | | កូដចម្លើយ | ឧបករណ៍សម្រាប់វិភាគ |
|---|---|---|---|
| **ប្រធានបទគោល** | **ប្រធានបទរង** | | |
| ១) ការតម្រង់ទិសភាពជាអ្នកដឹកនាំ | a. ការយល់ដឹងពីការអប់រំបំណិនជីវិត | 1 = មិនដឹង<br>2= ដឹង (សូមបញ្ជាក់) | - តារាងប្រេកង់ (ប្រេកង់ និងភាគរយ)<br>- ក្រាបផ្ចិត |
| | b. ការណែនាំ សេចក្តីណែនាំនិងការផ្សព្វផ្សាយអនុវត្ត | 1 = មិនបាន<br>2 = បាន | - តារាងប្រេកង់ (ប្រេកង់ និងភាគរយ)<br>- ក្រាបផ្ចិត |
| ២) ការអនុវត្ត និងការប្រតិបត្តិ | a. បំណិនដែលបានអនុវត្ត | 1 = មិនបាន<br>2 = បាន | - តារាងប្រេកង់ (ប្រេកង់ និងភាគរយ)<br>- ក្រាបផ្ចិត |
| | b. ការអនុវត្តកម្មវិធី | 1 = ផ្អែកតាមកម្មវិធីសិក្សារបស់ក្រសួង.អយក<br>2 = ផ្អែកតាមតម្រូវការមូលដ្ឋាន<br>3 = ផ្សេងៗ (សូមបញ្ជាក់:) | - តារាងប្រេកង់ (ប្រេកង់ និងភាគរយ)<br>- ក្រាបផ្ចិត |
| | c. បំណិនជីវិតដែលបានអនុវត្ត | 1 = មិនបាន<br>2 = បាន | - តារាងប្រេកង់ (ប្រេកង់ និងភាគរយ)<br>- តារាង |
| | d. ភាពញឹកញាប់ | 1 = មិនដែលសោះ<br>2 = តិចជាង ១ម៉ោងក្នុង១សប្តាហ៍ | - តារាងប្រេកង់ (ប្រេកង់ និងភាគរយ)<br>- ក្រាបសសរ |

| | | | |
|---|---|---|---|
| | | 3 = ១ម៉ោងក្នុង១សប្តាហ៍<br>4 = ២ម៉ោងក្នុង១សប្តាហ៍<br>5 = លើសពី ២ម៉ោងក្នុង១សប្តាហ៍ | |
| | e. វិធីសាស្ត្របង្រៀន | 1 = ទ្រឹស្តីសុទ្ធ<br>2 = ទ្រឹស្តីច្រើនជាងអនុវត្ត<br>3 = អនុវត្តច្រើនជាងទ្រឹស្តី<br>4 = ផ្សេងៗ | - តារាងប្រេកង់ (ប្រេកង់ និងភាគរយ)<br>- ក្រាបសសរ |
| | f. ការរៀបចំគ្រូបង្រៀន (ការគាំទ្រផ្នែកធនធានមនុស្ស | | |
| | f.1. គ្រូជំនាញឯកទេស | 1 = មិនមាន<br>2 = មាន តែមិនគ្រប់គ្រាន់<br>3 = មានគ្រប់គ្រាន់ | - តារាងប្រេកង់ (ប្រេកង់ និងភាគរយ)<br>- ក្រាបផ្លិត |
| | f.2. ការរៀបចំគ្រូ | 1 = ដាក់គ្រូដែលមានស្រាប់<br>2 = ដាក់គ្រូមុខវិជ្ជាផ្សេងៗជំនួស<br>3 = ស្នើជំនួយពីសហគមន៍<br>4 = ផ្សេងៗ | - តារាងប្រេកង់ (ប្រេកង់ និងភាគរយ)<br>- ក្រាបសសរ |

| | | | |
|---|---|---|---|
| | f.3. ការគាំទ្រការបណ្តុះបណ្តាលគ្រូ | 1 = មិនបាន<br>2 = បាន | - តារាងប្រេកង់ (ប្រេកង់ និងភាគរយ)<br>- ក្រាបផ្លិត |
| | g. ការពិនិត្យតាមដាន | | |
| | g.1. ការពិនិត្យតាមដាន | 1 = មិនបាន<br>2 = បាន | - តារាងប្រេកង់ (ប្រេកង់ និងភាគរយ)<br>- ក្រាបផ្លិត |
| | g.2. វិធីសាស្រ្តពិនិត្យតាមដាន | 1 = ប្រើឧបករណ៍វាយតម្លៃ<br>2 = ផ្អែកតាមរបាយការណ៍<br>3 = ផ្សេងៗ | - តារាងប្រេកង់ (ប្រេកង់ និងភាគរយ)<br>- ក្រាបផ្លិត |
| | h. ការយល់ឃើញពីវឌ្ឍនភាព | 1 = មិនមានអ្វីប្រែប្រួលទាល់តែសោះ<br>2 = ប្រែប្រួលតិចតួច<br>3 = ប្រែប្រួលខ្លះ<br>4 = ប្រែប្រួលខ្លាំង<br>5 = ប្រែប្រួលទាំងស្រុង | - តារាងប្រេកង់ (ប្រេកង់ និងភាគរយ)<br>- ក្រាបសសរ |
| | i. ភាពឆ្លើយតប | | |
| | i.1. ក្រសួង.អយក<br>i.2. មូលដ្ឋាន | 1 = មិនមានភាពឆ្លើយតបទាល់តែសោះ<br>2 = ឆ្លើយតបតិចតួច | - តារាងប្រេកង់ (ប្រេកង់ និងភាគរយ)<br>- ក្រាបសសរ |

| | |
|---|---|
| | ▪ ផ្តល់ថវិកាសម្រាប់គាំទ្រអ្នកជំនាញ និងទិញសម្ភារបង្រៀន |
| **ការិយ៉ាល័យ.អយក** | ▪ ជំរុញសាលារៀនអនុវត្តបំណិនជីវិតឱ្យបានពេញលេញ<br>▪ រៀបចំហេដ្ឋារចនាសម្ព័ន្ធ (ឧ.សាងសង់អគារ)<br>▪ ផ្តល់កញ្ចប់ថវិកាសម្រាប់ ទិញសម្ភារៈ និងគាំទ្រការពិនិត្យតាមដានការអនុវត្តកម្មវិធីបំណិនជីវិត<br>▪ បណ្តុះបណ្តាល និងបញ្ជូនគ្រូជំនាញតាមតម្រូវការរបស់សាលារៀន<br>▪ រៀបចំ និងបញ្ចូលមេរៀនបំណិនជីវិតទៅក្នុងកម្មវិធីសិក្សាជាតិ<br>▪ បំប៉នសមត្ថភាពបន្ថែមដល់នាយកឬនាយិកាសាលា និងគ្រូមុខវិជ្ជាបំណិនជីវិត<br>▪ ចេញសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីអប់រំបំណិនជីវិតមូលដ្ឋាននៅមធ្យមសិក្សាបឋមភូមិ<br>▪ លើកទឹកចិត្ត និងចេញប័ណ្ណសរសើរដល់សាលាដែលអនុវត្តបានល្អ |
| **នាយក ឬនាយិកាសាលា** | ▪ ផ្តល់ឯកសារ និងសម្ភារៈជាក់ស្តែងដែលបង្កភាពងាយស្រួលដល់ការបង្រៀន<br>▪ បំប៉នគ្រូដែលមានឧបនិស្ស័យឱ្យក្លាយជាគ្រូជំនាញ<br>▪ ធ្វើការជ្រើសរើស បណ្តុះបណ្តាល និងផ្តល់គ្រូឯកទេសបំណិនជីវិត *កុំព្យូទ័រ កសិកម្ម ពាងជាង សិល្បៈ* ឱ្យបានគ្រប់គ្រាន់គ្រប់សាលារៀន<br>▪ បំពាក់ និងផ្តល់សម្ភារបរិក្ខារឱ្យបានគ្រប់គ្រាន់សម្រាប់ដំណើរការការអនុវត្តការអប់រំបំណិនជីវិត (*កុំព្យូទ័រ ពាងជាង បន្ទប់*)<br>▪ ជួយកៀគរដៃគូ សម្រាប់ជួយសាលាបន្ថែម<br>▪ ផ្តល់វគ្គបណ្តុះបណ្តាលបំណិនជីវិតក្នុងពេលវិស្សមកាលនាយក គ្រូ សិស្ស |

### ១) បំណិនជីវិតតាមមូលដ្ឋានបន្ថែមដែលត្រូវដាក់ពិចារណា

| | | |
|---|---|---|
| **បំណិនទន់** | ការធ្វើសេចក្តីសម្រេចចិត្ត<br>ការដោះស្រាយបញ្ហា (ផ្ទាល់ខ្លួននិងសង្គម)<br>ការគិតច្នៃប្រឌិត<br>ការត្រិះរិះពិចារណា<br>ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព<br>ជំនាញទំនាក់ទំនងអន្តរបុគ្គល<br>ការស្គាល់ខ្លួនឯង<br>ការអាណិតអាសូរ<br>ការអត់ធ្មត់<br>ការគ្រប់គ្រងភាពតានតឹង | |
| **បំណិនអាជីពងាយៗ** | គេហវិទ្យា | ជំនាញឆុងកាហ្វេ ធ្វើនំ សំអាងការ កាត់សក់ |
| | សិល្បៈ | របាំ តន្ត្រី ចម្រៀង |
| | កុំព្យូទ័រ | កម្មវិធីមូលដ្ឋានសម្រាប់ការិយាល័យ |

| | | |
|---|---|---|
| | រោងជាង | ជួសជុលខ្នាតតូច ម៉ូតូ កង់ ទូរស័ព្ទ ទូរទស្សន៍)-ល-(<br>សិប្បកម្មខ្នាតតូច (ជាងដែក ជាងកំបោរ) |
| | កសិកម្ម | ការដាំដំណាំនានា |

## ២ ) បញ្ហាប្រឈម

| ល.រ | បញ្ហាប្រឈមក្នុងការអនុវត្តការអប់រំបំណិនជីវិត |
|---|---|
| ១ | ការបណ្តុះបណ្តាលគ្រូបំណិនជីវិតបានតិចតួច ទើប)តែបាន២ជំនាន់ ស្មើនឹង៤០នាក់( |
| ២ | គ្រូដែលទទួលបានការបំប៉នអប់រំបំណិនជីវិតមានតិចតួច |
| ៣ | កម្មវិធីសិក្សាលម្អិតថ្មីបានផ្សព្វផ្សាយប៉ុន្តែមិនបានអនុវត្ត<br>ការផ្សព្វផ្សាយបន្តលើឯកសារពាក់ព័ន្ធមិនទាន់បានទូលំទូលាយ |
| ៤ | សៀវភៅសិក្សាគោលមិនគ្រប់គ្រាន់ (បើប្រធានបទថ្មីខុសពីសៀវភៅសិក្សាគោល គ្រូត្រូវរៀបចំដោយខ្លួនឯង) |
| ៥ | ខ្វះគ្រូបង្រៀនឯកទេសបំណិនជីវិត |
| ៦ | វិធីសាស្រ្តបង្រៀនរបស់គ្រូនៅមានកម្រិត (គ្រូមិនទាន់ច្បាស់ពីបំណិនជីវិត និងមិនចេះរៀបចំកិច្ចតែងការ) |
| ៧ | ម៉ោងសិក្សា និងអនុវត្តតិច ១ម៉)/សប្តាហ៍ (=> ២ម៉)/សប្តាហ៍)<br>ការអនុវត្តការរៀន និងបង្រៀនបំណិនជីវិតតាមមូលដ្ឋាន ៦ដំណាក់កាល<br>(១ឆមាស ១ប្រធានបទ) |
| ៨ | ការចូលរួមមិនទាន់បានពេញលេញ៖<br>- សហគមន៍មិនទាន់បានចូលរួមពេញលេញ (ខ្វះអ្នកបច្ចេកទេសនៅតាមសហគមន៍ក្នុងការចែករំលែក បទពិសោធន៍) |

| | |
|---|---|
| | - សិស្សពុំសូវចាប់អារម្មណ៍ និងឱ្យតម្លៃ |
| ៩ | ខ្វះថវិកាគាំទ្រអ្នកជំនាញមកបង្រៀន និងទិញសម្ភារបង្រៀន |
| ១០ | កង្វះយន្តការពិនិត្យតាមដាន និងវាយតម្លៃ |
| ១១ | កន្លែភូមិសាស្រ្តៈ ហេដ្ឋារចនាសម្ព័ន្ធមិនទាន់មានលក្ខណៈសមស្រប |

## ៣ ) ការអន្តរាគមន៍

| Relevant person | Interventions |
| --- | --- |
| **មន្ទីរ អយក** | ▪ លើកស្នើកម្មវិធីបណ្តុះបណ្តាល តាមកម្រិតថ្នាក់ (ថ្នាក់ទី៧ ដល់៩)ទៅក្រសួងអប់រំ<br>▪ បើកវគ្គបំប៉នដល់គ្រូបង្រៀនលើការអប់រំបំណិនជីវិត (វគ្គខ្លីៗ ៥ថ្ងៃ x ៣ដង)<br>▪ អនុវត្តប្រឹក្សាអាជីពនៅតាមសាលារៀនដើម្បីដឹងពីតម្រូវការរបស់សិស្ស និងបើកវគ្គបំប៉នគ្រូ )(វគ្គខ្លីៗ ៥ថ្ងៃ x ២ដង)<br>▪ ផ្សព្វផ្សាយកម្មវិធីសិក្សាលម្អិតបន្តដល់សាលារៀន<br>▪ ថតចម្លងរាល់កម្មវិធីសិក្សាដែលមាន និងចែកតាមសាលារៀន<br>▪ ស្នើតម្រូវការសៀវភៅសិក្សាគោលបំណិនជីវិតទៅក្រសួងអយក<br>▪ ផ្តល់អាទិភាពឱ្យសាលាជ្រើសរើសគ្រូមុខវិជ្ជាផ្សេងឱ្យបង្រៀនមុខវិជ្ជាបំណិនជីវិត (ឧ.មានគ្រូមុខវិជ្ជាខ្មែរ និងផ្នែក សង្គម ទៅបង្រៀនមុខវិជ្ជាបំណិនជីវិត)<br>▪ ពង្រឹងការអនុវត្តរបស់គ្រូលើការបង្រៀនអប់រំបំណិនជីវិត<br>▪ ចុះពិនិត្យការបង្រៀនអប់រំបំណិនជីវិត និងមើលកិច្ចតែងការបង្រៀន<br>▪ ណែនាំសាលារៀនឱ្យយកម៉ោងទៅតាមលទ្ធភាពរបស់សាលានីមួយៗ<br>▪ មិនទាន់អនុវត្តជាទូទៅនៅតាមខេត្តនៅឡើយ<br>▪ ប្រជុំជាមួយគណៈគ្រប់គ្រងតាមសាលារៀន ដើម្បីបង្កើនទំនាក់ទំនងល្អជាមួយសហគមន៍ |

| | |
|---|---|
| | ▪ ណែនាំឱ្យសាលាបង្រៀនតាមកម្មវិធីរបស់ក្រសួង<br>▪ ប្រជុំផ្សព្វផ្សាយ និងពង្រឹងគណៈគ្រប់គ្រងសាលារៀនជួយកៀរគរសហគមន៍ សប្បុរសជន អង្គការ ដៃគូ |
| ការិ-អយក | ▪ ជំរុញការរៀបចំផែនការបង្រៀនប្រចាំឆ្នាំទាក់ទងនឹងបំណិនជីវិត និងដាក់បញ្ចូលទៅនឹងប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន<br>▪ ណែនាំប្រធានក្រុមបច្ចេកទេស និងគ្រូឱ្យរៀបចំផែនការសកម្មភាពលម្អិតទាក់ទង នឹងការបង្រៀនបំណិនជីវិត<br>▪ ចូលរួមប្រជុំឆ្លងផែនការ និងផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ<br>▪ ចូលរួមស្វែងរកដៃគូគាំទ្រ ថវិកា និងបច្ចេកទេស<br>▪ ប្រជុំជាមួយគណៈកម្មការគ្រប់គ្រងសាលា  អាជ្ញាធរ អ្នកអាណាព្យាបាល មាតាបិតាសិស្ស ដើម្បីជួយគាំទ្រទៅលើកម្មវិធីបំណិនជីវិតក្នុងសាលារៀន<br>▪ ស្វែងរកទីផ្សារដើម្បីលើកកម្ពស់ផលិតផលដែលផលិតបានក្នុងសាលាសហគមន៍<br>▪ ផ្សព្វផ្សាយឱ្យបានទូលំទូលាយ ឬបណ្តុះបណ្តាលដល់នាយកសាលា គ្រូ សហគមន៍ ឱ្យបានយល់ច្បាស់<br>▪ ស្នើសុំជ្រើសរើសគ្រូកិច្ចសន្យាពីសហគមន៍ ដែលមានជំនាញស្រាប់<br>▪ ពិនិត្យតាមដាន និងបូកសរុបលទ្ធផលការអនុវត្តកម្មវិធីអប់រំបំណិនជីវិត |

| | |
|---|---|
| **នាយក ឬនាយិកាសាលា** | ▪ បង្កើតគណៈកម្មការទទួលបន្ទុកផ្នែកបំណិនជីវិត<br>✓ កៀរគរសហគមន៍ឱ្យចូលរួមតាម រយៈការចូលរួមប្រជុំផ្សព្វផ្សាយ ពិគ្រោះយោបល់ស្ដីពីសារសំខាន់នៃការអប់រំបំណិនជីវិត ស្វែងរកមូលនិធិពីអង្គការ ពីដៃគូ ...<br>✓ ត្រូវធ្វើការតាមដានជាប្រចាំទៅការអនុវត្តការអប់រំបំណិនជីវិត<br>▪ លើកទឹកចិត្តគ្រូដែលមានឧបនិស្ស័យលើការអប់រំបំណិនជីវិត ( ....មានប័ណ្ណសរសើរ ប្រាក់លើកទឹកចិត្ត)<br>▪ ណែនាំសិស្សឱ្យមានសៀវភៅសម្រាប់កត់ត្រាចំណុចសំខាន់ដែលលោកគ្រូ អ្នកគ្រូបញ្ជ្រាបឱ្យបានគ្រប់គ្នា<br>▪ បញ្ជ្រាបជាប្រចាំនៅពេលគោរពទង់ជាតិ<br>▪ ណែនាំគ្រូឱ្យបញ្ជ្រាបនៅតាមថ្នាក់រៀនជាប្រចាំ<br>▪ ធ្វើការផ្សព្វផ្សាយពីសៀវភៅការអប់រំបំណិនជីវិតដល់លោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធ<br>▪ ដឹកនាំកំណត់ប្រធានបទមុនពេលបើក បវេសនកាល ជាមួយអ្នកពាក់ព័ន្ធ<br>▪ ត្រូវមានផែនការអនុវត្តឱ្យបានច្បាស់លាស់ (កាលវិភាគ)<br>▪ ចំពោះបញ្ហាទីតាំងភូមិសាស្ត្រតូច យើងអាចជ្រើសរើសប្រធានបទផ្សេងក្រៅពីកសិកម្ម ឬអាចឱ្យសិស្សយកបច្ចេកទេសអនុវត្តនៅតាមផ្ទះ |

## ៤) សំណូមពរទៅកាន់ក្រសួងអប់រំ យុវជន និងកីឡា

| អ្នកពាក់ព័ន្ធ | សូមឱ្យក្រសួង៖ |
|---|---|
| មន្ទីរ.អយក | ▪ បណ្តុះបណ្តាលគ្រូឯកទេសបំណិនជីវិតសម្រាប់មធ្យមសិក្សាបឋមភូមិ កន្លងមកបណ្តុះបណ្តាលតែគ្រូនៅនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស<br>▪ ចេញលិខិតអនុញ្ញាតឱ្យមន្ទីរអយកបើកវគ្គបំប៉នអប់រំបំណិនជីវិត .<br>▪ ផ្តល់គ្រូឧទ្ទេសថ្នាក់ជាតិដើម្បីចុះទៅសិក្សាពីតម្រូវការនៅសាលារៀន<br>▪ អនុញ្ញាតឱ្យប្រើប្រាស់កម្មវិធីសិក្សាលម្អិត ដើម្បីមានការឯកភាពគ្នា (ព្រោះមិនទាន់មានសៀវភៅសម្រាប់កម្មវិធីថ្មីនេះទេ)<br>▪ ផ្តល់សៀវភៅសិក្សាបំណិនជីវិតតាមតម្រូវការ<br>▪ ផ្តល់គ្រូឯកទេសបំណិនជីវិត<br>▪ ផ្តល់វគ្គបណ្តុះបណ្តាលវិធីសាស្ត្របង្រៀនអប់រំបំណិនជីវិតដល់គ្រូបង្រៀន<br>▪ បន្ថែមយ៉ាងហោចណាស់ ២ម៉ោង ក្នុង១សប្តាហ៍សម្រាប់មុខវិជ្ជាអប់រំបំណិនជីវិត<br>▪ អនុញ្ញាតឱ្យអនុវត្តគ្រប់សាលាទូទាំងប្រទេស កន្លងមក អនុវត្តតែនៅសាលាគោលដៅរបស់គម្រោង<br>▪ ជំរុញលើកទឹកចិត្តដល់គណៈគ្រប់គ្រងតាមសាលារៀនឱ្យមានកិច្ចសហការជាមួយសហគមន៍ លើការគាំទ្រការអប់រំបំណិនជីវិត<br>▪ ផ្តល់អាទិភាពដល់សាលារៀនដើម្បីជ្រើសរើសអ្នកបច្ចេកទេសនៅតាមសហគមន៍ដែលមានបទពិសោធន៍តាមជំនាញ |

| | |
|---|---|
| | ▪ ផ្តល់ថវិកាសម្រាប់គាំទ្រអ្នកជំនាញ និងទិញសម្ភារបង្រៀន |
| **ការិយ៍យ.អយក** | ▪ ជំរុញសាលារៀនអនុវត្តបំណិនជីវិតឱ្យបានពេញលេញ<br>▪ រៀបចំហេដ្ឋារចនាសម្ព័ន្ធ (ឧ.សាងសង់អគារ)<br>▪ ផ្តល់កញ្ចប់ថវិកាសម្រាប់ ទិញសម្ភារៈ និងគាំទ្រការពិនិត្យតាមដានការអនុវត្តកម្មវិធីបំណិនជីវិត<br>▪ បណ្តុះបណ្តាល និងបញ្ជូនគ្រូជំនាញតាមតម្រូវការរបស់សាលារៀន<br>▪ រៀបចំ និងបញ្ចូលមេរៀនបំណិនជីវតទៅក្នុងកម្មវិធីសិក្សាជាតិ<br>▪ បំប៉នសមត្ថភាពបន្ថែមដល់នាយកឬនាយិកាសាលា និងគ្រូមុខវិជ្ជាបំណិនជីវិត<br>▪ ចេញសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីអប់រំបំណិនជីវិតមូលដ្ឋាននៅមធ្យមសិក្សាបឋមភូមិ<br>▪ លើកទឹកចិត្ត និងចេញប័ណ្ណសរសើរដល់សាលាដែលអនុវត្តបានល្អ |
| **នាយក ឬនាយិកាសាលា** | ▪ ផ្តល់ឯកសារ និងសម្ភារៈជាក់ស្តែងដែលបង្កភាពងាយស្រួលដល់ការបញ្រ្ជាប<br>▪ បំប៉នគ្រូដែលមានឧបនិស្ស័យឱ្យក្លាយជាគ្រូជំនាញ<br>▪ ធ្វើការជ្រើសរើស បណ្តុះបណ្តាល និងផ្តល់គ្រូឯកទេសបំណិនជីវិត *កុំព្យូទ័រ កសិកម្ម ពាងជាង សិល្បៈ* ឱ្យបានគ្រប់គ្រាន់គ្រប់សាលារៀន<br>▪ បំពាក់ និងផ្តល់សម្ភារបរិក្ខារឱ្យបានគ្រប់គ្រាន់សម្រាប់ដំណើរការការអនុវត្តការអប់រំបំណិនជីវិត (*កុំព្យូទ័រ ពាងជាង បន្ទប់)*<br>▪ ជួយកៀគរដៃគូ សម្រាប់ជួយសាលាបន្ថែម<br>▪ ផ្តល់វគ្គបណ្តុះបណ្តាលបំណិនជីវិតក្នុងពេលវិស្សមកាលនាយក គ្រូ សិស្ស |